CSC
Formation, Dialogue, Cooperation

# អ្នកនាំសារ The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី៨ សម្រាប់ខែកក្កដា ឆ្នាំ២០១៦ លក់តម្លៃ ១០០០រៀល

លេខ ៩៥



## ព្រះសហគមន៍កាតូលិកតូចមួយភាគច្រើនត្រូវពេញចិត្តបង្កើតសហគ្រិនសង្គមនៅកម្ពុជា

## សេចក្ដីជូនដំណឹង

" លោហិតមរណសាក្សី គឺគ្រាប់ពូជរបស់ព្រះសហគមន៍ " (Apologeticus, Chapter 50:Tertullian)។ បងប្អូន ជាទីស្រឡាញ់ ព្រះសហគមន៍កាតូលិកកម្ពុជារីកចម្រើនដោយសារឈាមមរណសាក្សី។ ខ្ញុំលោកបូជាចារ្យ រឿង ឆ័ត្រសិរី អ្នករៀបចំសំណុំរឿង (Postulator) បានប្រមូលព័ត៌មានមួយចំនួនហើយ ប៉ុន្តែសូមបងប្អូនជួយផ្ដល់ព័ត៌មានបន្ថែម អំពីអ្នកបម្រើរបស់ព្រះជាម្ចាស់ថែមទៀតដូចជា រូបថត អត្ថបទ ឬសៀវភៅដែលគាត់សរសេរវត្ថុអនុស្សាវរីយរបស់គាត់ខ្លះ។ល។ សូមផ្ដល់ឈ្មោះអ្នកដែលអាចផ្ដល់សក្ខីភាពបានជូនមកខ្ញុំតាមរយៈអាសយដ្ឋានខាងក្រោម

Tel : 077 800 211 / 096 34 22 144

ប្រអប់សំបុត្រលេខ ១២៣ រាជធានីភ្នំពេញ

Email: martyrscambodia@gmail.com

# រូបភាពប្រចាំខែ

តើលោកអ្នកមើលឃើញសារព្រមានពីគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងស្រវឹង បានប៉ុន្មានភាគរយ ពីផ្ទាំងប៉ាណូផ្សាយពាណិជ្ជកម្មដែលគេឃើញផ្សាយជាទូទៅនៅទូទាំងរាជធានីភ្នំពេញ ចំណុចដែលមានមនុស្សឆ្លងកាត់មមាញឹកដូចក្នុងរូបភាពនេះ ?








កម្ពុជាត្រូវបានគេដឹងថា គឺជាឋានសួរនៃការប្រើប្រាស់គ្រឿងស្រវឹងមួយ នៅក្នុងតំបន់។ មកដល់ពេលបច្ចុប្បន្ននេះ ក្រៅពីរោងចក្រស្រាបៀរ និងស្រាជាច្រើនប្រភេទជាច្រើនយីហោរដែលផលិត និងផ្គត់ផ្គង់នៅក្នុងស្រុក កម្ពុជាក៏បាននាំចូល ស្រាបៀរ ស្រាវីស្គី ស្រាក្រហម រាប់សិបប្រភេទមកកាន់ទីផ្សារដែលមានប្រជាពលរដ្ឋប្រមាណជា ១៥លាននាក់នេះ។



បើស្រវឹងសូមកុំបើកបរ! នេះជាពាក្យស្លោកដែលគេតែងតែឮ តែងតែបានឃើញជាប្រចាំ ប៉ុន្តែជាទូទៅតួរលេខនៃគ្រោះថ្នាក់ចរាចរណ៍ដែលកើតមានឡើងដោយសារតែគ្រឿងស្រវឹងនៅតែជាកត្តាមូលហេតុចំបងនៅកម្ពុជា។

Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ

Tel/Fax : (855) 23 224 120

Email : csccambodia@gmail.com / Website : www.catholiccambodia.org

ចាងហ្វាង : លោក លី សុវណ្ណា
សេចក្ដីប្រកាសលេខ: ១០១ ព.ម.ប្រ.ក/ ០៥-កុម្ភៈ-២០១៤

# ទស្សនៈ ក្បាលដំរី កន្ទុយកណ្តុរ កំពុងកើតមានក្នុងបរិបថសង្គមកម្ពុជា

ដំរីជាសត្វមួយប្រភេទដែលមានក្បាលធំ ត្រចៀកធំ ខ្លួនក៏ធំ ហើយកន្ទុយវាក៏សមតាមនោះទៅតាម ធម្មជាតិនៃពូជអំបូរ ជាសត្វដំរី រីឯកណ្តុរជាប្រភេទសត្វដែលមានខ្លួនតូច ហើយកន្ទុយរបស់វាមានចុងស្តួចតូចទៅក៏នៅតែមានភាពសមសួននឹងដងខ្លួនរបស់វាដែរ ដូច្នេះ បើដំរីមានក្បាលធំហើយមានកន្ទុយប៉ុន កន្ទុយកណ្តុរមិនសមសួន និងខ្លួនវាឡើយ តែបើកណ្តុរមាឌតូចនេះមានក្បាលធំវិញក៏ជារឿងចម្លែកដែរ។

យើងបកមកសង្គមកម្ពុជាវិញម្តងតាមការសង្កេតរកន្លងមក វាពិតណាស់គឺបានផុសផុលតែមួយរយៈពេលប៉ុណ្ណោះហើយក៏រសាយទៅវិញ។ តើនេះពិតជាលក្ខណៈផ្លូវចិត្តរបស់មហាជនកម្ពុជា ឬយ៉ាង?

យើងខ្ញុំសូមលើកយកតែព្រឹត្តការណ៍មួយចំនួនមកបង្ហាញដូចតទៅ ជាក់ស្តែងគឺ ព្រឹត្តិការណ៍បាញ់ប្រហារ លើសិល្បៈការីនី ពិសិដ្ឋពិលីកា មានមហាជនជាច្រើនផុសផុល ចូលរួមមរណៈទុក្ខ ចូលរួមសោកសង្រេង សម្រក់ទឹកភ្នែក ស្រែកត្រូវតែរកយុត្តិធម៌ជូបសព អ្នកស្រីពិសិដ្ឋពិលីកា មានមនុស្សចូលរួបរាប់ពាន់ក្នុងពិធីបូជាសព។ មួយរយៈក្រោយមកស្ងាត់ឈឹង គ្មាននរណាម្នាក់និយាយរឿងហ្នឹងទៀត ហើយសម្លេងជុំវិញបញ្ហានេះក៏តិចទៅៗ ដោយមានតែបក្សប្រឆាំងប៉ុណ្ណោះស្រែកព្រោះតែផលចំណេញសម្រាក់ពួកគេ។ តើសម្រែករកយុត្តិធម៌នៅថ្ងៃនោះពិតជាបាត់ទៅតាមផ្សែងនៃការបូជាសពមែនឬ?

ព្រឹត្តិការណ៍មួយទៀតដែលគួរឲ្យចាប់អារម្មណ៍គឺ ការសម្លាប់លោកជា វិជ្ជា ម្នាក់ៗក៏បានស្រែក ចេញមកមិនចាញ់ព្រឹត្តិការណ៍ នៃឃាតកម្ម លោកស្រីពិសិដ្ឋពិលីកាឡើយ។ ម្នាក់ៗសុទ្ធតែយំសោកសង្រេង និងបានហៅលោកជា វិជ្ជា ថាជាវិរៈជនកម្មករ។ មួយរយៈក្រោយមកក៏ស្ងាត់ទៅៗ ហើយ សម្រែករកយុត្តិធម៌ក៏ថយទៅៗផងដែរ ដោយមកដល់ពេលនេះគេឮតែមួយឆ្នាំម្តងតែប៉ុណ្ណោះ ហើយក៏ស្ងាត់ឈឹងបន្តទៀត។ ចំណែកនៅរាជធានីភ្នំពេញវិញពេល លោកចៅហ្វាយក្រុងថ្មី ឡើងកាន់អំណាចភ្លាមប្រកាសភ្លាមនូវបទបញ្ជា ដាក់បញ្ញាតិមិនឲ្យឡានធំៗ ឆ្លងកាត់រាជធានីឡើយ។ បទបញ្ជាត្រូវបានអនុវត្តភ្លាមមិនបង្អង់ តក្រោយមកពេញលើសដើម។ ចំណែកបទបញ្ជារបស់លោករដ្ឋមន្ត្រីសាធារណការក៏មិនខុសគ្នាប៉ុន្មាន មិនឲ្យមានការកសាងសងផ្លូវពេលថ្ងៃ បានមួយរយៈពេលនេះ នៅតែមាន តាមមហាវិថីសហព័ន្ធរុស្ស៊ី និងវិថីមួយចំនួនទៀតដែលបង្ករការកកស្ទះ។

រីឯអនុសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រីវិញក៏មិនខុសគ្នាតែគ្រាន់បានរយៈពេលយូរបន្តិច ដូចជា "មើលផ្លូវ" "ដោះស្រាយបញ្ហាដីធ្លី"។ល។ បានមួយរយៈអ្នកអនុវត្តន៍គោរពបានយ៉ាងល្អក្រោយមករសាយទៅៗ តាមខ្យល់ តាមពេលតាមវេលា។ នៅមានស្ថាប័នរដ្ឋឯកជននិងសង្គមស៊ីវិលមួយចំនួនទៀតក៏ស្រដៀងគ្នាដែរ។ មេស្រែកបានខិតខំ បើមិនស្រែកទេសុខសប្បាយរហូត។ សរុបមកព្រឹត្តិការណ៍ទាំងនេះឆ្លុះបញ្ចាំង ដល់ពលរដ្ឋកម្ពុជាថា គួរតែពិចារណា និងត្រូវមានគោលការណ៍ គោលជំហរយ៉ាងពិតប្រាកដចេញពិតចិត្តរបស់ខ្លួនពិតជាថា ស្រឡាញ់សង្គម ស្រឡាញ់សន្តិភាព ស្រឡាញ់យុត្តិធម៌ពិតៗ ប្រឆាំងនិងអំពើអាក្រក់ ប្រឆាំងអំពើពុករលួយ ចេញពីខ្លួនផ្ទាល់ មិនធ្វើតាមគ្នា តាមការញុះញង់ តាមការប្រមែប្រមូលរបស់បុគ្គល អ្នកនយោបាយឡើយ។ ចំពោះអ្នកអនុវត្តច្បាប់បើមិនប្តូររបៀប មិនប្តូររូបមន្តពីរបូកពីរ ស្មើប៉ុន្មានស្រេចតែមេនោះសង្គមមួយនេះមិនអាចអនុវត្តច្បាប់ប្រកបដោយយុត្តិធម៌ និងសមជានិតិរដ្ឋឡើយ។ សូមចៀសឲ្យបានចេញពីទស្សនៈក្បាលដំរីកន្ទុយកណ្តុរនេះទៅ។



***លោក លី សុវណ្ណា***
*ចាងហ្វាងកាសែតអ្នកនាំសារ*

សន្តិភាពគង់វង្ស ប្រទេសអភិវឌ្ឍជឿនលឿន! អយុត្តិធម៌សង្គមកាន់ខ្លាំងនាំឲ្យមានការបែកបាក់។

# លោកបូជាចារ្យ សិលា ទម្លាប់ សុផល ២១ ឆ្នាំក្នុងមុខងារជាបូជាចារ្យ

កាលពីថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៦ ព្រះសហគមន៍កាតូលិកបាត់ដំបងបានប្រារព្ធពិធីអរព្រះគុណព្រះជាម្ចាស់ ថ្ងៃខួប២១ឆ្នាំក្នុងជីវិតជាបូជាចារ្យរបស់លោក សិលា ទម្លាប់ សុផល។ ពិធីបុណ្យបានប្រារព្ធរួមគ្នាជាមួយខួប ១៦ឆ្នាំក្នុងមុខងារជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់របស់លោក អែនរីកេ ហ្វីការេដូ។

លោកបូជាចារ្យ សិលា ទម្លាប់ សុផល ប្រសូតនៅថ្ងៃទី១៨ សីហា ១៩៥៣ នៅភ្នំពេញ។ លោកចម្រើនវ័យឡើងនៅភ្នំពេញ ក្នុងក្រុមគ្រួសារគ្រីស្តបរិស័ទកាតូលិក។ ក្នុងពេលប្រទេសកម្ពុជាធ្លាក់ក្នុងភ្លើងសង្គ្រាម លោកបានចាកពីប្រទេសកម្ពុជា និងបានទទួលសិទ្ធិជ្រកកោននៅប្រទេសកាណាដា។ នៅប្រទេសមួយជឿនលឿនអាចរស់នៅដោយស្ងប់សុខ ហើយ តែព្រះជាម្ចាស់បានត្រាស់ហៅ ហើយលោកបានឆ្លើយតប នឹងការត្រាស់ហៅនេះ ដោយយកជីវិតជាបូជាចារ្យ។ លោកបានចូលរៀនទេវវិទ្យាល័យនៅប្រទេសកាណាដា និងបានមកបម្រើបងប្អូនគ្រីស្តបរិស័ទ ខ្លះនៅជំរំជនភៀសខ្លួនព្រំដែនខ្មែរ ថៃ។ លោក សុផល បានទទួលការតែងតាំងជាឧបដ្ឋាកក្នុងដើមទស្សវត្សទី៩០ នៅប្រទេសកាណាដា ហើយបានវិល ត្រឡប់មកប្រទេសកម្ពុជាវិញ ដើម្បីបម្រើ និងកសាងព្រះសហគមន៍កាតូលិកនៅកម្ពុជាឡើងវិញ រួមជាមួយសាសនទូតផ្សេងៗទៀត។ នៅថ្ងៃទី០២ កក្កដា ១៩៩៥ នៅភ្នំពេញលោកបានទទួលអគ្គសញ្ញាតែងតាំងជាបូជារ្យ ជាបូជាចារ្យជាតិកម្ពុជាដំបូង គេ ក្រោយសង្គ្រាមបង្ហូរឈាមជាច្រើនឆ្នាំកន្លងមក។



*ថតដោយៈ វណ្ណា*

ក្រោយការតែងតាំងជាបូជាចារ្យ លោកអភិបាលព្រះសហគមន៍កាតូលិកបានចាត់លោក ឲ្យទៅបម្រើព្រះសហកមន៍កាតូលិកនៅតំបន់កំពង់ធំ។ នៅកំពង់ធំលោកបានខិតខំអស់កម្លាំងកាយចិត្ត ប្រមែរប្រមូលគ្រីស្តបរិស័ទយកចិត្តទុកដាក់ និងពិធីបុណ្យ អប់រំជំនឿដល់គ្រីស្តបរិស័ទ យុវជននិងកុមារកិច្ចការសង្គហៈលើកទឹកចិត្តបងប្អូនគ្រីស្តបរិស័ទ ទទួលស្វាគមន៍បងប្អូននិងបានកសាងព្រះវិហារ នៃព្រះសហគមន៍ជាច្រើនផងដែរ។ លោកបានយកចិត្តលើវិស័យសិក្សាអប់រំចំណេះដឹងទូទៅដោយបង្កើតឲ្យមានកម្មវិធីអប់រំអក្ខរកម្មជំនាញកាត់ដេរ និងបានបង្កើតមណ្ឌលសិស្ស ដើម្បីផ្តល់ឱកាសដល់សិស្សក្រីក្រជាច្រើនបានបន្តការសិក្សានៅវិទ្យាល័យនិងបន្តនៅមហាវិទ្យាល័យ និងនៅតាមសាលាបច្ចេកទេសមួយចំនួន នៅភ្នំពេញផងដែរ។

នៅឆ្នាំ១៩៩៩ លោកអភិបាលបានចាត់លោក ឲ្យទទួលបេសកកម្មនៅកន្លែងថ្មី គឺនៅព្រះសហគមន៍កាតូលិកតំបន់ភូមិភាគបាត់ដំបង។ លោកបានខិតខំយ៉ាងខ្លាំងក្លា ក្នុងកិច្ចការបម្រើព្រះសគមន៍ តាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។

សព្វថ្ងៃលោកកំពុងទទួលខុសត្រូវនៅព្រះសហគមន៍ខ្នាចរមាស និងទំពូង។ អស់រយៈពេល ២១ឆ្នាំកន្លងមកនេះលោកបានខិតខំអស់កម្លាំងកាយចិត្ត តាមជំនឿនិងកម្លាំងដែលមកពីព្រះជាម្ចាស់ ក្នុងបេសកកម្មបម្រើព្រះសហកមន៍។

ក្នុងវ័យ ៦៣ឆ្នាំ លោកកំពុងមានជំងឺខ្លះបៀតបៀន ជាពិសេសរបួសដែលបានទទួលក្នុងគ្រោះថ្នាក់មួយ ពេលបំពេញមុខងារជាគ្រូបអប់រំជំនឿនៅជំរំ គឺរបួសនៅលើឆ្អឹងកងចង្កេះរបស់លោក ពេលនេះវាបានរើឡើងប៉ះពាល់ប្រព័ន្ធប្រាសាទផងដែរតក្សា និងផ្តល់កម្លាំងជានិច្ចដល់លោកឪពុក។

*ដោយ ៖ សុវណ្ណា*

# ប្រជាពលរដ្ឋកម្ពុជាហាក់មានការសង្ស័យនឹងផលិតផលកសិកម្មសរីរាង្គ

ព្រោះតែក្តីបារម្ភអំពីសុវត្ថិភាពនៅក្នុងការហូបចុក ដោយសារតែបញ្ហាបន្លែ ត្រី សាច់ គ្រឿងសមុទ្រ អាហារក្រៀម មានសារធាតុគីមីនោះ ប្រជាប្រិយភាពនៃផលិតកម្មកសិកម្មសរីរាង្គជាពិសេស គឺផលិតផលបន្លែសរីរាង្គនោះ គឺកំពុងតែមានការរីកចម្រើននិងឲ្យតម្លៃខ្ពស់ពីប្រជាពលរដ្ឋកម្ពុជា ប៉ុន្តែទន្ទឹមនឹង ការគាំទ្រ ពួកគេក៏កំពុងតែមានការសង្ស័យ និងព្រួយបារម្ភអំពីការក្លែងបន្លំ។

លោក រិន សុខណា ជាមន្ត្រីរាជការមួយរូបដែលមានវ័យ ៤២ ឆ្នាំ បានអះអាងថា ដោយសារតែក្តីបារម្ភ អំពីបញ្ហាសុវត្ថិភាពនៅក្នុងការហូបចុកនេះ គ្រួសារលោក គឺជាអតិថិជន និងជាអ្នកគាំទ្រមួយ ចំពោះផលិតផលកសិកម្មសរីរាង្គ។

លោក សុខណា បញ្ជាក់ថា "គ្រួសារខ្ញុំភាគច្រើនប្រើប្រាស់តែបន្លែ ផ្លែឈើ និងផលិតផលកសិកម្មដែលលក់នៅក្នុងហាងណាដែល គេអះអាងថាផលិតផលសរីរាង្គ លើកលែងតែបន្លែណាដែលអត់មាននៅក្នុងហាង"។

លោក សុខណា បានបន្តថា រឿងប្រយ័ត្នប្រយែងនៅក្នុងការហូបចុកនេះ គឺពិតជារឿងដែលគួរយកចិត្តទុកដាក់បំផុត ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏វាមិនមានសុវត្ថិភាព១០០ ភាគរយដែរ ដោយសារ ផលិផលកសិកម្មសរីរាង្គដែលលក់ គឺវាមិនបានគ្រប់មុខ ហើយក៏មិនគ្រប់គ្រាន់តាមសេចក្តីត្រូវការ ថែមទៀត ដោយជួនកាលមានទៅ ជួនកាលអត់ទៅហើយ បន្លែ ផ្លែឈើខ្លះ ក៏មិនមានលក់ម្តោះហើយ គ្មានគ្រួសារណាអាចជៀសពីការស្វែងរកចំណីអាហារនៅតាមទីផ្សារនោះទេ ។

លោកបានបញ្ជាក់ថា "សុវត្ថិភាពហូបចុកស្រុកយើងវានៅមិនទាន់ធានាពីការមិនប្រើប្រាស់គីមីនេះបាន១០០ ភាគរយទេ តែបើយើងប្រយ័ត្ន ក៏វាអាចកាត់បន្ថយបាន ៣០ ទៅ ៤០ ភាគរយអីដែរ"។

លោកស្រី សុខ កេសរ ដែលជាស្ត្រីមេផ្ទះវ័យប្រមាណជា ៥០ ឆ្នាំមួយរូប បានអះអាងថា នៅស្រុកខ្មែរយើងឥឡូវនេះ លោកស្រីគិតថា គ្មាននរណាអាចគេចរួចពី អាហារដែលមានគីមី នោះទេ ព្រោះវាទូទៅទៅហើយ ប៉ុន្តែម្នាក់ៗចេះតែប្រយ័ត្ន និងព្យាយាមកាត់បន្ថយវាតែប៉ុណ្ណោះ ។

លោកស្រីបានរៀបរាប់ថា នៅក្នុងហាងដែលយើងជឿទុកចិត្តថា មានផលិតផលដែលមិនប្រើប្រាស់គីមីពោល គឺដាំដោយបែបបទធម្មជាតិនោះ គឺមានតែបន្លែផ្លែឈើ បួន ដប់ ប្រភេទតែប៉ុណ្ណោះ ដោយនៅក្នុងនោះ គ្រាន់តែសាឡាត់គឺមាន បួនប្រាំមុខបាត់ ក្រៅពីនោះមានត្រឹមត្រសក់ ល្ពៅ ចេក ជី ត្រកួន ខាត់ណាជាដើម។ ប៉ុន្តែបើយើងចង់ដូចជា ផ្កាខាត់ណា ស្ពៃក្តោបអី គឺមានតែទៅរកនៅផ្សារដែលភាគច្រើននាំចូល ។

លោកស្រីបានបញ្ជាក់ថា " ជួនកាលអាមានតិចមុខហើយនោះ ទិញមិនទាន់គេទៀត ដូច្នេះរឿងអីយើងមិនទៅផ្សារ"។

លោកស្រីបានបញ្ជាក់ទាំងញញឹមថា "បើលោកប្តីគាត់ចង់ ឡូកឡាក់សាច់គោទៅហើយ ហើយអាផ្សារ កសិកម្មសរីរាង្គវាអត់មានអាសាឡាត់ និងប៉េងប៉ោះធម្មជាតិ ចឹងគេចមិនរួចពីផ្សារទេ"។

លោក សាញ់ សម្បត្តិ ដែលជាប្រជាពលរដ្ឋមួយរូបផ្សេងទៀតបានបន្តទៀតថា រឿងហូបចុកនេះសំខាន់ណាស់ ហើយគួរតែប្រយ័ត្ន ដោយខ្លួនឯង។

លោកបានបន្តទៀតថា ឥឡូវនេះសូម្បីតែហាងដែលដាក់លក់បន្លែដែលអះអាងថា ធម្មជាតិជួនកាល ក៏មិនមែនធម្មជាតិដែរ ដោយសារតែលោកធ្លាប់ឃើញបុគ្គលិកនៅក្នុងហាងមួយចំនួន គឺនៅពេលដែលអស់បន្លែអត់មានអីលក់ គេចេញទៅទិញពីផ្សារមកវិចខ្ចប់ នៅក្នុងប្រអប់បន្លែមានសុវត្ថិភាពហើយដាក់លក់។

លោកបានបន្តទៀតថា " ខ្ញុំឧស្សាហ៍ទាន់ណាស់ ជាពិសេសគឺនៅរដូវប្រាំងពិបាកទឹក តែអត់ បុគ្គលិកឃួរថង់ទៅទិញហើយ"។

លោកស្រី ចេត កញ្ញនា ជាស្ត្រីមេផ្ទះមួយរូបដែលកំពុងតែកាន់កន្ត្រកចេញមកពីផ្សារបឹងកេងកង បានឲ្យដឹងថា សុវត្ថិភាពនៃការហូបចុកគឺសំខាន់ណាស់ ប៉ុន្តែវាពិតជាលំបាកណាស់ ហើយម្នាក់ៗគឺបានត្រឹមតែការព្រួយបារម្ភ ។

លោកស្រី បានបញ្ជាក់ថា "សព្វថ្ងៃនេះនរណាក៏បារម្ភដែររឿង បន្លែ ត្រី សាច់ គ្រឿងសមុទ្រដាក់សារធាតុគីមី ប៉ុន្តែវាមិនដឹងធ្វើម៉េច ដោយសារតែវាគ្មានជម្រើស"។

ជុំវិញការអះអាងខាងលើ ដែលថាមានការលបលួចទិញបន្លែពីផ្សារមកវិចខ្ចប់ដាក់លក់នៅហាងនេះ បុគ្គលិកផ្សារកសិកម្មធម្មជាតិសេដាកមួយកន្លែង បានអះអាងថា នេះមិនមែនជាករណីដែលកើតឡើង នៅក្នុងហាងរបស់សេដាកឡើយ។

បុគ្គលិកដែលសុំមិនបញ្ចេញអត្តសញ្ញាណបានអះអាងថា គ្មានរឿងបែបនេះកើតឡើងនៅតាមផ្សារ សេដាក ដោយសារតែផលិតផលទាំងនេះ គឺផលិតដោយបណ្តាញសហគមន៍ ដែលអង្គការបានប្រមូលទិញ ហើយបើសិនជាអស់ គឺយើងប្រាប់អតិថិជនថាអស់តែម្តង ។

កញ្ញាអះអាងថា វាអាចកើតមាននៅហាងទំនើបមួយចំនួន តែយើងសូមធានាថា រឿងនេះអត់កើតនៅ សេដាក់ទេ។

កញ្ញា បានអះអាងថា មានហាងដែលដាក់លក់ផលិតផលធម្មជាតិអត់មានគីមីនេះច្រើន ដោយរួមទាំងផ្សារទំនើប មីនីម៉ាតជាច្រើន។

ទាក់ទិននឹងការអះអាងអំពីការក្លែងបន្លំនេះ លោក សម្បត្តិ បានអះអាងថា មធ្យោបាយសំខាន់ គឺមានតែប្រយ័ត្នប្រយែង និងលាងបន្លែទាំងនោះឲ្យស្អាត។

លោកបានអះអាងថា ដូចជាគ្រួសាររបស់លោកគឺថា មុននឹងទទួលទានបន្លែ ឬ ផ្លែឈើទោះទិញនៅទីណាក៏ដោយក៏ត្រូវលាងទឹកដោយដាក់អំបិលបន្តិច បើសិនជាមិនមានទឹកសម្រាប់លាងបន្លែដែលអាចទិញ ពីឱសថស្ថានបាន។

លោកបញ្ជាក់ថា "អំបិល មិត្តភ័ក្រខ្ញុំជាគ្រូពេទ្យបានប្រាប់ថា វាអាចជួយប្រតិកម្មលាងសំអាត ជាតិពុលបានតែមួយចំណែកខ្លះដែរ"។

រហូតមកដល់ពេលបច្ចុប្បន្ននេះ នៅក្នុងមួយថ្ងៃប្រជាពលរដ្ឋកម្ពុជា ត្រូវការបន្លែ ប្រមាណជា ៤០០ទៅ ៥០០ តោន ប៉ុន្តែដោយសារតែ បញ្ហាហេដ្ឋារចនាសម្ព័ន្ធដែលទ្រទ្រង់កសិកម្មមិនទូលំទូលាយ ជាពិសេសគឺ ប្រព័ន្ធធារាសាស្ត្រ ផលិតផលដែលមាននៅលើទីផ្សារភាគច្រើន គឺនាំចូលពីប្រទេសជិតខាង ដែលគេដឹងថាខ្លាំងជាងគេគឺវៀតណាម ។

ផលិតផលដែលកសិករកម្ពុជាអាចដាំនិងលទ្ធភាពផ្គត់ផ្គង់នៅលើទីផ្សារ គឺនៅរដូវដែលមានទឹកគ្រប់គ្រាន់ គឺអាចនឹងឈានដល់ ៥០ ភាគរយ ដែរ ដោយនៅក្នុងនោះ បន្លែធម្មជាតិ អត់ប្រើប្រាស់គីមីសូម្បីតែជីគីមី គឺមានចំណែកត្រឹមតែប្រមាណជា ៥ ភាគរយ ប៉ុណ្ណោះ ។

*ដោយ អរិយបុត្រ*



ថតដោយៈ រិទ្ធី

# យុវសិស្សខ្មែរមិនចូលចិត្តមុខវិជ្ជាវិទ្យាសាស្ត្រសង្គម



យុវតីនិងយុវជនដែលគ្រោងនឹងចូលរួមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនៅថ្ងៃទី ២២ សីហា ២០១៦ ខាងមុខនេះ ភាគច្រើន គឺមិនចូលចិត្តមុខវិជ្ជាវិទ្យាសាស្ត្រសង្គមឡើយ ដោយពួកគេអះអាងថា ពួកគេពិបាកទន្ទេញមេរៀន។

យុវតី ប៊ូ សុវឌី ជាបេក្ខជនមួយរូបដែលកំពុងតែត្រៀមប្រឡងសញ្ញាបត្រទុតិយភូមិនៅពេលខាងមុខនេះបានអះអាងថា នាង គឺជាបេក្ខជនម្នាក់ដែលជ្រើសរើសយកមុខវិជ្ជាវិទ្យាសាស្ត្រ។

ដោយទើបតែនឹងចេញពីសាលារៀនបំពេញវិជ្ជា មួយកន្លែងលើជំនាញវិទ្យាសាស្ត្រ នៅម្តុំសាលាវិទ្យាល័យ បាក់ទូក យុវតីរូបនោះ អះអាងថា នៅក្នុង ចំណោមមុខវិជ្ជាដែលត្រូវសិក្សាទាំងជាង ១០មុខ គឺដាច់ខាតនាង មិនជ្រើសរើសយកមុខវិជ្ជាវិទ្យាសាស្ត្រសង្គមទេ ដោយសារតែមុខវិជ្ជានេះ គឺត្រូវការទន្ទេញមេរៀន។

សុវឌី បានបញ្ជាក់ថា " អ៊ូយ មេរៀនច្រើនណាស់ គ្រាន់តែ ភូមិ ប្រវត្តិនោះ គឺយ៉ាប់ហើយ ចុះនៅទស្សនវិទ្យា និងមេរៀនផ្សេងៗទៀតនោះ"។

នាងបានបន្តឲ្យដឹងទៀតថា នៅក្នុងចំណោមមិត្តភក្តិដែលរៀននៅក្នុងថ្នាក់ និងសាលានៅពេលសួរទៅ គឺគ្មានអ្នកណាជ្រើសរើសយកមុខវិជ្ជាវិទ្យាសាស្ត្រសង្គមនោះឡើយ។

សុវឌី បានបញ្ជាក់ថា "មិត្តភក្តិទាំងអស់ពេលសួរទៅថា យកមុខវិជ្ជាអី១០ ទាំង១០ គឺយកវិទ្យាសាស្ត្រ ដោយសារអត់ត្រូវការទន្ទេញមេរៀន តែបើសួរ ២០អី គ្រាន់អាចបានមួយម្នាក់"។

ការអះអាងរបស់យុវតី ប៊ូ សុវឌី គឺមិនខុសពីការលើកឡើងពីយុវជន និងយុវតីដែលជាបេក្ខជនផ្សេងៗទៀតភាគច្រើន ដែលអ្នកនាំសារបានជួបសំភាសន៍នោះឡើយ។ ម្នាក់ៗ សុទ្ធតែមិនចាប់អារម្មណ៍និងវិទ្យាសាស្ត្រសង្គម។

យុវជន សេក ចម្រុង ដែលជាបេក្ខជនមួយរូបកំពុងតែត្រៀមប្រឡង សញ្ញាបត្រទុតិយភូមិ មួយរូប បានអះអាងថា ខ្លួនក៏ជាអ្នកដែលជ្រើសរើសយកវិទ្យាសាស្ត្រដែរដោយអះអាងថា ស្រួលគ្រាន់តែទន្ទេញរូបមន្ត និងស្គាល់ អំពីវិធីសាស្ត្រ ក៏ដូចជាគន្លឹះនៅក្នុងការដោះស្រាយលំហាត់ គឺចប់ តែបើមុខវិជ្ជាវិទ្យាសាស្ត្រសង្គមវិញ គឺ ត្រូវយល់ហើយ ចាំទៀត ពោលគឺត្រូវទន្ទេញដូចសេកតែម្តង។

ចម្រុងអះអាងថា គ្រាន់តែរូបមន្តល្មម គឺយើងពិបាកចាំទៅហើយ ចុះទម្រាំដល់មេរៀន ទាំងសៀវភៅ គឺមិនចាំទេ។

ចម្រុងបានបញ្ជាក់ថា "គណិតវិទ្យាអី គឺគ្រាន់តែយើងចាំ រូបមន្តខ្លីៗ ចាំអំពីវិធីត្រូវដោះស្រាយគឺបាន ខណៈរូបវិទ្យាអី គឺចាំបាតុភូត ហើយគីមី គឺចាំ រូបមន្តវាឡ៉ង់ វាគឺបានហើយ"។

យុវជនមួយរូប ដែលអង្គុយផឹកទឹកអំពៅ នៅក្បែរសាលាបាក់ទូក បាននិយាយយ៉ាងរំភើយថា សម្រាប់ មុខជំនាញវិទ្យាសាស្ត្រ ពេលដែលប្រឡងចេះឬ មិនចេះ អាចងាយស្រួល សុំគេមើលខ្លះ តែបើមុខវិជ្ជាវិទ្យាសាស្ត្រសង្គម គឺយ៉ាប់ពីព្រោះវាវែងពិបាកមើល ។

យុវជនម្នាក់ដែលអះអាង ខ្លួនឈ្មោះ ទីបូលីន បានឲ្យដឹងថា ប្រសិនបើពេលប្រឡងមានការបែកធ្លាយវិញ្ញាសារ អាចយកឯកសារចូលដូចពីមុន គឺប្រហែលអាចមានការចាប់អារម្មណ៍ច្រើនលើការជ្រើសរើសមុខ ជំនាញវិទ្យាសាស្ត្រសង្គម។

ទីបូលីន បានឲ្យដឹងថា "ខ្ញុំទោះបីជាមិនពូកែដូចគេ ប៉ុន្តែចេះតែខំជ្រើសរើសមុខជំនាញ វិទ្យាសាស្ត្រនឹងគេដែរហើយ ក្រែងលោចេញប៉ះអាយើងចេះខ្លះគ្រាន់បានសរសេរយកពិន្ទុ ប៉ុន្តែបើឲ្យយកវិទ្យាសាស្ត្រសង្គម គឺមានតែក្រដាសសរឬកត់វិញ្ញាសារចូលតែ ប៉ុណ្ណោះ"។

កញ្ញា សុវឌី បានអះអាងថា នៅក្នុងចំណោម មុខវិជ្ជាដែលរៀនទាំងអស់ ជាង ១០ មុខវិជ្ជា គឺយុវសិស្សម្នាក់ៗប្រឡងតែ ៧មុខជំនាញប៉ុណ្ណោះ ដោយវិទ្យាសាស្ត្រសង្គមមាន ៧មុខវិជ្ជា មុខជំនាញវិទ្យាសាស្ត្រ គឺមាន ៧ ដែរ ។

យុវតីបានរៀបរាប់បន្តថា ៧ មុខនេះគឺយកមុខវិជ្ជាដែលមានលំហាត់ទាំងអស់ បូក និងភាសាអង់គ្លេស និងវិទ្យាសាស្ត្រសង្គមមួយមុខ ដែលគេចាប់ឆ្នោតបាន ប៉ុន្តែមេគុណ គឺឲ្យតម្លៃទៅលើវិទ្យាសាស្ត្រពិតខ្ពស់។

យុវជន ទេព ដារាឫទ្ធិ ជានិស្សិតដែលកំពុងតែ រៀននៅមហាវិទ្យាល័យផ្នែកអង់គ្លេសមួយរូប បានអះអាងថា តាំងពីសម័យប្រឡងរបស់លោក កាលពីឆ្នាំ ២០១៥ មកដល់ពេលនេះ មិនសូវមានអ្នកដែលរៀនជំនាញវិទ្យាសាស្ត្រសង្គមទេ ហើយសាលារៀនមួយចំនួន គឺគ្មានសិស្ស ជ្រើសរើសជំនាញវិទ្យាសាស្ត្រសង្គមឡើយ ។

លោកបញ្ជាក់ថា "រៀនវិទ្យាសាស្ត្រសង្គម គ្មាននរណាចង់ទេ ដោយសារតែអក្សរវាច្រើនពេក "។

យោងទៅតាមសេចក្តីប្រកាសរបស់ក្រសួងអប់រំយុវជននិងកីឡា បានឲ្យដឹងថា នៅក្នុងចំណោម មណ្ឌលប្រឡងនានានៅទូទាំងប្រទេសនាថ្ងៃទី២២ ខែសីហា ខាងមុខមណ្ឌលប្រឡងរបស់សិស្ស ដែលចាប់យកជំនាញវិទ្យាសាស្ត្រសង្គម គឺមានតិចមែនទែន ។

ប្រភពដដែលបានបន្តឲ្យដឹងថា ជាក់ស្តែងនៅក្នុងទីក្រុងភ្នំពេញ ដែលមានមណ្ឌលប្រឡងទាំងអស់ ២៣មណ្ឌល គិតជាបន្ទប់មាន ៧១០បន្ទប់ មណ្ឌលប្រឡងចំពោះសិស្សវិទ្យាសាស្ត្រសង្គម គឺមានតែ ៣មណ្ឌល និង៩៧បន្ទប់ប៉ុណ្ណោះ ក្រៅពីនោះ គឺមណ្ឌលប្រឡងសម្រាប់សិស្សជ្រើសរើសមុខវិជ្ជា វិទ្យាសាស្ត្រទាំងអស់។

ប្រភពដដែលបានឲ្យដឹងថា នៅតាមបណ្តាខេត្តវិញ ក៏មានស្ថានភាពដូចគ្នាដែរ គឺជាទូទៅមណ្ឌលប្រឡង សម្រាប់សិស្សដែលជ្រើសរើសជំនាញវិទ្យាសាស្ត្រពិត គឺមានច្រើនជាង វិទ្យាសាស្ត្រសង្គម។ ជាក់ស្តែងដូចជានៅខេត្ត កណ្តាលវិញ ដែលមានមណ្ឌលប្រឡងសរុប ១៣ មណ្ឌលមាន ២៥៤បន្ទប់ មណ្ឌលប្រឡងសម្រាប់សិស្សជ្រើសរើសមុខវិជ្ជាវិទ្យាសាស្ត្រ គឺមានរហូតដល់ទៅ១១ មណ្ឌល ស្មើនឹង ២៥៤ បន្ទប់ ដោយឡែក មណ្ឌលសិស្សប្រឡងជំនាញវិទ្យាសាស្ត្រសង្គមវិញ នោះ គឺមាន ត្រឹមតែ ២ មណ្ឌល ប៉ុណ្ណោះ ដោយ ស្មើនឹង ៤៣ បន្ទប់ ។

*ដោយ អារិយបុត្រ*

# វិទ្យាស្ថានសន្តប៉ូល យកចិត្តទុកដាក់ ចំពោះបរិស្ថាន



ថតដោយ: សុវណ្ណា

សិក្ខាកាមជានិស្សិត សាស្ត្រាចារ្យបុគ្គលិកសិក្សា អង្គការក្រៅរដ្ឋាភិបាល និងនាយកវិទ្យាល័យចំនួនប្រមាណជា ១៧០ នាក់បាន ចូលរួមយ៉ាងសកម្មក្នុងអង្គ សិក្ខាសាលាស្រាវជ្រាវស្តីអំពី ៖ "ការរួមគ្នាជាគ្រួសារតែមួយដើម្បីយកចិត្តទុកដាក់ថែរក្សាបរិស្ថានក្នុងបរិបថអាស៊ាន" ។ សិក្ខាសាលានេះបានរៀបចំដោយវិទ្យាស្ថានសន្តប៉ូល កាលពីថ្ងៃទី១១-១៣ ខែកក្កដា ឆ្នាំ២០១៦ ដែលសម្របសម្រួល ដោយលោកអភិបាលអូលីវីយេ ឆ្មីតហាស្លែរ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ និងជានាយកវិទ្យាស្ថានសន្តប៉ូល។

វិទ្យាស្ថានសន្តប៉ូលជាគ្រឹះស្ថានអប់រំថ្នាក់ឧត្តមសិក្សាតែមួយគត់នៃព្រះសហគមន៍កាតូលិកនៅកម្ពុជា។ វិទ្យាស្ថានធ្វើកិច្ចសហប្រតិបត្តិការយ៉ាងល្អ ជាមួយស្ថាប័នអប់រំផ្សេងៗទៀតទាំងក្នុង និងក្រៅប្រទេស។ សិក្ខាសាលាស្រាវជ្រាវវិទ្យាស្ថានសន្តប៉ូលបានរៀបចំចំនួនពីរលើករួចមកហើយ នេះជាលើកទីបី ដែលទទួលបានការគាំទ្រពីបឹហ្គាមូនៅប្រទេសអ៊ីតាលី និងអង្គការការីតាសកម្ពុជា។ ក្នុងអង្គសិក្ខាសាលានេះ មានវាគ្មិនមកពីក្រសួងបរិស្ថាន អង្គការការីតាស ថ្នាក់ដឹកនាំសាសនាគ្រីស្ត និងពុទ្ធសាសនា ព្រមទាំងសាស្ត្រាចារ្យស្តេហ្វាញ៉ា ( Stefania ) នៃសកលវិទ្យាល័យបឹហ្គាមូ ។

រយៈពេលបីថ្ងៃនេះសិក្ខាកាមទាំងអស់បានសិក្សាឈ្វេងយល់ប្រធានបទជាច្រើនទាក់ទងនឹងស្ថានភាពបរិស្ថានក្នុងបរិបទអាស៊ាន តាមលក្ខណៈបច្ចេកទេសព័ត៌មានទស្សនសាសនាក្នុងការការពារបរិស្ថាន និងអនុសញ្ញាអន្តរជាតិមួយចំនួនស្តីអំពីការការពារថែរក្សាបរិស្ថាន មានអនុសញ្ញា COP21 ជាដើម។ ក្នុងនោះក៏បានស្វែងយល់អំពីសកម្មភាពរបស់ប្រទេសកម្ពុជាដោយផ្អែកលើស្មារតីនៃកិច្ចប្រជុំកំពូលថ្នាក់ដឹកនាំពិភពលោក នៅប៉ារីស COP 21។

ចំពោះទស្សនតាមគ្រីស្តសាសនាដែលលោកបូជាចារ្យ កាព្រីអែល ជាវាគ្មិនបានលើកសារលិខិតរបស់សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ "LAUDATO SI " មកបង្ហាញ។ លោកបានបង្ហាញយ៉ាងច្បាស់អំពីបរិស្ថានទាំងមូល ៖ បរិស្ថានធម្មជាតិ បរិស្ថានសេដ្ឋកិច្ច បរិស្ថានសង្គម បរិស្ថានវប្បធម៌ បរិស្ថានការរស់នៅប្រចាំថ្ងៃ បរិស្ថានផលប្រយោជន៍រួម បរិស្ថានយុត្តិធម៌តំណរមនុស្ស។

ថ្ងៃបញ្ចប់ សិក្ខតាមទាំងអស់ បានរៀបចំផែនការ អនុវត្តន៍បន្ត អំពីអ្វីដែលគេបានរៀនក្នុងរយៈពេលបីថ្ងៃនេះដោយលើកជាគម្រោងផែនការមួយមានឈ្មោះថា "វិទ្យាស្ថានសន្តប៉ូល បៃតង - Green Saint Paul Institute "។ សិក្ខាកាមបានកំណត់ ទស្សវិស័យ គុណតម្លៃ និងផែនការសកម្មភាព សម្រាប់បុគ្គលផ្ទាល់ និងគ្រួសារសហគមន៍ និងក្នុងវិទ្យាស្ថានសន្តប៉ូល។

ជំហានដំបូងនៃផែនការនេះ វិទ្យាស្ថានសន្តប៉ូលបានជ្រើសរើសនិស្សិតគ្រប់ផ្នែកចងជាគណៈកម្មការអនវត្តន៍ជាក់ស្តែងមានឈ្មោះថា គណៈកម្មការបៃតង។

អង្គសិក្ខាសាលាបានបិទបញ្ចប់ដោយសិក្ខាកាមទាំងអស់រួមគ្នាដាំដើមឈើ ដែលជាសញ្ញាបង្ហាញថា ជាគ្រួសារតែមួយ និងស្របតាមទស្សនវិស័យនៃអង្គសិក្ខាសាលានេះ។

មានប្រសាសន៍បិទ សិក្ខាសាលាលោកអូលីវីយេ ឆ្មីតហាស្លែរ បានមានប្រសាសន៍ថា ៖ វិទ្យាស្ថានសន្តប៉ូលមានមោទនភាពដែលបានរៀបចំសិក្ខាសាលារយៈពេល៣ ថ្ងៃក្នុងការស្រាវជ្រាវ អំពីបរិស្ថាន និងជាពិសេស គឺបានបង្ហាញថា មនុស្សយើងជាគ្រួសារតែមួយត្រូវតែការពារ និងថែរក្សាបរិស្ថាន។

លោកបន្តថា បរិស្ថាន គឺមានភាពទូលំទូលាយមិនមែនត្រឹមតែធម្មជាតិទេ គឺមានទាំងបរិស្ថានធម្មជាតិ បរិស្ថានសង្គម បរិស្ថានវប្បធម៌ បរិស្ថានទំនាក់ទំនងជាមួយអ្នកជុំវិញ និងបរិស្ថានខាងផ្លូវវិញ្ញាណ។

លោកអូលីវីយេ បន្ថែមថា នេះជាឱកាសមួយក្នុងអប់រំនិស្សិតនៅវិទ្យាស្ថានសន្តប៉ូល ដើម្បីឲ្យពួកគេភ្ញាក់ស្មារតី ចេះទទួលខុសត្រូវដោយចេះកសាងសង្គមជាតិទាំងផ្នែកបរិស្ថាន ផ្នែកអេកូឡូហ្ស៊ី Ecology ដែលណែនាំឲ្យមានគំនិតទូលំទូលាយក្នុងការអភិវឌ្ឍប្រទេសរបស់យើង។ ហើយម្យ៉ាងទៀតក៏ជាឱកាសមួយដើម្បីឲ្យវិទ្យាស្ថានសន្តប៉ូលអាចទទួលតួនាទីមួយយ៉ាងពិសេសក្នុងការអប់រំ ថែរក្សា និងណែនាំទាំងនិស្សិត ទាំងប្រជាជនក្នុងសហគមន៍ឲ្យយកចិត្តទុកដាក់ក្នុងការថែរក្សាបរិស្ថានពួកគេ។ លោកអភិបាលថា នេះជាហេតុដែលចង់ឲ្យវិទ្យាស្ថាននេះជាវិទ្យាស្ថានបៃតង គឺមានន័យថាជាវិទ្យាស្ថានគំរូដើម្បីយកចិត្តទុកដាក់ចំពោះ បរិស្ថានដែលមានទាំងធម្មជាតិ សង្គមវប្បធម៌ និងសេដ្ឋកិច្ចប្រចាំថ្ងៃផងដែរ។

ក្នុងលោកក៏ជំរុញឲ្យនិស្សិត និងសិក្ខាមទាំងអស់យកចិត្តទុកដាក់បរិស្ថានសង្គមយកចិត្តទុកដាក់អ្នកដែលគេបោះបង់ចោល អ្នកទន់ខ្សោយ ជនពិការ អ្នកជំងឺជនខ្សោយសតិបញ្ញា និងជនទាំងឡាយដែលងាយរងគ្រោះផងដែរ។

សាស្ត្រាចារ្យ Stefania ជាវាទគ្មិន និងជាអ្នកឧបត្ថមកម្មវិធី បានមានប្រសាសន៍ផ្តាំផ្ញើរថា សិក្ខាសាលានេះបានត្រឹមតែ៣ថ្ងៃមែន តែត្រូវបន្តនៅក្នុងជីវិតប្រចាំថ្ងៃនៅក្នុងសហគមន៍ និងនៅសាលារៀនដើម្បីអនុវត្តសេចក្តីស្រឡាញ់ ការពារ និងថែរក្សាបរិស្ថាន នៅក្នុងជីវិតជាក់ស្តែង។ អ្នកស្រីបន្តថា ថ្ងៃបន្ទាប់នៃសិក្ខាសាលានេះ ខ្ញុំ នឹងទៅជួបជាមួយឯកឧត្តមនៃក្រសួងអប់រំ ហើយនឹងពាំនាំនូវគំនិតដែលបានមកពីសិក្ខាសាលានេះទៅដល់ឯកឧត្តមដើម្បីស្នើរសុំឲ្យមានការដាក់បញ្ចូលក្នុងក្រសួងអប់រំផងដែរ។

សិក្ខាកាម កែវ ថនអង្គារស្មី ជានិស្សិតឆ្នាំទី៣ ផ្នែកសង្គមកិច្ច បានឲ្យដឹងថា សិក្ខាសាលាទាំង៣ថ្ងៃនេះ បានផ្តល់នូវចំណេះដឹងជាច្រើនខាងផ្នែកបរិស្ថាន ដោយយល់ពីអត្ថប្រយោជន៍ និងរបៀបនៃការកាត់បន្ថយនៃការឡើងកំដៅលើផែនដី។ កញ្ញាបន្តថា នឹងយកទៅផ្សព្វផ្សាយបន្តដល់មនុស្សនៅជុំវិញ និងនៅសាលាឲ្យយល់អំពីឥទ្ធិពល និងផលប៉ះពាល់ដែលបណ្តាលមកពីបញ្ហាបរិស្ថានទាំងនេះ។

វិទ្យាស្ថានសន្តប៉ូល ស្ថិតនៅកណ្តាលវាលស្រែ ក្នុងភូមិអង្គគី ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ។ វិទ្យាស្ថាននេះមានថ្នាក់បរិញ្ញាបត្រ ចំនួន ៥មហាវិទ្យាល័យដូចជា ព័ត៌មានវិទ្យា អក្សរសាស្ត្រអង់គ្លេសទេសចរណ៍ ក្សេត្រសាស្ត្រ( កសិកម្ម ) និងមហាវិទ្យាល័យសង្គមកិច្ច។ ក្នុងនោះក៏មានថ្នាក់បរិញ្ញាបត្ររង ព័ត៌មានវិទ្យាអង់គ្លេសសណ្ឋាគារនិងបដិសណ្ឋារកិច្ចផលិតកម្មដំណាំឈើហូបផ្លែ និងបន្លែជំនាញកែច្នៃចំណីអាហារ ប្រព័ន្ធកសិកម្មចំរុះ និងជំនាញវេជ្ជសាស្ត្រសត្វ។

*ដោយ : ដាលីស*

# ក្រុមរាំងសង់ឌីប៉ូល នៃព្រះសហគមន៍ភូមិភាគកំពង់ចាម ធ្វើដំណើរទស្សនៈកិច្ចនៅវៀតណាម

សមាគមន៍សមាជិក្រុមរាំងសង់ឌីប៉ូល នៃព្រះសហគមន៍ភូមិភាគកំពង់ចាមចំនួន ២៣នាក់ បានធ្វើដំណើរទស្សនៈកិច្ចទៅប្រទេសវៀតណាម រយៈពេល៥ថ្ងៃ ចាប់ពីថ្ងៃទី១៨-២១ ខែសីហាកន្លងទៅ។

លោកផាន់ ប៉ូរ៉ា ជាប្រធានសមាគមន៍ក្រុងរាំងសង់ឌីប៉ូល ប្រចាំប្រទេសកម្ពុជា បានឲ្យដឹងថា៖ ដំណើរទស្សនៈកិច្ចនេះបានវាជាកម្មវិធីដែលមានជាប្រចាំឆ្នាំ ក្រុមបានជ្រើសរើសទៅប្រទេសវៀតណាម ព្រោះចង់សិក្សាស្វែងយល់អំពីការរីកចម្រើនខាងផ្នែកជំនឿ។ នេះជាការផ្លាស់ប្តូរបទពិសោធន៏ និងចំណះដឹងរវាងការអនុវត្តជំនឿកាតូលិក នៅប្រទេសជិតខាងដើម្បីយកមកអភិវឌ្ឍន៏នូវចំណុចខ្វះខាងខាងផ្នែកជំនឿរបស់ខ្លួន។



រូបថតពី ហ្វេសបុក

លោកបន្តទៀតថា ៖ សមាជីកទាំងអស់បានមើលពីសកម្មភាពរស់នៅរបស់គ្រីស្តបរិស័ទកាតូលិកវៀតណាម មើលពីការរៀនអប់រំជំនឿរបស់ក្មេងៗ និងបានផ្លាស់ប្តូរបទពិសោធន៍ជាមួយពួកគេថែមទៀត។ លោកប៉ូរ៉ាបាននិយាយពីលក្ខណៈខុសប្លែកគ្នារវាងព្រហៈសគមន៍កាតូលិកនៅកម្ពុជា និងនៅវៀតណាម គឺព្រះសហ-គមន៍ស្រុកខ្មែរ គឺពឹងជំនួយពីបរទេសត ចំណែកព្រះសហគមន៍នៅវៀតណាមវិញ គឺពឹងផ្អែកទៅលើតែគ្រីស្តបរិស័ទនៅក្នុងស្រុកតែប៉ុណ្ណោះ។

គ្រប់ព្រះវិហារ និងព្រះសហគមន៍នៅទីនោះកកើតឡើង គឺដោយសារតែមានកំលាំងជួយឧបត្ថមពីគ្រីស្តបរិស័ទនៅក្នុងស្រុករបស់ខ្លួន។ និយាយរួម គឺគ្រីស្ត-បរិស័ទនៅទីនោះ គឺគេមានសាមគ្គីគ្នាក្នុងការជួយទៅវិញទៅមកដោយមិនត្រូវការជំនួយឧបត្ថមពីស្រុកក្រៅឡើយ។

លោកផាន ប៉ូរ៉ាក៏បាននិយាយដោយភាពរីករាយថា នេះជាលើកទីមួយហើយសម្រាប់ដំណើរទស្សនៈកិច្ចនេះហើយ ចំនុចដែលលោកចាប់អារម្មណ៍បំផុតនោះ គឺជាទឹកចិត្តស្វាគមន៍ដ៏សែនកក់ក្តៅពីកន្លែងមួយទៅកន្លែងមួយមានទឹកមុខញញឹមជានិច្ច។ លើសពីនេះទៅទៀតពួកគេក៏បានចំណាយថវិកាផ្ទាល់ខ្លួន និងពេលវេលា សម្រាប់ការស្វាគមន៍នេះ។ ទាំងអស់នេះបានធ្វើឲ្យគ្រីស្តបរិស័ទអ្នករួមដំណើរទាំងអស់មានសេចក្តីរំភើបយ៉ាងខ្លាំង និងមានទំនុកចិត្តក្នុងការស្នាក់នៅទីនោះផងដែរ។

ទទឹមនឹងការធ្វើដំណើរទស្សនៈកិច្ចនេះ លោកផានប៉ូរ៉ា ដដែលលោកបានចែករំលែកបន្ថែមទៀតថា៖ក្នុងពេលជាមួយគ្នានោះក្រុមសមាជិករបស់ពួកគាត់ក៏បានយកប្រធានបទមួយដែលទាក់ទងនឹងសន្តម៉ាថាយ មករិះគិតក្នុងពេលធ្វើដំណើរទស្សនកិច្ច ប៉ុន្មានថ្ងៃនេះ។

តាមយោបល់ផ្ទាល់របស់លោកប៉ូរ៉ា បានឲ្យដឹងទៀតថា រយៈពេលត្រឹមតែ៤ថ្ងៃដែលលោកបាននៅទីនោះលោកបាន យល់ឃើញថា គ្រីស្តបរិស័ទជនជាតិវៀតណាមគឺមានជំនឿរឹងមាំពិតប្រាកដ។ គេមានចំនុចខ្លាំង គឺចេះចែករំលែកនិងចេះជួយគ្នាទៅវិញទៅមកហើយមានការជ្រុមជ្រែងយ៉ាងខ្លាំងពីគ្រីស្តបរិស័ទចំពោះព្រះសហគមន៍។ តែលោកក៏បាននិយាយថា គ្រីស្តបរិស័ទយើងក៏មានចំនុចខ្លាំងផងដែរ។ សម្រាប់ដំណើរទស្សនៈកិច្ចទៅក្រៅប្រទេសសម្រាប់ក្រុមរាំងសង់នៅប៉ូលនេះលោកកំពុងសម្លឹងមើលពេលវេលាសម្រាប់ភូមិភាគផ្សេងទៀតដូចជា ខាងបាត់ដំបង និងភ្នំពេញ។ *កញ្ញា ហុកស៊ីវ*

# បោះជំរំកុមារនៅព្រះសហគមន៏កាតូលិកកោះការ



រូបថតពី ហ្វេសបុក

ព្រះវិហារសន្តហ្វ្រង់ស្វ័រនិងសន្តីក្លារា អាស៊ីស៊ី (កោះរការ) បានធ្វើកម្មវិធីបោះជំរុំកុមារ កាលពីថ្ងៃទី២៤ កក្កដាកន្លងទៅដោយមានកុមារចូលរួមប្រមាណជា១៥០នាក់។

លោកផានបូរីជាបូជាចារ្យជំនួយការនៅព្រះសហគមន៍កោះរការបានឲ្យដឹងថា ៖ កម្មវិធីនេះត្រូវបានរៀបចំឡើងដោយក្រុមយុវជនយុវនារី និងគ្រូអប់រំជំនឿមួយចំនួន ដើម្បីជួយកុមារក្នុងពេលវិសមកាលពីការសិក្សា។

លោកបន្តទៀតថា កុមារទាំងនោះនៅក្មេង មិនទាន់អាចជួយសម្រួលកិច្ចការឪពុកម្តាយបានទេ ពេលទំនេ គឺមិនមានអ្វីក្រៅពីការដើរលេងនោះទេ។

លោកបន្តថា ៖ កម្មវិធីបោះជំរុំកុមារនេះ គឺសម្រាប់កុមារទាំងអស់ មិនថាកូនគ្រីស្តបរិស័ទ ឬពុទ្ធបរិស័ទនោះទេ គឺក្នុងបំណងផ្តល់ការអប់រំណែនាំដល់កុមារ។

លោកផាន បូរីបានបន្ថែមទៀតថា ៖ កុមារសប្បាយចិត្តក្នុងការចូលរួមកម្មវិធីនេះ(បោះជំរុំ) ព្រោះមានទាំងការលេងល្បែងកម្សាន្ត មានទាំងការអប់រំអំពីការរស់នៅប្រចាំថ្ងៃ និងការអប់រំតាមរបៀបគ្រីស្តសាសនា។

អ្វីដែលពិសេសនោះ គឺយើងផ្តល់ឱកាសឲ្យក្មេងៗបានស្គាល់គ្នា ទៅវិញទៅមក ចេះសាម្មីគ្នា ចេះស្តាប់ និងរិះគិតបញ្ចេញយោបល់ផ្សេងៗផងដែរ។

នៅក្នុងឱកាសនៃការជួបជុំរបស់កុមារផងដែរនោះ អ្នករៀបចំក៏បានជ្រើសរើសប្រធានបទមួយរបស់សន្តប៉ូលដែលបាននិយាយ អំពីកុមារមករិះគិតរួមគ្នា។

ក្នុងនោះក៏មានការស្តាប់ និងរិះគិតអំពីព្រះបន្ទូលផងដែរ។ ហើយអ្វីដែលពិសេសនោះ គឺបង្ហាញឲ្យកុមារស្គាល់អំពីដំណើរជីវិតខ្លះៗរបស់សន្តសន្តី តាមរយៈការទស្សនាវីឌីអូ។

លោកបូជាចារ្យរូបនោះបានបញ្ជាក់បន្ថែមថា ៖ ទោះបីជាមានកម្មវិធីច្រើនសម្រាប់កុមារទាំងនោះតែយើងមិនបានភ្លេចនូវគោលជំហររបស់ខ្លួន គឺចង់ឲ្យកុមារដែលកំពុងរៀនអប់រំជំនឿយល់កាន់តែច្បាស់អំពីព្រះយេស៊ូ និងដំណើរជីវិតជាគ្រីស្តបរិស័ទ។

ជាពិសេសក្នុងឆ្នាំ គឺជាឆ្នាំព្រះមហាករុណាទិគុណ គឺចង់ឲ្យកុមារបានរស់នៅជាមួយព្រះយេស៊ូ តាមជំនឿ និងឲ្យគេដឹងថា ព្រះយេស៊ូមិនដែលទុកក្មេងនៅតែម្នាក់ឯងនោះទេ។

លោកបូជាចារ្យផាន បូរី ក៏សូមឲ្យព្រះសហគមន៍កាតូលិកនៅកម្ពុជាទាំងអស់យកចិត្តទុកដាក់ទៅលើកុមារ ព្រោះកុមារ គឺជាមរតកដ៏មានតម្លៃ និងជាក្តីសង្ឃឹមរបស់ព្រះសហគមន៍ ហើយកិច្ចការនេះដូចគ្នាទៅ និងព្រះបន្ទូលមួយឃ្លារបស់ព្រះយេស៊ូថា៖ "សូមឲ្យក្មេងៗមករកខ្ញុំ" ហើយសូមឲ្យយើងមានចិត្តដូចក្មេងៗទាំងនោះដែរ៕

*ដោយ ស្រីម៉ាច*

# វាចានារីរកស៊ីផ្លូវភេទ៖ "គ្មាននរណាចង់ប្រកបរបរនេះទេ ប្រសិនបើមានជម្រើស"




របររកស៊ីផ្លូវភេទត្រូវបានគេដឹងថា គឺជារបរមួយដែលមានចំណាស់យូរបំផុតនៅក្នុងប្រវត្តិមនុស្សជាតិ ប៉ុន្តែគ្រប់សម័យកាល គ្រប់ជំនាន់សូម្បីតែបច្ចុប្បន្ននេះ នៅតែមាន គឺដោយសារតែបញ្ហាជំចាក់ស្រេះជាច្រើន។

ស្រីមុំ ដែលជាឈ្មោះ អ្នកនាំសារសូមប្រសិទ្ធិនាជូន ខណៈពេលដែលបានសំភាសន៍នៅ កន្លែងដែលនាង តែងតែត្រាច់ចររកអតិថិជនមួយកន្លែងនៅក្នុងទីក្រុងភ្នំពេញថា នាងមិនមានបំណងចង់ប្រកបរបរនេះនោះទេ ប៉ុន្តែដោយសារតែគ្មានជម្រើស។

នៅក្នុងនាមជានារីដែលតែលតោលមួយរូប ស្រីមុំ បានបង្ខំចិត្តលក់ខ្លួននៅទីនោះ រយៈពេលប្រមាណជា ៤ ឆ្នាំមកហើយ ដោយសារតែកត្តាជីវភាព គ្មានចំណេះ ហើយមានគេមកបបួលនាង។

ជាមួយនឹងការតុបតែងមុខមាត់លាបម្សៅ លាបក្រែម បាញ់ទឹកអប់ក្លិនយ៉ាងក្រអូបក្រអួន ស្រីមុំបានអះអាងថា ក្នុងមួយថ្ងៃនាងទទួលបានភ្ញៀវប្រមាណជាពីពីរទៅបីនាក់តែប៉ុណ្ណោះ តែជួនកាលក៏គ្មានភ្ញៀវផងក៏មាន។

និយាយទាំងទឹកមុខអៀនព្រៀនផង ស្រីមុំ បានបញ្ជាក់ថា "ខ្ញុំមិនបានគិតអ្វីពីអារម្មណ៍របស់ភ្ញៀវ ហើយភ្ញៀវក៏មិនបានគិតពីអារម្មណ៍របស់ខ្ញុំដែរ សំខាន់ខ្ញុំ គឺជាអ្នកដែលលក់ខ្លួន"។

ស្រីមុំ បន្តទៀតថា នាងបានក្លាយខ្លួនជានារីរកស៊ីផ្លូវភេទនេះ ក្រោយពេលដែលការងាររោងចក្រកាត់ដេរមានបញ្ហា ថៅកែរត់ ហើយនៅពេលនោះ ម្ដាយឈឺត្រូវការវះកាត់ ក៏បានជួបនារីម្នាក់ដែលជាអ្នកស្គាល់គ្នាហើយក៏បានបបួលនាងទៅលក់ខ្លួនតែម្ដង ។

ស្រីមុំបានបន្តទៀតថា មកដល់ពេលនេះ គ្មាននរណាម្នាក់ដឹងថា នាងមករកស៊ីលក់ខ្លួនបែបនេះទេ សូម្បីតែមិត្តភក្តិដោយនាងគ្រាន់តែប្រាប់ថា នាងមានការងារជានារីបម្រើនៅតាមហាង។

ស្រីមុំ បានបន្តទៀតថា នៅក្នុងមួយថ្ងៃ នាងអាចរកចំណូលពីការលក់ខ្លួននេះប្រមាណជា ២០ទៅ ៣០ដុល្លារ ហើយពេលខ្លះ ក៏បានច្រើនជាងនេះ ពេលខ្លះក៏អត់ដោយសារតែមិនមានភ្ញៀវ ហើយពេលខ្លះទៅក៏បានស្រួលចិត្តពេលដែលប៉ះភ្ញៀវគាត់ចិត្តល្អ មិនធ្វើបាប តែពេលខ្លះក៏ប៉ះចំភ្ញៀវខ្លះ ត្រូវវាយធ្វើបាបខ្លះស្រវឹងក្អួតដាក់ក៏មានដែរ ប៉ុន្តែចេះតែទ្រាំទៅ វាប្រសើរជាងអង្គុយនៅរោងចក្រដេរបានមួយខែ ១០០ទៅ២០០ដុល្លារ។

ស្រីមុំបានបញ្ជាក់ថា "ជីវិតគឺឥចឹង! ចង់បានលុយគេវាមិនស្រួលទេ កាលនៅពេលធ្វើការនៅរោងចក្រអង្គុយមួយថ្ងៃៗ បួន ដប់ម៉ោងបានលុយតែ បួន ប្រាំ ដុល្លារ តែរបរនេះវាក៏មិនជាស្រួលដែរ ទោះបីជាវាធ្វើការតិចហើយបានលុយច្រើន ក៏ពិតមែន តែសង្គមមិនឲ្យតម្លៃ ហើយពេលខ្លះទៅ ក៏ត្រូវភ្ញៀវវាយធ្វើបាបក៏មានដែរ"។

ស្រីមុំបានបន្តទៀតថា "ថ្ងៃខ្លះ ខ្ញុំត្រូវភ្ញៀវគេបង្ខំរួមភេទហើយ អត់ឲ្យលុយក៏មាន ពេលខ្លះ គេណាត់តាមទូរស័ព្ទ ថានៅផ្ទះសំណាក់នេះ បន្ទប់នេះពេលទៅដល់គេថា អត់មានហៅក៏មាន ពេលខ្លះទៅត្រូវគេហៅទៅលេងសើចក៏មាន"។

មកដល់ពេលនេះ ស្រីមុំ ត្រូវបានចាត់ទុកថា គឺជានារី ដែលប្រកបរបរនេះថ្នាក់មធ្យមមួយរូប ខណៈដែលនៅពេលនេះមានអ្នកដែលប្រកបរបរនេះថ្នាក់ខ្ពស់ និងថ្នាក់ទាបជាច្រើនទៀត។ ស្រីមុំ មិនសូវដើររកម៉ូយទេ គឺច្រើនតែមានម៉ូយគេហៅ តាមទូរស័ព្ទ។

បុប្ផា ជានារីរកស៊ីផ្លូវភេទចល័តមួយរូប បាននិយាយប្រាប់អ្នកនាំសារ ទាំងទឹកមុខស្រពោន និងអួលដើមកថា "គ្មាននារីខ្មែរណាម្នាក់ចង់មកធ្វើបែបនេះនោះទេ"។

បុប្ផា អះអាងថា "ខ្ញុំក៏មានភាពខ្មាស់អៀន និងចង់រស់នៅជាមនុស្សថ្លៃថ្នូរក្នុងសង្គមដូចគេដូចឯងដែរ" តែដោយសារតែជីវភាពក្នុងគ្រួសារក្រីក្រពេក ហើយណាមួយខ្លួនគ្មានចំណេះដឹងផងនោះ ក៏មិនបាន មើលឃើញមុខរបរអ្វីដែលល្អជាងនេះ តែប្រសិនបើនាងមានការងារត្រឹមត្រូវហើយមានប្រាក់កាសសមល្មមជួយគ្រួសារ និងខ្លួនឯងបាននោះនាងក៏មិននៅស៊ូទ្រាំ និងកាងារនេះទៀតដែរ។

ដើរបណ្ដើរដៃផាត់មុខតុបតែងខ្លួនបណ្ដើរខណៈរង់ចាំភ្ញៀវនៅទីសាធារណៈមួយកន្លែង ដែលយើងសូមមិនប្រាប់ទីកន្លែង បុប្ផា បានអះអាងថា នាងបានប្រកបរបរនេះរយៈពេល២ឆ្នាំមកហើយ។

នារីរូបនេះនិយាយផងដៃមមារញឹកលាបក្រែមផងបានបន្តទៀតថា "វាជារឿងធម្មតាទេអូនអើយ!!! តែប្រុសៗមានចំណង់ គឺគាត់មករកខាងក្រៅហើយបើទោះបីគាត់មានប្រពន្ធក៏ដោយព្រោះថាការដែរគាត់មករកសេវាខាងក្រៅនេះ ទោះបីយ៉ាងណាក៏ជួយបន្ធូអារម្មណ៍ខាងផ្លូវភេទមួយពេលដែរ"។

បុប្ផា បានអះអាងថា ភ្ញៀវប្រភេទណាក៏នាងធ្លាប់ជួបដែរ ហើយបើនិយាយទៅម្នាក់បានលុយប៉ុន្មានវិញ គឺអស់ហើយបួនម៉ឺនរៀល ខ្លះទៅបីម៉ឺនរៀលក៏មាន តែហេងទៅ ជួនជាមួយភ្ញៀវបរទេសទៅក៏បាន ៣០ទៅ ៤០ដុល្លារ តាមកាអាណិតរបស់គេទៅ។

បុប្ផាបានបន្ថែថា និយាយទៅវាគ្មានការងារណាស្រួលទេ តែយើងចង់បានលុយគេ ទោះគេឲ្យយើងដេក ដើរ ឈរអង្គុយ ស្រេចតែចិត្តគេ ប៉ុន្តែដើម្បីបានលុយក៏ចេះតែធ្វើគោ ធ្វើសេះ ទៅជីវិតវាជ្រុលទៅជាឥចឹងទៅហើយនោះ ។

*ដោយ ស្រីម៉ាច*

# សម្រង់ការវិភាគចំៗបញ្ហាមុនពេល លោកបណ្ឌិត កែម ឡី មុនពេលអស់ជីវិត

បើសិនជាអ្នកទាំងអស់គ្នាជាប្រិយមិត្តដែលចូលចិត្តស្តាប់ព័ត៌មានអានអំពីបញ្ហានយោបាយ និងសង្គមប្រាកដជាបានស្គាល់លោកបណ្ឌិត កែម ឡី ជាអ្នកសាវជ្រាវការអភិវឌ្ឍន៍សង្គម ដែលអ្នកសារព័ត៌មានតែងតែដាក់មុនងារលោកថា ជាអ្នកវិភាគឯករាជ្យ ប៉ុន្តែចាប់ពីព្រឹកថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៦ តទៅទាំងអស់គ្នាលែងបានឮលែងបានអានទស្សនៈ និងយោបល់របស់លោកទៀតហើយ ។

លោក បណ្ឌិត កែម ឡី ត្រូវបានខ្មាន់កាំភ្លើងបាញ់សម្លាប់កាលពីវេលាព្រឹកថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៦ នៅឯស្តារម៉ាតក្នុងស្ថានីយលក់ប្រេងឥន្ធនៈកាល់តិចដែលគេដឹងថា គឺជាកន្លែងដែលលោក ទទួលការណាត់ជួបសំភាសន៍ជាមួយអ្នកសារព័ត៌មាន និងក្រុមការងាររបស់លោក។

លោកបណ្ឌិត កែម ឡី ត្រូវបានគេដឹងថា គឺជាបញ្ញវ័ន្តដែលហ៊ានថា ហ៊ាននិយាយ ហើយត្រូវបានពលរដ្ឋដែលនិយមស្តាប់ និងអានទស្សនៈរបស់លោកយល់ថា ជាអ្នកដែលហ៊ានអេះរមាស់អ្នកមានអំណាច អ្នកនយោបាយ និងហ៊ានកេះខ្នងពួកគេប្រាប់អំពីបញ្ហាអយុត្តិធម៌សង្គមផ្សេងៗ ដែលកើតមាននៅសង្គមកម្ពុជា។

## ទស្សនៈលោកបណ្ឌិត កែម ឡី ៖

នៅក្នុងអំឡុងពេលដែលលោកបាននៅរស់រានមានជីវិតសំដីពិតប្រាកដដែលលោកហ៊ាននិយាយ និងហ៊ានថា ហើយត្រូវបានពលរដ្ឋកំណត់ចំណាំជាងគេ គឺពាក្យមួយឃ្លាដែលថា "នៅពេលដែលខ្ញុំវិភាគម្តងៗ ខ្ញុំមិនដែលគិតថា ខ្លួនខ្ញុំមានជីវិតទេ ដោយសារនៅក្នុងប្រទេសគឺ មានខ្លា មានពស់វែក និងមានឆ្លាមកាន់តែច្រើន ប៉ុន្តែបើសិនជាយើងនាំគ្នាខ្លាច យើងគ្មានលទ្ធភាពផ្តល់គំរូដល់យុវជនទេ ហើយយើងក៏អត់មានលទ្ធភាពកែប្រែប្រទេសយើងដែរ"។

សំដីដែលលោកបណ្ឌិត កែម ឡី តែងតែនិយាយនៅពេលជួបជាមួយនឹងអ្នកសារព័ត៌មានគឺថា "មុនពេលធ្វើការវិភាគលើបញ្ហាអ្វីមួយ គឺដាច់ខាតត្រូវមានលិខិតឆ្លងដែនមួយមានទិដ្ឋាការ៣ ទីមួយគឺ បើសិនជាគេមិនសប្បាយចិត្ត គេឲ្យទៅមន្ទីរពេទ្យ ទីពីរ ទៅព្រៃសរ និងទីបី ទៅវត្តព្រះពុទ្ធ។ ទស្សនៈនិងយោបល់ដែលគួតែកត់សំគាល់មួយទៀតដែលលោកបាននិយាយគឺថា សង្គមកម្ពុជា គឺកំពុងតែញ៉ាំញីដោយជំងឺញៀននឹងអំណាច ។

លោកបណ្ឌិតធ្លាប់ប្រាប់អ្នកសារព័ត៌មានថា កម្ពុជាកំពុងតែញ៉ាំញី ដោយជំងឺសង្គម ៤ គឺ ញៀនអំណាច ជំងឺដោរ ជំងឺលោភលន់ និងជំងឺផ្លូវចិត្ត។

លោកបានធ្លាប់អះអាងថា ជំងឺញៀនអំណាច ជាជំងឺសង្គមមួយក្នុងចំណោមជំងឺសង្គមដែលកំពុងបន្តញ៉ាំញីសង្គមខ្មែរ ដែលត្រូវការការព្យាបាលជាបន្ទាន់ទើបអាចធ្វើឲ្យប្រទេសដែលស្ទើរតែរលុបឈ្មោះបាត់ពីផែនទីពិភពលោកមួយនេះ ស្គាល់នូវភាពរុងរឿង ដូចបណ្តាប្រទេសជឿនលឿន នៅលើពិភពលោកបាន។ លោកបានប្រាប់អ្នកសារព័ត៌មានថា "ជំងឺញៀនអំណាច រួមទាំងជំងឺដោរនេះ គឺម្នាក់ៗចង់ឲ្យគេសរសើរ ចង់ឲ្យគេគោរព ចង់ឲ្យគេគិតថា ខ្លួនឯងជាអ្នកធំ ខ្លួនឯងជានាម៉ឺន មន្ត្រីជាឯកឧត្តម ឧកញ៉ា សម្តេច ឧត្តមសេនីយ៍...អាហ្នឹងញៀនហ្មង ញៀនអំណាច អាហ្នឹងជំងឺសង្គមដែលកើតឡើងយូរហើយតាំងពីជំនាន់ស្តេច"។

ដោយឡែកចំពោះជំងឺ លោភលន់វិញ លោកបណ្ឌិតធ្លាប់ប្រាប់អ្នកសារព័ត៌មាន បើសិនជាមិនមានយន្តការទប់ស្កាត់ទេ អ្នកណាឡើងកាន់អំណាចក៏ចង់បានតែម្នាក់ឯងបែបនេះ យូរៗទៅប្រទេសកម្ពុជាទាំងមូលចង់បានតែម្នាក់ឯង "ចង់ឲ្យគេងាប់ឲ្យអស់ហើយយកតែម្នាក់ឯង អត់ខ្លាចខ្មោចលងទេឬអី?"។

ចំពោះជំងឺហិង្សាលោក បណ្ឌិតធ្លាប់បានចែករំលែកថា ជាទម្លាប់នៃការប្រើអំពើហិង្សា នៅពេលដែលខ្លួនធ្វើជាទាហាន ធ្វើជានគរបាល ធ្វើជាប៉េអឹម ធ្វើជានាយករដ្ឋមន្ត្រី ធ្វើជារដ្ឋមន្ត្រី "ចង់បាញ់ ចង់សម្លាប់ចង់យកអាណាទៅបាញ់ចោល ចង់យកអាណាទៅសម្លាប់ចោល ប្រព្រឹត្តដាក់គេអីចឹងទៅ... អាហ្នឹងខ្ញុំគិតថា ទម្លាប់ហិង្សាហ្នឹងធំណាស់ដែលយើងត្រូវតែព្យាបាល"។

ដោយឡែកជំងឺទី៤ គឺជាជំងឺផ្លូវចិត្ត ដែលលោកបណ្ឌិតអះអាងថា ជាវប្បធម៌សងសឹកគ្នារបស់មេដឹកនាំខ្មែរពីមួយជំនាន់ទៅមួយជំនាន់ ដែលនេះក៏ជាចំណុចត្រូវរិះគិត។

នៅមុនពេលបាត់បង់ជីវិត ក្រៅពីទស្សនៈនិងយោបល់ខាងលើនេះ លោកបណ្ឌិតនៅបានផ្តល់គំនិត និងយោបល់ជាច្រើនទៀតសម្រាប់សង្គមកម្ពុជា។

## សកម្មភាពគួរឲ្យកត់សំគាល់នៅមុនអំពើឃាតកម្មមកលើលោកបណ្ឌិត កែម ឡី

នៅមុនពេលបាត់បង់ជីវិតអ្វីដែលគួរឲ្យកត់សំគាល់នៃសកម្មភាពរបស់លោកបណ្ឌិតមួយទៀតគឺ លោកបានប្រកាសតាមប្រព័ន្ធផ្សព្វផ្សាយនៅក្នុងការធ្វើនូវយុទ្ធនាការ ១០០ រាត្រីនៃគ្រួសារខ្មែរ ដែលនេះគឺជាយុទ្ធនានៃការស្រាវជ្រាវមួយ ជាមួយនឹងប្រជាពលរដ្ឋនៅតំបន់ដាច់ស្រយាល ដើម្បីសិក្សាអំពីជីវភាព និងស្ថានភាពពួកគេនៅតាមបណ្តោយព្រំដែនកម្ពុជាវៀតណាម ដោយមកទល់នឹងពេល លោកបាត់បង់ជីវិត គឺលោកទើបតែសម្រេចបាន ១៥រាត្រីប៉ុណ្ណោះ។

តាមរយៈយុទ្ធនាការនេះ ទើបបណ្តាលឲ្យមានការវិភាគថា ការបាត់បង់ជីវិតរបស់លោកអាចពាក់ព័ន្ធ និង ឥទ្ធិពលពីបរទេស ។ ក្រៅពីបញ្ហាទាំងនេះ រឿងដែលក្តៅបំផុត គឺលោកបណ្ឌិតបានចេញមុខនៅក្នុងការបញ្ចេញយោបល់ទាក់ទងនឹងរបាយការណ៍មួយរបស់អង្គការ ហ្គូបិលវីណេស ដែលស្គាល់ថាអង្គការឃ្លាំមើលពិភពលោកមួយដែលបានចេញផ្សាយរបាយការណ៍មួយមានចំណងជើងថា "អាណាចក្រត្រកូលហ៊ុន" ដោយលោកបណ្ឌិតបានវិភាគ និងបញ្ចេញយោបល់ដ៏រសើបមួយចំនួនទាក់ទង និងសកម្មភាពអាជីវកម្មរបស់ក្រុម គ្រួសារប្រមុខរដ្ឋាភិបាលនៅកម្ពុជា ។

នៅក្នុងការធ្វើអត្ថាធិប្បាយនោះ លោកបានវិភាគដោយដាក់បន្ទុកជាច្រើនទៅលើក្រុមគ្រួសារអ្នកកាន់ អំណាចទាក់ទងនិងក្រុមគ្រួសារអ្នកកាន់អំណាច ។

លោកធ្លាប់បានអះអាងថា កម្ពុជាកំពុងតែស្ថិតនៅលើផ្លូវបំបែក ហើយពលរដ្ឋកាន់តែស្រេកឃ្លានលទ្ធិប្រជាធិបតេយ្យ ។

## ប្រវត្តិការងារនិងគ្រួសារក៏ដូចជាការសិក្សាលោកបណ្ឌិត កែម ឡី

លោកបណ្ឌិត កែម ឡី ត្រូវបានគេដឹងថា គឺជាប្រជាពលរដ្ឋកម្ពុជាដែលមានស្រុកកំណើតនៅភូមិអង្គតាកុក ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។ លោកបានបាត់បង់ជីវិតនៅអាយុ ៤៧ឆ្នាំ ដោយមានភរិយា និងកូន៤ នាក់ ដោយនៅក្នុងនោះភរិយារបស់លោកកំពុងមានផ្ទៃពោះ ៥ខែម្នាក់ទៀត។

នៅពេលបញ្ចប់ការសិក្សាសញ្ញាបត្រទុតិយភូមិ នៅក្នុងឆ្នាំ១៩៨៨ លោកត្រូវបានគេដឹងថា បានមកបន្តការសិក្សាពេទ្យនៅភ្នំពេញ ហើយបានបន្តទទួលអាហាររូបករណ៍នៅសាលាក្រៅប្រទេសមួយចំនួនដូចជា នៅសាកលវិទ្យាល័យ ជូឡាឡុងកន ប្រទេសថៃ និងសាកលវិទ្យាល័យនៅម៉ាឡេស៊ី និងសិក្សានៅក្នុងប្រទេសមួយចំនួនទៀត។

លោកបណ្ឌិតជាបញ្ញវ័ន្ត ដែលធ្លាប់បានបម្រើការនៅតាមស្ថាប័នមួយចំនួនទាំងរដ្ឋ ឯកជន និងអង្គការក្រៅរដ្ឋាភិបាលដូចជា ក្រសួងសុខាភិបាល កាកបាទក្រហម កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ វិទ្យាស្ថានជាតិដើម្បីប្រជាធិបតេយ្យមូលនិធិសហប្រជាជាតិដើម្បីកុមារ ទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីការអភិវឌ្ឍន៍អន្តរជាតិ។





# ព្រះសហាគមន៍កាតូលិកភូមិភាគភ្នំពេញបង្កើត

ព្រះសហាគមន៍កាតូលិកនៅក្នុងភូមិភាគភ្នំពេញកំពុងតែ និងបោះជំហានទៅមុខ នៅក្នុងការបង្កើតនៅសហគ្រិនភាពនៃសង្គមមួយនូវកម្ពុជា នៅក្នុងគោលបំណងដើម្បីជួយដល់អ្នកក្រីក្រដែលមានសមត្ថភាពទាប និងពិបាកនៅក្នុងការប្រកួតប្រជែងស្វែងរកការងារធ្វើនៅតាមបណ្ដារោងចក្រសហគ្រាសនានានៅក្នុងប្រទេស។

លោកអូលីវីយេ ផ្ទឹតអីស្ល៊េរ អភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានមានប្រសាសន៍កាលពីពេលថ្មីៗនេះថា នេះគឺជាគំនិតផ្តួចផ្តើមមួយរបស់ព្រះសហាហគមន៍ ដើម្បីជាផ្នែកមួយជួយឲ្យសមាជិកសង្គមនៅកម្ពុជា ទាំងស្រីទាំងប្រុសដែលខ្វះលទ្ធភាពនៅក្នុងការស្វែងរកការងារធ្វើ ដោយសារបញ្ហាគ្មានជំនាញខ្សត់ខ្សោយផ្នែកកម្លាំងជនពិការឲ្យពួកគេមានការងារធ្វើនៅក្នុងបរិយាកាសមួយដែលមិនពិបាករីករាយហើយងាយស្រួល និងបំពេញសម្រាប់ពួកគេ។

លោកអូលីវីយេ ផ្ទឹតអីស្ល៊េរ បានបញ្ជាក់ថា "នេះគឺជាផ្នែកមួយដែលយើងបានរិះគិតដើម្បីជួយសម្រាប់អ្នកដែលទន់ខ្សោយដែលមិនមានសមត្ថភាពធ្វើការនៅតាមរោងចក្រមួយចំនួនដោយសារតែគាត់ធ្វើការយឺត ដោយសារតែគាត់មានកម្លាំងខ្សោយដូច្នេះនេះជាឱកាសមួយដើម្បីលើកទឹកចិត្តពួកគេ គោរពសមត្ថភាពរបស់ពួកគេនឹងដើម្បីឲ្យពួកគេមានទាំងការងារធ្វើប្រកបដោយកិត្តិយសដោយគេអាចមានប្រាក់ខែសមល្មមដែលអាចសល់ផ្ញើទៅផ្ទះខ្លះ និងទុកសម្រាប់គេខ្លះ"។

លោកអូលីវីយ បោនមានប្រសាសន៍ថា មកដល់ពេលនេះសហគ្រិនសង្គមដែលព្រះសហគមន៍ភូមិភាគភ្នំពេញបានផ្តួចផ្តើមគំនិតឡើងនេះ គឺកំពុងតែស្ថិតនៅក្នុងដំណាក់កាលនៃការចាប់ផ្តើមពេលគឺមិនទាន់ធំនៅឡើយទេ ប៉ុន្តែបានជួយដល់បងប្អូនមួយចំនួនមានការងារធ្វើដូចជានៅរោងសិប្បកម្មផលិតស្កគ្រាប់តម្បាញសូត្រជាដើម។

បណ្ដាបុគ្គលិកកម្មករដែលបម្រើការនៅក្នុងសហគ្រិនសង្គមនេះ គឺអាចទទួលបាននូវការងារធ្វើការហូកចុកការស្នាក់នៅការផ្តល់សេវាសុខភាពផ្តល់ការអប់រំការធ្វើការជាក្រុមនៅក្នុងបរិយាកាសការ-ងារមួយដែលមានបរិស្ថានមានទេសភាពយ៉ាងប្រសើរ។

លោកអូលីវីយេ ផ្ទឹតអីស្ល៊េរបានមានប្រសាសន៍ថា បងប្អូនបុគ្គលិកម្មករនៅក្នុងសហគ្រិនសង្គមដែលយើងកំពុងតែគិតបានបម្រើការងារនៅក្នុងរោងសិប្បកម្មចំនួន៣សប្តាហ៍ ហើយពួកគេអាចទៅផ្ទះជួបជុំបងប្អូនគ្រួសារបានមួយសប្តាហ៍ដោយនៅក្នុងពេលស្នាក់នៅក្នុងសហគ្រិនសង្គមនេះ គឺទទួលបានទាំងប្រាក់ខែដ៏សមរម្យ និងមានកន្លែងស្នាក់នៅហូបចុកថែទាំងសុខភាពយ៉ាងបរិបូរណ៍។

លោកអូលីវីយេ ផ្ទឹតអីស្ល៊េរបានថ្លែងថា នៅក្នុងរោងសិប្បកម្មនេះ គឺយើងបានខិតខំផ្តល់នូវការយកចិត្តទុកដាក់៧ចំណុច គឺមានការអប់រំដោយយើងបានយកចិត្តទុកដាក់បញ្ជូនកុមារកំព្រានិងយុវជនមួយចំនួនទៅសាលារៀន។ អំពីផ្នែកសុខភាពនៅទីនេះយើងយកចិត្តទុកដាក់ ចំពោះពួកគេទាំងអស់ដែលជាជនពិការ និងអ្នកដែលបម្រើការនៅទីនោះទាំងមូលឲ្យអស់ពីសមត្ថភាព។ ចំពោះវិស័យពលករ គឺយើងបានបង្កើតនូវរោងចក្រមួយដើម្បីឲ្យពួកគេមានការងារធ្វើហើយបើនិយាយអំពីជនពិការវិញ គឺយើងយកចិត្តទុកដាក់ផ្តល់ការងារដល់ពួកគេ។ ដោយអ្នកនៅទីនេះយើងមានអ្នកពិការ ដៃ ជើង ភ្នែកមនុស្សតឿជាដើម។ អំពីបរិស្ថាន និងធម្មជាតិ គឺយើងមានសួនច្បារទាំងផ្កាទាំងដើមឈើ ទាំងដើមឈើហូបផ្លែ មួយកំប្លែររួមទាំងសត្វថែមទៀត។

លោកអភិបាល បានបន្តថា អំពីការជួយអ្នកក្រីក្រនៅក្នុងសង្គម គឺយើងមានកម្មវិធីនេះជាមួយនឹងរោងសិប្បកម្មស្កគ្រាប់ដោយអ្នកខ្លះគាត់គ្មានក្តីសង្ឃឹមទេ តែយើងនៅតែជួយពួកគេហើយព្យា-យាមផ្តល់ការងារតិចៗដើម្បីជួយពួកគេ។

លោកអភិបាល បានបន្ថែមទៀតថា លើផ្នែកអន្តរសាសនាវិញនៅទីនេះយើងមានចម្រុះដោយនៅទីនេះមានពុទ្ធបរិស័ទច្រើន និងគ្រីស្តបរិស័ទមួយចំនួន ប៉ុន្តែយើងលើកទឹកចិត្តឲ្យពួកគេធ្វើការរួមគ្នាជាអន្តរសាសនា។

លោកអូលីវីយេ ផ្ទឹតអីស្ល៊េរបានបញ្ជាក់ថា "នៅទីនេះគឺយើងព្យាយាមបណ្តុះស្មារតីឲ្យពួកគេជ្រួតជ្រាបទាំង ៧ ចំណុចដើម្បីជាប្រយោជន៍ចំពោះពួកគេ។ អ្វីដែលយើងបានធ្វើនៅទីនេះ គឺដើម្បីផ្តល់ចំណេះដឹង និងបញ្ញាបដើម្បីឲ្យពួកគេយល់អំពីតម្លៃជាគ្រួសារ និងបង្កើតបរិកាសល្អដែលយល់ពីពួកគេជួយពួកគេ។ នេះគឺជាគំនិតផ្តួចផ្តើមជាសហគមន៍សហគ្រិនមួយនៅភូមិភាគភ្នំពេញដើម្បីធានាភាពច្បាស់លាស់ ហើយមកដល់ពេលនេះ គឺយើងមានរូបរាងដូចជារោងសិប្បកម្មស្កគ្រាប់កន្លែងតម្បាញសូត្រ"។

លោកអូលីវីយេ ផ្ទឹតអីស្ល៊េរបានបន្តថា ក្រៅពីនេះដូចជានៅភ្នំវ័ល្លិ៍យើងកំពុង



ដោយ: កញ្ញា

## វិស័យឧស្សាហកម្មផ្តល់ចំណូលចូលរដ្ឋ ៨,៨ ពាន់លានដុល្លារ តែគ្មានកំណត់ត្រាអំពីការរួមចំណែករបស់ជនពិការ

យោងតាមរបាយការណ៍ប្រចាំឆ្នាំ២០១៥ របស់ក្រសួងឧស្សាហកម្ម និងសិប្ប-កម្ម បានអះអាងថា កម្ពុជាមានរោងចក្រចំនួន ១.៤៥០ និងសហគ្រាសខ្នាតតូចនិងមធ្យមប្រមាណជា ៣៨.៨៣១ កន្លែង ដោយផ្តល់ការងារធ្វើសរុបចំនួន ១.០៥៣.៥៩៩ នាក់ ប៉ុន្តែសម្រាប់ជនពិការគឺគ្មានតួរលេខ ។

ប្រភពដដែលបានបន្តថា បណ្ដារោងចក្រ និងសហគ្រាសឧស្សាហកម្មខ្នាតតូចនិងមធ្យមទាំងនេះ គឺបានរួមចំណែកនៅក្នុងការបង្កើតជាប្រាក់ចំណូលប្រមាណជា ៨.៨៧៣ លានដុល្លារ ប៉ុណ្ណោះ ។

លោក ប៉ុម សារ៉ាន់ អាយុ ២៧ ឆ្នាំជាជនពិការកំពស់ មួយរូប បានអះអាងថាឱកាសការងារសម្រាប់ជនពិការនៅរោងចក្រ និងបណ្ដាសហគ្រាសឧស្សាហកម្មខ្នាតតូច និង មធ្យមទាំងនេះគឺអាចគ្មាន ឬ បើមានគឺតិច ។

លោកបានបញ្ជាក់ថា លោកធ្លាប់ទូរស័ព្ទទំនាក់ទំនងស្វែងការងារធ្វើជាច្រើនកន្លែងណាស់ ពេលមិនទាន់ស្គាល់ព្រះ សហគមន៍កាតូលិក ប៉ុន្តែ ឱកាសទទួលការងារ គឺគ្មាន។

លោកបានបន្តថា "ខ្ញុំតេ ( ទូរសព្ទ័ )ទៅច្រើនកន្លែងណាស់ ប៉ុន្តែចម្លើយគឺថាអត់មានគោលការណ៍រើសជនពិការ"។

# សហគ្រិនសង្គមនៅកម្ពុជា



## រដ្ឋកំណត់កូត្រាឲ្យជ្រើសរើសមន្ត្រីជាជនពិការឲ្យបាន២ភាគរយ

ដើម្បីជាការលើកទឹកចិត្តដល់ជនពិការ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹតមួយ ដែលចុះហត្ថលេខា ដោយ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីឲ្យបណ្តាក្រសួងមន្ទីនានារបស់រដ្ឋ ផ្តល់ការងារធ្វើដល់ជនពិការឲ្យបាន យ៉ាងតិច២ភាគរយ ។

យោងទៅតាមសារនៅក្នុងទិវាជនពិការជាតិនិងអន្តរជាតិ ដែលប្រកាសកាលពី ខែធ្នូ ឆ្នាំ២០១៥កន្លងទៅ របស់សម្តេចតេជោ បានឲ្យដឹងថា ជនពិការត្រូវបានជំរុញ និងលើកទឹកចិត្តឲ្យបណ្តាក្រសួងមន្ទីចំណុះរដ្ឋ ៤០ស្ថាប័នផ្តល់ការងារធ្វើចំពោះជនពិការ ។

តួលេខនៃជនពិការដែលកំពុងតែបម្រើការតាមបណ្តាស្ថាប័ន និងក្រសួងមន្ទីរនានារបស់រដ្ឋមិនត្រូវបានដឹងនាឆ្នាំ២០១៦នេះ ប៉ុន្តែកាលពីឆ្នាំ២០១៤ មានសេចក្តីរាយការណ៍មួយដែលអះអាងថារាជរដ្ឋាភិបាល បានផ្តល់ការងារធ្វើដល់ជនពិការប្រមាណជា ២.៥៥០ នាក់ គឺស្មើ នឹង១,១៧ភាគរយ នៃបុគ្គលិកសរុប ហើយរំពឹងថា នឹងកើនដល់ ៣.៩៤៩នាក់ នៅឆ្នាំ២០១៥។

តែរៀបចំឲ្យមានការកែច្នៃម្ហូបអាហារខ្លះដើម្បីឲ្យនៅទីនោះក្លាយទៅជាសហគ្រិនសង្គមមួយទៀត។ លោកបានបន្តទៀតថា យើងកំពុងតែរិះគិតដើម្បីបង្កើតសិប្បកម្មផ្សេងៗទៀតដែលយើងចង់បង្កើតជាពិសេសនៅក្នុងភូមិសុខសាន្តដែលយើងមានកាត់ដេរ ការកែច្នៃនំទឹកសណ្តែក កែច្នៃឈើដើម្បីធ្វើជាល្បែងរបស់កូនក្មេង។

លោកអូលីវីយេ ជ្មីតអីស្លែរបានបញ្ជាក់ជាថ្មីទៀតថា "នេះគឺជាគំនិតផ្តួចផ្តើមមួយនៅក្នុងគំនិតផ្តល់ការអប់រំ និងលើកកម្ពស់បណ្តុះគំនិតជាសហគ្រិននៅក្នុងព្រះសហគមន៍ដើម្បីជួយដល់អ្នកក្រីក្រ អ្នកទន់ខ្សោយប្រកបដោយនិរន្តរភាព"។

លោកបានបញ្ជាក់ទៀតថា "គោលគំនិតរបស់យើង គឺមិនចង់ឲ្យពួកគេនៅតែជាអ្នកក្រីក្រយើងចង់ឲ្យពួកគេមានការងារធ្វើមានប្រាក់ខែមានលុយសន្សំដើម្បីឲ្យពួកគេមានអ្វីដែលជារបស់ខ្លួនមានអ្វីដែលជាកម្មសិទ្ធិរបស់ពួកគេ។

លោកអភិបាល បានបន្តទៀតថា នេះជាការរួមចំណែកមួយដ៏តូចហើយមិនច្រើនទេតែយើងខិតខំតាមសមត្ថភាព និងលទ្ធភាពរបស់យើងដើម្បីជួយដល់ពួកគេ។

លោកបានបន្ថែមទៀតថា នេះ គឺជាឱកាសមួយដើម្បីជួយឲ្យសង្គមរបស់កម្ពុជារីក ចម្រើនវាមិនច្រើនទេ ប៉ុន្តែបើកន្លែងនីមួយៗគេអាចធ្វើដូច្នេះក៏ល្អ។ ឧទាហរណ៍ដូចជានៅភូមិសុខសាន្តមានគ្រួសារជនពិការគេចេះដាល់អំបុកហើយឥឡូវកំពុងតែទទួលចំណេញហើយយើងក៏បានជួយជនពិការពីរនាក់ផ្សេងទៀតឲ្យក្លាយជាជាងកាត់ដេរដែរ។ នៅពេលនេះយើងកំពុងតែបង្រៀនស្ត្រីពីរបីនាក់ឲ្យចេះត្បាញក្រមា យើងក៏មានគម្រោងការណ៍ទិញម៉ាស៊ីនប៉ាក់ដើម្បីឲ្យពួកគេចេះប៉ាក់ដោយខ្លួនឯង។

តាមប្រសាសន៍របស់លោកអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ គំនិតនៅក្នុងការរុញច្រាន់សហគ្រិនសង្គមនេះឲ្យរីកចម្រើនទៅមុខក៏ជាផ្នែកមួយ ដែលព្រះសហគមន៍កំពុងតែរិះគិតផងដែរ។

លោកអូលីវីយេ ជ្មីតអីស្លែរបានបន្តថា នៅពេលនេះយើងកំពុងតែរៀបចំសហគ្រិនសង្គមនៅភូមិភាគភ្នំពេញ ដើម្បីឲ្យមានច្បាប់មានឡូហ្គោដើម្បីយើងអាចលក់ផលិតផលរបស់យើងនៅផ្សារធំៗបានហើយយើងក៏កំពុងតែរៀបចំពង្រីកផលិតកម្មរបស់យើងឲ្យមានច្រើនដូចជាការធ្វើស្ករគ្រាប់ចេក ស្វាយ ម្នាស់តាមរដូវ និងកំពុងតែរៀបចំធ្វើទីផ្សារជាមួយនឹងជនបរទេសបន្ថែមទៀតដើម្បីបានតម្លៃខ្ពស់។

លោកបានបញ្ជាក់ថា "គោលការណ៍សហគ្រិនសង្គមនេះ យើងមិនមែនរិះគិតដើម្បីចំណេញទេ។ តែយើងរិះគិតដើម្បីបានលុយចំណូល និងមានទីផ្សារសម្រាប់ជួយអ្នកក្រីក្រអ្នកដែលមានស្ថានភាពលំបាកផ្សេងៗ"។

រហូតមកដល់ពេលនេះ គេដឹងថារាជរដ្ឋាភិបាលបានចេញនូវអនុក្រឹតមួយដែលកំណត់ឲ្យមានការជ្រើសរើសជនពិការឲ្យចូលធ្វើការនៅតាមក្រសួងមន្ទីរដែលជាស្ថាប័នរដ្ឋនានា ហើយក៏បានលើកទឹកចិត្តឲ្យបណ្តាក្រុមហ៊ុនអាជីវកម្មនៅកម្ពុជានានា ផ្តល់ឱកាសការងារដល់បងប្អូនជាជនពិការ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយបងប្អូនពិកានៅតែត្អូញត្អែរអំពីការពិបាករកការងារធ្វើ ជាពិសេសសម្រាប់អ្នកដែលខ្វះធនធាន ខ្វះសមត្ថភាពនៅក្នុងការសិក្សាឲ្យបានជ្រៅជ្រះ។

លោក ម៉ែន យ៉ុំ អាយុ ២៧ ជាកម្មករនៅរោងសិប្បកម្មស្ករគ្រាប់ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានឲ្យដឹងថានៅក្នុងនាមជាជនពិការដៃ និងជើងតាំងពីកំណើតមក ហើយមានលទ្ធភាពសិក្សាត្រឹមតែថ្នាក់ទី៩ អះអាងថា លោកពិតជាអស់សង្ឃឹមមែនទែន នឹងការស្វែងរកការងារធ្វើ ប៉ុន្តែនៅពេលនេះសហគ្រិនសង្គមនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញកំពុងតែផ្តល់ក្តីសង្ឃឹមនេះដល់លោក។

លោកបានបញ្ជាក់ថា "ខ្ញុំមិនដែលសង្ឃឹមថា អាចរស់នៅជាមួយនឹងកម្លាំងញើសឈាមខ្លួនឯងដូចបច្ចុប្បន្ននេះទេ ប៉ុន្តែឥឡូវខ្ញុំមានការងារធ្វើ មានប្រាក់ចំណូលខ្លះជួយគ្រួសា ជាពិសេសបងស្រីដែលកំពុងតែឈឺ "។

លោក ប៉ុម សារ៉ាន់ អាយុ ២៧ ឆ្នាំជាជនពិការកំពស់មួយរូប ដែលកំពុងតែបម្រើការងារជាមួយនឹង លោក ម៉ែន យ៉ុំ បានអះអាងថា ក្រោយពេលដែលរៀនចប់ថ្នាក់ទី១២ គឺលោកធ្លាប់បានស្វះស្វែងរកការងារធ្វើជាច្រើនកន្លែង ប៉ុន្តែគ្មានកន្លែងណាដែលអាចផ្តល់ឱកាសដល់លោកជាជនពិការ និងដែលមានការសិក្សាបន្តិចបន្តួចបែបនេះឡើយ។

លោកបានបញ្ជាក់ថា "ខ្ញុំធ្លាប់ទូរស័ព្ទសួររកការងារធ្វើជាច្រើនកន្លែងតែចម្លើយគឺមានត្រឹមតែអត់មានកន្លែង។ ម៉ាជីវិតខ្ញុំនេះគិតថា នឹងពឹងវាសនាជាមួយឪពុកម្តាយ និងបងប្អូនម៉ាជីវិតហើយ។ តែពេលនេះ ខ្ញុំមានសង្ឃឹម ដោយសារតែខ្ញុំមានការងារធ្វើ មានប្រាក់ខែ គ្រាន់ចិញ្ចឹមខ្លួន ដូចគេដូចឯង"។

លោកបានបន្តថា លោកអរគុណចំពោះព្រះសហគមន៍កាតូលិក ដែលបានផ្តួចផ្តើមគំនិតរៀបចំជារោងសិប្បកម្មស្ករគ្រាប់ ដែលជាសហគ្រាសសង្គមមួយជួយផ្តល់ការងារដល់អ្នកដែលគ្មានក្តីសង្ឃឹមដូចជារូបលោក។

*ដោយ អរិយបុត្រ*

# ពិធីបិទឆ្នាំសិក្សា២០១៥-២០១៦ នៅទេវវិទ្យាល័យ សន្ត យ៉ូហាន ម៉ារីវីយ៉ាណែ

ទេវវិទ្យាល័យ សន្ត យ៉ូហាន ម៉ារីវីយ៉ាណែ រៀបចំអភិបូជាបិទឆ្នាំសិក្សា ២០១៥-២០១៦ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ ក្រោមអធិបតីភាព លោកអូលីវីយេ ស្មីតហាស្លែរ ជាអភិបាល ព្រះសហគមន៍កាតូលិក ដែលទទួលបន្ទុកលើទេវៈវិទ្យាល័យ ដោយមានអ្នកចូលរួមប្រមាណជាង៦០នាក់។

ក្នុងអភិបូជានេះ លោកអភិបាលបានមានប្រសាសន៍ណែនាំ ដោយធម្មទេសនា ដើម្បីជំរុញឲ្យនិស្សិតទេវវិទ្យាល័យ រិះគិត និងវាយតម្លៃអំពីលទ្ធផលនៃការសិក្សាកន្លងមក ជាពិសេសអំពីរបៀបដែលនិស្សិតប្រព្រឹត្តក្នុងនាមជាព្យាការីរបស់ព្រះជាម្ចាស់។ លោកក៏បានផ្តល់ជាអនុសាសន៍ ដល់និស្សិត និងបូជាចារ្យ ដែលចូលរួមក្នុងពិធីនេះចំនួន ៤ចំនុច ដើម្បីជាជំនួយក្នុងការរិះគិតគឺ ១) តើជីវិតនិងអ្វីដែលយើងខ្ញុំបានប្រកាសដូចគ្នាដែរឬអត់? ២) រិះគិតអំពីកំរិតនៃជីវិតខាងផ្លូវវិញ្ញាណ រិះគិតអំពីសេចក្តីស្រឡាញ់របស់ព្រះយេស៊ូ និងកំរិតនៃការកែប្រែចិត្តគំនិត ជាពិសេសក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ តើខ្លួនបានស្រឡាញ់ព្រះជាម្ចាស់ដល់កំរិតណា? ៣) ស្គាល់ខ្លួនឯងបន្ថែមទៀតនូវអ្វីដែលល្អ និងអ្វីដែលមិនល្អ។ ៤) ពិនិត្យមើលលទ្ធផលដែលជាផលផ្លែដែលបានទទួលពេញមួយឆ្នាំនេះ។

លោកអភិបាល អូលីវីយេ ក៏បានពន្យល់បន្ថែមអំពីមុខងារជាព្យាការីរបស់ព្រះជាម្ចាស់ថា ព្យាការី មានតួនាទីធ្វើឲ្យមនុស្សភ្ញាក់ស្មារតី កែប្រែចិត្តគំនិត ហើយក៏ធ្វើឲ្យមនុស្សអន់ចិត្ត និងឈឺចិត្តជាពិសេស ចំពោះរឿងអយុត្តិធម៌ និងសេរីភាពនៅក្នុងសង្គម ដូចអ្វីដែលយើងបានមើលអំពីជីវិតរបស់ព្រះយេស៊ូដែរ។ លើសពីនេះទៅទៀតលោកបានបន្តថា ទេវវិទ្យាល័យ និងព្រះសហគមន៍ត្រូវការគឺគ្រីស្តទូតដ៏វិសុទ្ធដែលចេះបង្ហាញអំពីអំណរសប្បាយ មានសេចក្តីស្រឡាញ់ ដែលមានព្រះវិញ្ញាណដ៏វិសុទ្ធណែនាំដើម្បីទៅជាសញ្ញាសម្គាល់អំពីព្រះជាម្ចាស់។

និស្សិតប៊ុនលីបាននិយាយបន្តទៀតថា រយៈពេលមួយឆ្នាំកន្លងមកនេះបានរកឃើញអំណរសប្បាយអំពីជីវិតខាងវិញ្ញាណ តាមរយៈព្រះបន្ទូលព្រះយេស៊ូ និងជាពលេវលោមួយដលែហានទំនាក់ទំនងជាមួយព្រះជាម្ចាស់។ ហេតុនេះហើយខ្ញុំយល់ថាជីវិតនៅក្នុងទេវវិទ្យាល័យ បានឲ្យខ្ញុំបានស្គាល់អំពីខ្លួនឯង និងការត្រាស់ហៅច្បាស់ជាងមុន ជាពិសេសមានបទពិសោធន៍អំពីព្រះយេស៊ូផ្ទាល់ក្នុងជីវិត ដោយស្គាល់ព្រះហឫទ័យព្រះជាម្ចាស់។ លើសពីនេះទៅទៀត គឺបានទទួលសេចក្តីស្រឡាញ់ពីព្រះជាម្ចាស់ ដែលធ្វើឲ្យខ្ញុំមានការរីកចម្រើនបន្តិចម្តងៗនៅក្នុងជីវិតនៃការត្រាស់ហៅនេះ ដោយយល់ថា



ថតដោយៈ សុធារិទ្ធ

ជាសុភមង្គលយ៉ាងពិតប្រាកដ ទាំងជីវិតខាងផ្លូវវិញ្ញាណទាំងព្រះសហគមន៍ទាំងជីវិតនៅក្នុងសង្គម និងជីវិតជាក្រុម។

ក្រោយអភិបូជាលោកអភិបាលបានប្រកាសចាត់តាំងដើម្បីឲ្យនិស្សិតចេញទៅបំពេញបេសកម្មក្នុងឱកាសវិស្សមកាល ៣ខែខាងមុខ គឺ ១) លោកវី សំណាង លោកសុខ ខឿន និងលោកឧបដ្ឋាក ឆាល ទៅបម្រើព្រះសហគមន៍នៅតំបន់តាកែវ ជាមួយលោកបូជាចារ្យ សាន់ដេ។ ២) លោកវិន កាន់ និងលោកសុខ សំណាង ទៅបម្រើព្រះសហគមន៍មណ្ឌលសកម្មភាពកំពង់សោម ជាមួយលោកបូជាចារ្យ អ៊ិន សុន។ ៣) លោកកែវ សំណាង ទៅបម្រើព្រះសហគន៍កំពត ជាមួយលោកបូជាចារ្យ យ៉ាំង លូកា។ ៤) លោក ប៊ុន លី និងលោកហេង សុផាត ទៅបម្រើព្រះសហគមន៍ភូមិភាគកំពង់ចាម ជាមួយលោកបូជាចារ្យ សេរ៉ាល់ និងលោកបូជាចារ្យ ផាន បូរី។

ទេវវិទ្យាល័យ សន្ត យ៉ូហាន ម៉ារីវីយ៉ាណែ ជាទេវវិទ្យាល័យតែមួយគត់ នៅក្នុងព្រះសហគមន៍កាតូលិកប្រទេសកម្ពុជា ដែលជាសាលាបណ្តុះបណ្តាលយុវជនសិក្សាអំពីទេវវិទ្យា និងមុខវិជ្ជាជាច្រើនទៀតដើម្បីត្រៀមខ្លួនក្នុងការឆ្លើយតបនឹងការត្រាស់ហៅរបស់ព្រះជាម្ចាស់ ដើម្បីបំពេញមុខងារជាបូជាចារ្យកាតូលិក។

*ដោយ ដាលីស*

# ព្រះវិហារសន្តមីការ៉ែអែលប្រារព្ធទិវាមហាករុណាទិគុណចំពោះអ្នកជំងឺនិងអ្នកពិការ



ព្រះសហគមន៍កាតូលិក សន្តមីការ៉ែអែល ខេត្តព្រះសីហនុ បានរៀបចំកម្មវិធីអភិបូជាយ៉ាងឱឡារិកក្នុងថ្ងៃនៃឆ្នាំមហាករុណាទិគុណសម្រាប់អ្នកជំងឺ និងជនពិការតាមសេចក្តីអំពាវនាវរបស់ លោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ។ ពិធីបានប្រារព្ធកាលពីថ្ងៃទី១១ មិថុនា ២០១៦កន្លងទៅ ដោយមានអ្នកជំងឺ និងជនពិការចំនួន ៤៥នាក់ និងគ្រីស្តបរិស័ទជាច្រើនចូលរួមក្រោមការដឹកនាំដោយលោកយ៉ូហាន អ៊ិន សុន បូជាចារ្យទទួលសុខត្រូវនៅមណ្ឌលសកម្មភាពកំពង់សោម។

លោកបូជាចារ្យ យ៉ូហាន អ៊ិន សុន បានមានប្រសាសថា "យើងម្នាក់ៗតែងតែមានជំងឺ និងជួបនូវរឿងមិនល្អជាច្រើន ថែមទាំងសេចក្តីស្លាប់ គឺយើងជៀសមិនផុតសោះឡើយ ប៉ុន្តែបើយើងជឿ សង្ឃឹមលើព្រះជាម្ចាស់វិញនោះ ព្រះអង្គ និងសង្គ្រោះ យើងឲ្យរួចពីសេចក្តីទុក្ខទាំងអស់នោះ ទោះបីមិនអាចផុតពីស្លាប់"។

លោកក៏បានបន្ថែមទៀតថា "ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ និងមកសណ្ឋិតលើយើងម្នាក់ៗដើម្បីឲ្យបងប្អូនបានរួចពីទុក្ខកង្វល់ទាំងឡាយដែលយើងមាន។

លោកបូជាចារ្យ អ៊ិន សុន ក៏បានបន្តដោយណែនាំគ្រីស្តបរិស័ទទាំងអស់ឲ្យគោរពស្រលាញ់ព្រះយេស៊ូអស់ពីកម្លាំងកាយចិត្ត ដើម្បីបម្រើព្រះអង្គដោយចិត្តបរិសុទ្ធ។

ក្នុងនោះផងដែរក៏មានការញាំុអាហារសាមគ្គីរួមគ្នាក្រោយអភិបូជាដើម្បីបង្ហាញថា យើងជាក្រុមគ្រួសារតែមួយក្នុងអង្គព្រះគ្រីស្តផងដែរ។

ការយកចិត្តទុកដាក់នឹងអ្នកជំងឺ ជនពិការ គឺជាចំណុចអាទិភាពមួយរបស់ព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ ដែលបានដាក់ជូនដល់ព្រះសហគមន៍កាតូលិកទាំងអស់នៃភូមិភាគនេះ ក្នុងឆ្នាំមេត្តាករុណា នៃព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់។ ព្រោះអ្នកទាំងនោះជាបុត្រធីតារបស់ព្រះជាម្ចាស់ដែរ ជីវិតមានតម្លៃ មានសេចក្តីថ្លៃថ្នូរ ដូចគ្រប់មនុស្សទាំងអស់។

*ដោយ តូច ពឿន*

# ក្រុមកីឡាករកងរាជអាវុធហាត់ខេត្តបាត់ដំបង លើកពានរង្វាន់លោកអភិបាលឆ្នាំនេះ



ក្រុមកីឡាករកងរាជអាវុធហាត់ខេត្តបាត់ដំបងទទួលពានរង្វាន់ ថតដោយៈ សុវណ្ណា

ក្រុមកីឡាករមហាជន ក្រុមកុមារអាយុក្រោម១៣ឆ្នាំ និងក្រុមកីឡាការិនី មកពីព្រះសហគមន៍នានា នៃភូមិភាគបាត់ដំបង និងក្រុមកីឡាមហាជនមកពីស្ថាប័ននានា ក្នុងទីរួមខេត្តបាត់ដំបង ចូលរួមប្រកួតគ្នាយ៉ាងស្វិតស្វាញអស់រយៈពេលជាងមួយខែ ដើម្បីដណ្តើមពានរង្វាន់លោកអភិបាល អេនរីកេ ហ្វីការ៉េដូ អភិបាលព្រះសហគមន៍កាតូលិកប្រចាំភូមិភាគបាត់ដំបង។

កាលពីថ្ងៃទី០៤ កក្កដា ២០១៦ ជាថ្ងៃប្រកួតផ្តាច់ព្រ័ត្រ ដើម្បីដណ្តើមពានរង្វាន់នេះ គឺនៅវគ្គផ្តាច់ព្រ័ត្រមាន ក្រុមកីឡាករ ៤ក្រុម គឺក្រុមកីឡាករសាលាបញ្ញាសាស្ត្រ ត្រូវប្រកួតដណ្តើមលេខ៣ និងលេខ៤ ជាមួយក្រុមកីឡាករក្រុមបរិស្ថានA ហើយក្រុមកីឡាករកងរាជអាវុធហាត់ខេត្តបាត់ដំបង ត្រូវប្រកួតដណ្តើមលេខ១ និងលេខ២ ជាមួយក្រុមកីឡាករបរិស្ថានB ។

នៅចុងបញ្ចប់ក្រុមកីឡាករកងរាជអាវុធហាត់ ដណ្តើមបានពានរង្វាន់លោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបងក្នុងឆ្នាំ២០១៦នេះ ហើយក្រុមកីឡាករបរិស្ថានB ទទួលបានចំណាត់ថ្នាក់លេខ២ ។

ដោយឡែកលោកអភិបាលអេនរីកេ ហ្វីការ៉េដូ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង បានមានប្រសាសន៍ថា "លោកមានការចាប់អារម្មណ៍ ពោលគឺចាប់តាំងពីពេលរៀបចំការប្រកួតមក លោកមើលឃើញថា ក្រុមនីមួយៗដោយខិតខំប្រឹងប្រែង ហើយមានការសាមគ្គីភាពគ្នាបានល្អណាស់នៅក្នុងការប្រកួត"។ ការប្រកួត ពិតណាស់តែងតែមានអ្នកឈ្នះ និងអ្នកចាញ់ ប៉ុន្តែមិនជាបញ្ហា យើងត្រូវគិតថា ការលេងកីឡាបានជួយឲ្យយើងមានការទំនាក់ទំនងជាមួយគ្នា ជួយយើងឲ្យមានសុខភាពល្អនោះផង។ សម្រាប់ក្រុមមិនបានទទួលជ័យលាភី លោកអភិបាលបានមានប្រសាសន៍ផ្តាំផ្ញើថា "បើទោះបីមិនទទួលលទ្ធផលល្អនៅក្នុងឆ្នាំនេះក្តី ប៉ុន្តែនេះក៏ជាបទពិសោធន៍ថ្មីមួយសម្រាប់ក្រុមខ្លួន"។ ចូរយើងខិតខំប្រឹងប្រែងជាបន្តទៀត ដើម្បីសម្រាប់ការប្រកួតនៅឆ្នាំក្រោយ។ ក្នុងនោះលោកអភិបាលក៏បានថ្លែងអំណរគុណដល់គណកម្មការរៀបចំការប្រកួតបាល់ទាត់ដណ្តើមពានរង្វាន់លោកអភិបាលនាឆ្នាំនេះ ប្រកបទៅដោយជោគជ័យ ហើយយើងនឹងជួបគ្នានៅឆ្នាំក្រោយ ឆ្នាំ ២០១៧ ជាបន្តទៀត។ មានប្រសាសន៍ក្នុងឱកាសនោះដែរ លោក ស្ទេផានូស ជាបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍បាត់ដំបង មានប្រសាសន៍ថា " លោកសូមសម្តែងនូវអំណរគុណចំពោះលោកអភិបាល ក្នុងការគាំទ្រឲ្យមានការរៀបចំកម្មវិធីនេះឡើងជារៀងរាល់ឆ្នាំ"។ លោកមានក្តីរំភើបរីករាយ ចំពោះក្រុមដែលទទួលបានជោគជ័យពីការប្រកួតដណ្តើមពានរង្វាន់លោកអភិបាលឆ្នាំនេះ។ លោកបានផ្តាំផ្ញើថា "ចូរប្អូនៗចូលរួមលេងកីឡាឲ្យបានគ្រប់ៗគ្នា ពីព្រោះកីឡា គឺជាការកសាងទំនាក់ទំនងជាមិត្តភាព ការរួបរួមកម្លាំងសាមគ្គីគ្នា នៅក្នុងក្រុមដែលជួយយើងឲ្យដណ្តើមបានជ័យជំនះ"។

តំណាងគណកម្មការរៀបចំការប្រកួតដណ្តើមពានរង្វាន់ បានមានប្រសាសន៍នៅក្នុងពិធីប្រគល់ពានរង្វាន់លោកអភិបាលនាពេលនោះ ដោយលោកបានលើកឡើងថា "ចំពោះស្ថានភាពទូទៅនៃការប្រកួតដណ្តើមពានរង្វាន់លោកអភិបាលនាឆ្នាំនេះ គឺបានប្រព្រឹត្តិទៅដោយជោគជ័យ បើទោះបីមានការលំបាកបន្តិចបន្តួចក្តី ប៉ុន្តែការប្រកួតគឺមានលក្ខណៈជាមិត្តភាព ដោយក្រុមនីមួយៗ ខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ដោយមានក្រុមកីឡាករ កីឡាការិនីជាច្រើនក្រុមមក ចូលរួមក្នុងកម្មវិធីប្រកួតនាឆ្នាំនេះ"។ លោកបានបន្ថែមបញ្ជាក់ថា ៖ ដោយឆ្លងកាត់ការប្រកួត តាំងពីថ្ងៃបើកការប្រកួតរហូតមកដល់ថ្ងៃនេះយើងមើលឃើញថា ក្រុមកីឡាករនីមួយៗ មានការរីកចម្រើនច្រើនទាំងបច្ចេកទេស និងបទពិសោធន៍នៅក្នុងការប្រកួត ។

គួរបញ្ជាក់ថា ក្រោយពីបញ្ចប់ការប្រកួតជ្រើសរើសគូជើងឯក សម្រាប់ពានរង្វាន់លោកអភិបាលនាឆ្នាំនេះ ក៏មានការចែកពានរង្វាន់ដល់ក្រុមកីឡាករជ័យលាភី ក៏ដូចជាការចែកវត្ថុអនុស្សាវរីយ៍ និងថវិការមួយចំនួនទៀត ទៅដល់ក្រុមកីឡាករមហាជន ក្រុមកុមារអាយុក្រោម១៣ឆ្នាំ និងក្រុមកីឡាការិនី ដែលបានអញ្ជើញមកពីព្រះសហគមន៍នានា នៃភូមិភាគបាត់ដំបង នៅក្រោមបរិយាកាសសប្បាយរីករាយយ៉ាងក្រៃលែង ។

*ដោយ : សម្ផស្ស*

# សាលាដុនបូស្កូប្រគល់វិញ្ញាបនបត្រដល់និស្សិតជំនាន់ទី២២

សាលាបណ្តុះបណ្តាលវិជ្ជាជីវៈដុនបូស្កូផ្នែកនារីបានប្រគល់វិញ្ញាបនបត្រដល់និស្សិតជំនាន់ទី២២ ចំនួន ៧៤នាក់ ធ្វើឡើងនៅវិទ្យាល័យដុនបូស្កូ ស្ថិតនៅផ្លូវន័រប្រ៊ីត សង្កាត់ទឹកថ្លា ខ័ណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ កក្កដា កន្លងទៅ។ បងស្រីអូព្រីនីជាអធិការណីមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈដុនបូស្កូក្នុងខេត្តបាត់ដំបងបានឲ្យដឹងថា ថ្ងៃនេះ គឺជាពេលវេលាកំណត់នៃការចាប់ផ្តើមជីវិតថ្មីមួយរបស់និស្សិតជំនាន់ទី២២។ បងស្រីអូព្រីនីក៏បានបន្ថែមទៀតថា ៖ ចាប់តាំងពីឆ្នាំ១៩៩២ ដល់ឆ្នាំ ២០១៦ គឺមានរយៈពេល២៤ឆ្នាំមកហើយ ដែលមានយុវនារីជាច្រើនបានទទួលបណ្តុះបណ្តាលជំនាញពីមជ្ឈមណ្ឌលនេះ និងបានចូលបម្រើការងារនៅក្នុងប្រទេសកម្ពុជា។ ដូនជីរូបនេះបន្តថា មជ្ឈមណ្ឌលបណ្តុះបណ្តាលដុនបូស្កូផ្នែកនារីនេះ គឺមានមោទនភាពដែលបានចូលរួមចំណែកអប់រំយុវនារីឲ្យក្លាហាន និងទៅជាពលរដ្ឋស្មោះត្រង់ និងសកម្មសម្រាប់ប្រទេសកម្ពុជា។ ក្នុងកម្មវិធីចែកវិញ្ញាបនបត្រនេះ មានការអញ្ជើញចូលរួមពីសំណាក់លោកស្រី ឈាងវីយោឡា ជាប្រធានគ្រប់គ្រងជាន់ខ្ពស់ផ្នែកប្រព័ន្ធធនធានមនុស្ស និងទំនាក់ទំនងនិយោជិកនៃក្រុមហ៊ុនព្រូដិនសល(ខេមបូឌា) ឡាយហ្វ៍អឹស្សួរិនស៍ភីអិលស៊ី, បងស្រីជេស៊ីកាសាលវាញ៉ាជាប្រធាននៃក្រុមបងស្រីសាឡេស៊ានប្រចាំប្រទេសកម្ពុជា និងមីយ៉ានម៉ា, លោក ៉ាម៉ុនហ្វីហ្គារេដូ ជាសមាជិកក្រុមប្រឹក្សាSAUCE (សាអ៊ូសេ), រួមនិងភ្ញៀវជាតិនិងអន្តរជាតិសរុបប្រមាណ ៣០០នាក់។



អ្នកស្រីឈាង វីយោឡា បានមានប្រសាសន៍ទៅកាន់បេក្ខនារីដែលទទួលវិញ្ញាបនបត្រថា ការស្វះស្វែងរកចំណេះដឹងគឺជារឿងដែលយុវនារីត្រូវធ្វើ។ អ្នកស្រីបានឲ្យដឹងទៀតថា អ្នកស្រីបានឆ្លងកាត់ការលំបាកជាច្រើនរួមទាំងការមិនគាំទ្រឲ្យសិក្សាពីសំណាក់អ្នកភូមិ និងក្រុមគ្រួសាររបស់អ្នកស្រីផ្ទាល់ផងដែរ តែអ្វីដែលសំខាន់នោះ គឺអ្នកស្រីផ្តល់តម្លៃលើការសិក្សាជានិច្ចរហូតដល់ទទួលបានជោគជ័យដូចក្នុងពេលបច្ចុប្បន្ននេះ។

ក្នុងឱកាសនោះដែរអ្នកស្រី វីយោឡា បានផ្តាំផ្ញើដល់យុវជនារីទាំងអស់ឲ្យខិតខំអនុវត្តនូវអ្វីដែលសាលាបានអប់រំ។ ក្នុងនោះមាន សីលធម៌ និងចរិយាធម៌ បូករួមទាំងសេចក្តីព្យាយាមដែលយើងមាននៅក្នុងខ្លួន។ លើសពីនេះទៀត លោកស្រីវីយោឡា ក៏សូមឲ្យអាណាព្យាបាលទាំងអស់បន្តជំរុញ និងលើកទឹកចិត្តដល់កូនស្រីឲ្យបានបន្តការសិក្សា និងចូលរួមប្រឡូកក្នុងវិស័យការងារ ដើម្បីឲ្យពួកគេកាន់តែមានអនាគតល្អប្រសើរ និងមានមុខមាត់នៅក្នុងសង្គម។ អង្គុយនៅលើរទេះរុញដៃកាន់វិញ្ញាបនបត្រ យុវតីកើត យុន្នី ជាសិស្សរៀនផ្នែកលេខាធិការនិយាយទាំងទឹកភ្នែកដោយសេចក្តីរំភើបថា "ខ្ញុំមិនដែលគិតសូម្បីតែម្តងថា ខ្ញុំអាចឡើងលើវិទិការដើម្បីទទួលសញ្ញាបត្របែបនេះឡើយ។ ព្រោះថា ខ្ញុំជាជនពិការ ហើយវាពិបាកណាស់ក្នុងការសិក្សា ទាំងការធ្វើដំណើរផ្សេងៗ គឺវាមិនស្រួលដូចគេនោះទេ គ្រប់ពេលគឺត្រូវការមានអ្នកជួយ"។ យុន្នីក៏សូមលើកទឹកចិត្តដល់ជនពិការទាំងអស់ ត្រូវខិតខំតស៊ូ ក្នុងការសិក្សា ទោះបីជាយើងមិនមានអ្វីគ្រប់គ្រាន់ដូចគេ តែយើងជាមនុស្សម្នាក់នៅក្នុងសង្គម និងមានបេះដូងដូចគេ ហេតុនេះការព្យាយាមគង់តែបានសម្រេចនៅពេលណាមួយ។

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈដុនបូស្កូផ្នែកនារីមានបីទីតាំងក្នុងប្រទេសកម្ពុជា។ រីឯនិស្សិតដែលបានបញ្ចប់ការសិក្សាចំនួន៧៤នាក់នោះមកពី ទីតាំងទី១ គឺនៅទួលគោក បណ្តុះបណ្តាលផ្នែកលេខាធិការិនីនិងកុំព្យូទ័រមានចំនួន៤១នាក់។ ទីតាំងទី២នៅទឹកថ្លា បណ្តុះបណ្តាលផ្នែកបច្ចេកវិទ្យាធ្វើម្ហូបអាហារ និងសេវាកម្មសណ្ឋាគារមានចំនួន ២០នាក់។ និងទីតាំងទី៣ គឺនៅខេត្តបាត់ដំបងបណ្តុះបណ្តាលផ្នែកអក្ខរកម្ម និងកាត់ដេរមានចំនួន ១៣នាក់។

*ដោយៈ ស្រីម៉ាច*

# ពិធីបិទឆ្នាំសិក្សា២០១៥-២០១៦ នៃមណ្ឌលនិស្សិតព្រះសហគមន៍កាតូលិកកម្ពុជា



និស្សិតដែលបានទទួលអាហាររូបករណ៍ពីមណ្ឌលនិស្សិតព្រះសហគមន៍កាតូលិកដើម្បីបន្តការសិក្សាតាមបណ្តាសកលវិទ្យាល័យនានាក្នុងទីក្រុងភ្នំពេញ បានរៀបចំពិធីបិទឆ្នាំសិក្សា ២០១៥-២០១៦ ក្រោមអធិបតីភាពលោកអភិបាលព្រះសហគមន៍កាតូលិក អូលីវីយេ ឆ្មឺតអឺស្លែរ។ ពិធីនេះរៀបចំឡើងកាលពីល្ងាចថ្ងៃទី៦ កក្កដា ២០១៦ នៅមណ្ឌលនិស្សិត សង្កាត់បឹងត្របែក ភ្នំពេញ និងមានការចូលរួមយ៉ាងកុះករពីសំណាក់ក្រុមគ្រួសារនិស្សិត និងអតីតនិស្សិត។

លោកម៉ារីយ៉ូ ហ្គេហ្ស៊ី ជាអ្នកសម្របសម្រួលមណ្ឌលនិស្សិតព្រះសហគមន៍កាតូលិកបានមានប្រសាសន៍ថា "បំណងមណ្ឌលនិស្សិតនៅទីនេះ មានការយកចិត្តទុកដាក់ខ្លាំងមែនទែនចំពោះការសិក្សា។ ហើយអ្វីដែលសំខាន់ ជាងនេះទៅទៀតគឺជីវិតខាងផ្លូវវិញ្ញាណ ដែលការអធិដ្ឋានអភិបូជាថ្ងៃអាទិត្យដែលជួយឲ្យនិស្សិតកាតូលិកចូលរួមក្នុងសង្គម ដើម្បីប្រកាសដំណឹងល្អ"។

ក្នុងធម្មទេសនា លោកអភិបាល បានណែនាំនិស្សិតទាំងអស់ ឲ្យរិះគិតអំពីជីវិតរបស់ខ្លួននាពេលអនាគត ដោយលើកយកអនុសាសន៍៣ចំនុចសំខាន់ៗគឺ៖ ១) យកពេលវេលារិះគិតទូទៅអំពីជីវិតសង្គម និងការសិក្សា។ ២) វាយតម្លៃផ្ទាល់ខ្លួនដោយគិតអំពីកំរិតរីកចម្រើននៃទំនាក់ទំនងជាមួយសង្គម និងអស់អ្នកដែលយើងបានបម្រើដើម្បីឲ្យពួកគេមានរីកចម្រើនទាំងកាយ និងវិញ្ញាណ។ ៣) ពិចារណាអំពីអនាគតផ្ទាល់ខ្លួនថា និងក្លាយទៅជាមនុស្សបែបណា?។ ជាងនេះទៅទៀត លោកអភិបាលផ្តាំផ្ញើរទៅនិស្សិតទាំងអស់ថា យើងត្រូវការមានកម្លាំងចិត្តដើម្បីរៀបចំអនាគត និងសង្គម ដោយគិតពីរបៀបនៃការយកចិត្តទុកដាក់ក្នុងជីវិត ដែលនាំឲ្យយើងមានអំណរសប្បាយ។ លោកបន្តថា "ព្រះជាម្ចាស់បានបង្កើតយើងជាមនុស្សឲ្យមានលក្ខណៈដូចព្រះអង្គដោយមានសមត្ថភាព។ ហេតុនេះសូមប្រើសមត្ថភាពដែលយើងមានប៉ុណ្ណា យើងធ្វើប៉ុណ្ណឹងទៅ"។ លោកអូលីវីយេ បន្ថែមថា ព្រះជាម្ចាស់បានជ្រើសរើសយើង ដើម្បីឲ្យសង្គមខ្មែរ និងពិភពលោករីកចម្រើន ដោយបង្កើតសង្គមថ្មី ធ្វើជាមនុស្សថ្មី តាមរបៀបគិតពីផលប្រយោជន៍រួម និងមានព្រះជាម្ចាស់ជាទីពឹង។ ក្រោយពីអភិបូជាក៏មានការចែកនូវវិញ្ញាបនបត្រដល់និស្សិតឆ្នាំទី៤ចំនួន ១៩រូប ដែលត្រូវចាកចេញពីមណ្ឌលនិស្សិត និងបានបញ្ចប់ការសិក្សារបស់ខ្លួនពីសកលវិទ្យាល័យហើយកំពុងបម្រើកិច្ចការងារនៅក្នុងសង្គម។

មណ្ឌលនិស្សិតព្រះសហគមន៍កាតូលិក បានកើតមានឡើងជាំង១០ឆ្នាំមកហើយ។ មណ្ឌលនេះផ្តល់អាហារូបករណ៍ដល់និស្សិតដែលបានប្រឡងជាប់កំរិតមធ្យមសិក្សាទុតិយភូមិ (បាក់ឌុប) និងគ្មានលទ្ធភាពបន្តការសិក្សានៅតាមបណ្តាសកលវិទ្យាល័យនានាក្នុងទីក្រុងភ្នំពេញ។

*ដោយ : ដាលីស*

# លោកបូជាចារ្យ សិលា ឡេ ធឿងឌុង (១៩៤០-១៩៧២)

## Père Pierre LÊ THƯỢNG ĐÚNG

## បូជាចារ្យភូមិភាគកំពង់ចាម



លោកបូជាចារ្យសិលា ឡេ ធឿងឌុង ជាបូជាចារ្យបម្រើនៅភូមិភាគកំពង់ចាម។ លោកកើតនៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៤០ នៅស្រុកបាណាម (អ្នកលឿង)។ ទោះបីជាជនជាតិវៀតណាម លោកបានរៀននៅអនុទេវវិទ្យាល័យសន្តៈយ៉ូសែប ក្នុងសាលានៅភ្នំពេញដែរ។ ឆ្នាំ១៩៦៩ លោកត្រូវបញ្ជូនទៅរៀននៅទេវវិទ្យាល័យធំនៅជ្រោយចង្វារ ហើយទទួលការតែងតាំងជាបូជាចារ្យនៅខែមិថុនា ឆ្នាំ១៩៦៩។ ក្រោយបានតែងតាំងជាលោកបូជាចារ្យ លោកត្រូវបញ្ជូនទៅនៅខ្សាច់ប្រចេស (សព្វថ្ងៃនេះ គឺក្តុលលើ) ខេត្តក្រចេះ នៅឆ្នាំ១៩៧០-១៩៧២ ដើម្បីបន្ថែមចំណេះដឹងភាសាខ្មែរ។

លោកត្រូវបម្រើក្នុងមុខងារជាលោកបូជាចារ្យជំនួយដ៏ប្រសើររបស់លោកវ៉ាប៉ាំង ដែលជាលោកបូជាចារ្យទទួលខុសត្រូវនៅព្រះសហគមន៍ចាប់ពីក្រចេះដល់ស្រុកក្រូចឆ្មារ។ លោកជាមនុស្សស្លូត។ លោកជាមនុស្សខិតខំព្យាយាមណាស់។

ពេលសង្គ្រាមផ្ទុះនៅឆ្នាំ ១៩៧០ លោកមិនភៀសខ្លួនទៅវៀតណាមទេ លោកធ្លាប់និយាយថា "គ្រីស្តបរិស័ទគ្មានសន្តិសុខក៏លោកគ្មានសន្តិសុខដែរ"។ ព្រោះលោកដឹងថា លោកជាបូជាចារ្យសម្រាប់ប្រទេសខ្មែរ ទោះបីក្រុមគ្រួសាររបស់លោកបានភៀសខ្លួនទៅវៀតណាមអស់ហើយក៏ដោយ។ នៅខែមករា ឆ្នាំ១៩៧២ លោកទៅសួរសុខទុក្ខគ្រីស្តបរិស័ទនៅខេត្តក្រចេះ។ មុនត្រូវគេចាប់ លោកជួយរៀបចំបុណ្យអាពាហ៍ពិពាហ៍ឲ្យគ្រីស្តបរិស័ទចំនួន ១៥គូ។

នៅថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៧២ នោះ វេលាម៉ោង ៥ ល្ងាច ពួកទាហានវៀតកុង "អញ្ជើញ" គាត់ទៅជាមួយពួកគេ។ លោកដឹងខ្លួនថា ជីវិតលោកមុខជាអន្តរាយជាពុំខាន ដូច្នេះលោកក៏យកអាវបំពង់របស់បូជាចារ្យមកពាក់។ ពួកវៀតកុងនាំលោកទៅឃុំឃាំងនៅសាលារៀនមួយ រួចយកទៅឃុំក្នុងផ្ទះមួយចម្ងាយប្រហែល ២ គ.ម. នៅខាងជើងទីក្រុង។ មានគ្រីស្តបរិស័ទទៅទាមទារឲ្យពួកទាហានដោះលែងលោក តែឥតបានការអ្វីឡើយ។

នៅថ្ងៃទី១១ មីនា ១៩៧២ ពួកគេនាំលោកទៅទាំងចងស្លាបសេក។ មួយថ្ងៃក្រោយមក ស្ត្រីគ្រីស្តបរិស័ទម្នាក់ ដែលតែងយកចំណីអាហារបន្តិចបន្តួចទៅជូនលោក ឃើញបុរសម្នាក់យកអាវបំពង់ខ្មៅរបស់លោកមកពាក់។ ក៏ប៉ុន្តែបុរសនោះមិនមែនជាលោកឌុងទេ! ប្រហែលជាគេបានសម្លាប់លោកចោល ក្នុងពេលយប់នោះទៅហើយ។

---



សន្តីរ៉ូសា នៅក្រុងលីម៉ា

នាងរ៉ូសាកើតនៅប្រទេសប៉េរូ នៅអាមេរិកខាងត្បូង ឆ្នាំ១៥៨៦។ នាងរ៉ូសាស្រឡាញ់ព្រះយេស៊ូខ្លាំងណាស់នាងតែងតែព្យាយាមជួយមនុស្សទាំងឡាយដោយក្តីអំណរជានិច្ច។ នាងរ៉ូសាជានារីដ៏ស្រស់ស្អាតម្នាក់។

ម្តាយនាងមានបំណងឲ្យនាងស្លៀកសម្លៀកបំពាក់ដ៏ល្អប្រណិត ប៉ុន្តែនាងបានប្រាប់ម្តាយថា "ម៉ែអើយ!មានតែទឹកចិត្តទេដែលមានសារៈសំខាន់"។ មានបុរសអ្នកមានម្នាក់ចង់រៀបការជាមួយនាងរ៉ូសា ដោយសុខចិត្តជូនផ្ទះដ៏ស្កឹមស្កៃមួយព្រមទាំងមានអ្នកបម្រើជាច្រើននាក់ដល់នាង ប៉ុន្តែនាងមិនព្រមទទួលទេ។ នាងស្រឡាញ់តែព្រះយេស៊ូ ហើយចង់បម្រើព្រះម្ចាស់តែមួយព្រះអង្គគត់។ នាងមានប្រសាន៍ថា"មានតែព្រះយេស៊ូទេជាម្ចាស់ចិត្តរបស់នាងខ្ញុំ ហើយមានតែព្រះអង្គទេ ដែលអាចបំពេញចិត្តរបស់នាងខ្ញុំឲ្យបានពេញលក្ខណៈ"។

នៅពេលដែលឪពុកម្តាយធ្លាក់ខ្លួនក្រ នាងរ៉ូសាតែងចេញទៅធ្វើការនៅខាងក្រៅជារៀងរាល់ថ្ងៃ ហើយនៅពេលយប់នាងដេរប៉ាក់ដើម្បីជួយឪពុកម្តាយ។ នាងរ៉ូសាសួរសុខទុក្ខអ្នកក្រីក្រ ហើយផ្តល់អាហារដល់ពួកគេ។ នាងថ្វាយទុក្ខលំបាក និងអំពើល្អទាំងប៉ុន្មានរបស់នាងទៅព្រះជាម្ចាស់ ហើយនាងជួយអង្វរព្រះអង្គសម្រាប់អ្នកបាប។ ពេលខ្លះព្រះជាម្ចាស់បង្ហាញព្រះអង្គ ដូចជាក្មេងម្នាក់ឲ្យនាងឃើញ។ ព្រះអង្គសព្វព្រះហឫទ័យក្នុងកិច្ចការដែលនាងធ្វើ។ នាងរ៉ូសាទទួលមរណភាពនៅអាយុ៣១ឆ្នាំ ទាំងពោលថា "ឱព្រះយេស៊ូអើយ! សូមព្រះអង្គគង់នៅជាមួយនាងខ្ញុំផង"។

---

## កំណាព្យ ម្តេចមិនប្រមាណខ្លួនផង

(បទពាក្យ ៧)



និពន្ធដោយអ្នកស្រី ខុង ណារី,
មន្ត្រីគ្រប់គ្រងកម្មវិធីអប់រំ និងសុខភាពនៃគម្រោងអភិវឌ្ឍន៍ជនបទ
អង្គស្តួល / JSC

១- ជារុក្ខាជាតិនាមសង្កែ
ពូជពង្សមិនខ្ពស់រស់ត្រសុំ
ដុះតាមភ្លឺស្រែក្បែរជើងភ្នំ
ជាព្រិជល្បះភ្នំជុំព្រោងព្រាត។

២- ភ្នំក្មែងព័ទ្ធពង់វង់មិនឆ្ងាយ
ខ្លួនជាល្បះភ្នំមិនចង់ឃ្លាត
ទឹកចិត្តសប្បាយដុះជួបញាតិ
រួមរស់ក្បែរញាតិជាតុដូចគ្នា។

៣- ប្លែកតែសង្កែប្រែប្រាណចិត្ត
ជួបនិងមហន្តរាយកាយវេទនា
ផ្តោះផ្តោងគំនិតឥតគិតគ្រា
ភ្លេចភ្លាំងមួយគ្រាព្រោះលោភលន់។

៤- ឃើញដើមគគីដុះជើងភ្នំ
បក្សាបក្សីទំដោជន់
លូតខ្ពស់ឡើងធំជុំល្អគន់
សមរាងពេកពន់ដើមស្លឹកមែក។

៥- សង្កែក្បែរនោះប្រឹងលូតតាម
យកឈ្នះគគីទីតាំងដេក
គិតថានិងច្បាមឲ្យអនេក
ពពួកសត្វត្រេកត្រអាលខ្លាំង។

៦- គគីរុក្ខាជាតិដើមឈើធំ
មិនថាវស្សារដូវប្រាំង
មានម្លប់ត្រសុំត្រជាក់បាំង
រស់ពេញកម្លាំងសែនសុខក្រៃ។

៧- ខុសតែសង្កែមិនមើលមាឋ
ដើមស្លួចស្លឹកតូចប៉ុនមេដៃ
ប្រឹងលូតបបៀតយកឈ្នះដៃ
គ្មានគិតសំចៃជីវិតខ្លួន។

៨- យប់ថ្ងៃគិតតែលូតបន្ត
មានព្យុះភ្លៀងផ្គរបក់ជួបជូន
ប្រឹងទាំងត្រដឥតដេកពួន
រាងតូចស្រឡូនបោកបាក់អស់។

៩- ម្តេចមិនប្រមាណខ្លួនឯងផង
ជាតុជាល្បះព្រិជជើងភ្នំសោះ
បង្កើតចិត្តប៉ងឥតស្រណោះ
តាំងខ្លួនបង្អោះបង្ហាញរិទ្ធ។

១០- ចុងក្រោយលទ្ធផលជួបគ្រោះភ័យ
មិនទទួលស្គាល់សារជាតុពិត
ព្យុះវាយធ្លាក់ដីគ្មានអាណិត
ខ្លួននេះអាតិតកើតពីអ្វី។

# អង្គការការីតាស់កម្ពុជាចុះអនុស្សរណៈ យោគយល់ជាមួយអគ្គនាយកដ្ឋានពន្ធនាគារ

អង្គការការីតាស់កម្ពុជាកាលពី ព្រឹកថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៦នេះ បានចុះអនុស្សរណៈយោគយល់ ស្តីពីគម្រោងសេវាសុខភាព និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងពន្ធនាគារជាមួយអគ្គនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ។

ពិធីចុះហត្ថលេខាបានធ្វើឡើងនៅទីស្តីការក្រសួងមហាផ្ទៃ ដោយមានការអញ្ជើញចូលរួមពីសំណាក់លោកគីម រតនា នាយកប្រតិបត្តិអង្គការការីតាស់ប្រចាំនៅកម្ពុជា រួមជាមួយឯកឧត្តមអគ្គនាយរក្សថ្នាក់លេខ១ ចាន់ គឹមសេង អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ។

លោកគីម រតនា នាយកប្រតិបត្តិអង្គការការីតាស់កម្ពុជា បានឲ្យដឹងថា ៖ គម្រោងនៃកិច្ចព្រមព្រៀងរវាងអង្គការការីតាស់កម្ពុជា ជាមួយអគ្គនាយកដ្ឋានពន្ធនាគារ មានឈ្មោះថា គម្រោងសេវាសុខភាពពន្ធនាគារដោយរួមបញ្ចូលនូវការបណ្តុះបណ្តាលវិជ្ជាជីវៈដល់អ្នកជាប់ពន្ធនាគារនៅក្នុងប្រទេសកម្ពុជា។ គម្រោងនេះមានរយៈពេល៣ឆ្នាំ គឺគិតចាប់តាំងពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៦ រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩ ខាងមុខនេះ ដែលប្រើប្រាស់ថវិកាប្រមាណជាង ២០ម៉ឺនដុល្លារអាមេរិក។



ថតដោយ: អង្គការការីតាស់

លោកបន្តថា ទីតាំងអនុវត្តន៍គម្រោងនៅក្នុងកិច្ចព្រមព្រៀងសហការគ្នានេះ គឺត្រូវអនុវត្តន៍ដោយគ្របដណ្តប់ទៅលើមណ្ឌលអប់រំកែប្រែទី៤ (ម៤) នៅក្នុងខេត្តពោធិ៍សាត់ និងពន្ធនាគារនៅតាមខេត្តចំនួន៨ផ្សេងទៀតរួមមាន ៖ ពន្ធ-នាគារខេត្តសៀមរាប ខេត្តព្រះវិហារ ខេត្តកំពង់ធំ ខេត្តមណ្ឌលគីរី ខេត្តរតនគីរី ខេត្តក្រចេះ ខេត្តស្ទឹងត្រែង និងខេត្តប៉ៃលិន។ កិច្ចសហការនេះ គឺសម្រាប់ជួយដល់ទណ្ឌិត ដែលកំពុងជាប់ក្នុងពន្ធនាគារទាំងនោះ នូវការផ្តល់សេវាសុខភាពព្រមទាំងគម្រោងបណ្តុះបណ្តាលវិជ្ជា-ជីវៈសម្រាប់ពួកគេផងដែរ។

លោកបានបញ្ជាក់ថា គម្រោងនេះមានគោលបំណងពង្រឹងនិរន្តភាពនៃកម្មវិធីប៉ុស្តិ៍សុខភាព ដែលមានហេដ្ឋារចនា-សម្ព័ន្ធ ស្របតាមបទដ្ឋានរបស់ក្រសួងសុខាភិបាល ដូចជា ឱសថ សម្ភារៈបរិក្ខារពេទ្យ និងប្រព័ន្ធបញ្ជូន ដើម្បីផ្តល់សេវាកម្មថែទាំគ្រប់ជ្រុងជ្រោយ រួមមានសុខភាពផ្លូវកាយ និងសុខភាពផ្លូវចិត្តរបស់ជនជាប់ឃុំ ក្នុងមណ្ឌលអប់រំកែប្រែទី៤ (ម៤) នៃខេត្តពោធិ៍សាត់ ខេត្តសៀមរាប ខេត្តព្រះវិហារ ខេត្តកំពង់ធំ ខេត្តមណ្ឌលគីរី ខេត្តរតនគីរី ខេត្តក្រចេះ ខេត្តស្ទឹងត្រែង និងពន្ធនាគារខេត្តប៉ៃលិន តាមរយៈការផ្តល់សេវាសុខភាពប្រកបទៅដោយគុណភាព ប្រសិទ្ធភាព ក្រោមកិច្ចសហប្រតិបត្តិការពីគ្រប់ភាគីពាក់ព័ន្ធនានាដែលទាក់ទងកម្មវិធីពន្ធនាគារ ។

លោកបន្តថា អង្គការការីតាស់ក៏ផ្តល់មធ្យោបាយថែទាំបន្ត ដើម្បីទទួលការព្យាបាលពេញលេញ ក្រោយពេលដោះលែងពីពន្ធនាគារ តាមរយៈការទំនាក់ទំនងជាមួយមន្ទីរពេទ្យបង្អែកខេត្ត និងមណ្ឌលសុខភាព ព្រមទាំងអប់រំផ្សព្វផ្សាយបង្ការទប់ស្កាត់អំពីផលប៉ះពាល់រាល់ការប្រើប្រាស់គ្រឿងញៀន និងអប់រំឲ្យមានការផ្លាស់ប្តូរឥរិយាបទ លុបបំបាត់ការរើសអើងចំពោះអ្នកជម្ងឺរបេង អ្នកផ្ទុកមេរោគអេដស៍ ។

អង្គការការីតាសកម្ពុជាជាអង្គការមួយនៅក្នុងរចនាសម្ពន្ធរបស់ព្រះសហគមន៍កាតូលិកនៅកម្ពុជាដែលកំពុងមានសកម្មភាពនៅខេត្តចំនួន១៣ដោយអនុវត្តលើគម្រោងកម្មវិធីអភិវឌ្ឍន៍សហគមន៍ ជាច្រើនដូចជា៖ កម្មវិធីសុខភាព កសិកម្ម អប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ កម្មវិធីសម្រាប់ពន្ធនាគារ កម្មវិធីចំណាកស្រុក និងគ្រប់គ្រងគ្រោះមហន្តរាយធម្មជាតិនានា។ល។ ៕

*ដោយ : ឡុង សម្ផស្ស*

# យើងជឿលើព្រះយេស៊ូ ព្រះអង្គនាំយើងឲ្យមានសេចក្តីសង្ឃឹម

"អ្វីៗដែលយើងមាន យើងត្រូវអរព្រះគុណព្រះជាម្ចាស់ ដែលជាអ្នកណែនាំយើង ឱ្យក្លាយទៅជាលោកអភិបាល លោកបូជាចារ្យ បងប្រុស បងស្រី ដែលព្រះជាម្ចាស់ត្រាស់ហៅឲ្យបំរើព្រះសហ-គមន៍ និងបំរើបងប្អូន"។

លោកអភិបាលអេនរីគែ ហ្វីការ៉េដូ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង មានប្រសាសន៍ដូចនេះនៅក្នុងពិធីថ្វាយអភិបូជាអរព្រះគុណព្រះជាម្ចាស់រំលឹកខួបលើកទី១៦ឆ្នាំ នៃការទទួលតែងតាំងជាអភិបាលព្រះសហគមន៍ សម្រាប់ភូមិភាគបាត់ដំបង កាលពីថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០០០ កន្លងមក ។

ពិធីថ្វាយអភិបូជានេះបានរៀបចំឡើងនៅព្រះវិហារព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ នៃព្រះសហ-គមន៍កាតូលិកខេត្តបាត់ដំបង មានការអញ្ជើញចូលរួមពីសំណាក់លោកអភិបាលអេនរីគែ ហ្វីការ៉េដូ លោកបូជាចារ្យក្នុងភូមិភាគបាត់ដំបង បងប្រុសបងស្រី រួមជាមួយបងប្អូនគ្រីស្តបរិស័ទដែលមកពីព្រះសហគមន៍នានាយ៉ាងច្រើនកុះករ។

ថ្លែងនៅក្នុងធម្មទេសនា នាឱកាសនោះលោកអភិបាលអេនរីកេ បានមានប្រសាសន៍ថា នៅក្នុងអត្ថន័យ នៃព្រះគម្ពីរនាថ្ងៃនេះ បានណែនាំយើងឲ្យមើលឃើញថា ព្រះយេស៊ូ ព្រះអង្គបានប្រកាសដំណឹងល្អ ដើម្បីឲ្យយើងមានសេចក្តីសង្ឃឹមពេល គឺនៅពេលយើងជឿលើព្រះយេស៊ូ គឺព្រះអង្គបានធ្វើឲ្យយើងទាំងអស់គ្នាមានសេចក្តីឡើងវិញ ។

លោកបានបន្តថា នរណាមានជំនឿលើព្រះយេស៊ូ គឺជាអ្នកដែលនាំយកព្រះយេស៊ូដាក់នៅជាប់ដួងចិត្ត និងក្នុងជីវិតរបស់យើង។ នៅពេលយើងនៅជាប់ព្រះយេស៊ូ គឺយើងផ្ញើជីវិតលើព្រះអង្គជា-និច្ច។ យើងត្រូវអរព្រះគុណព្រះជាម្ចាស់ដោយយើងមាន ព្រះយេស៊ូគង់នៅជាមួយយើង ។

លោកអភិបាលបានបញ្ជាក់ថា ជារៀងរាល់ថ្ងៃក្នុងជីវិតរបស់យើង យើងត្រូវធ្វើដំណើរ ជាមួយដំណាក់កាលនីមួយៗ ដោយបោះជំហានទៅមុខដែលជួយណែនាំឲ្យអ្នកដទៃបានស្គាល់ព្រះជាម្ចាស់។


ថតដោយ: វណ្ណា

ជាចុងក្រោយលោកអភិបាលបានសង្កត់ធ្ងន់ថា៖ អ្វីៗទាំងអស់ដែលយើងមានរហូតមកដល់ពេលនេះ គឺយើងមានដោយសារតែយើងមានធនធានមនុស្សជាពិសេសបងប្អូនគ្រីស្តបរិស័ទកាលពីសម័យដើម ដែលបានបន្ត និងចម្លងជំនឿ និងបានធ្វើជាគំរូសម្រាប់យើងរហូតមកដល់ពេលនេះ។ នៅក្នុងព្រះសហគមន៍ ការអប់រំ បន្តជំនឿ តាមរយៈការអធិដ្ឋាន និងការរួបរួមគ្នានាំឲ្យយើងឲ្យរួមចិត្តគំនិតជាមួយគ្នាដើរតាមព្រះយេស៊ូជារៀងរហូត។

សូមបញ្ជាក់ថា៖ នៅក្នុងពិធីអរព្រះគុណព្រះជាម្ចាស់រំលឹកខួបលើកទី១៦ឆ្នាំ នៃការតែងតាំងជាអភិបាលរបស់លោកអេនរីកេ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង ក៏មានការរំលឹកខួបគម្រប់២១ឆ្នាំ នៃការតែងតាំងជាបូជាចារ្យរបស់លោកបូជាចារ្យ ទម្លាប់ សុផល ផងដែរ។ ក្នុងពិធីនោះក៏មានការជូនផ្កាជូនវត្ថុអនុស្សាវរីយ៍ និងសារជូនពរ ចំពោះលោកអភិបាល លោកបូជាចារ្យ ដែលបានប្រារព្ធខួបផ្សេងៗក្នុងខែនេះ។៕

*ដោយ សម្ផស្ស*

# ត្រីស្តបរិស័ទ៩នាក់ ទទួលអគ្គសញ្ញាលាបថ្ងាស នៅព្រះវិហារព្រះយេស៊ូសង្គ្រោះមនុស្សលោក



បេក្ខជន បេក្ខនារីចំនួន ៩នាក់ បានទទួលអគ្គសញ្ញាលាបថ្ងាស ដែលបញ្ជាក់បន្ថែមថាគេជាគ្រីស្តបរិស័ទពេញលក្ខណៈ និងទទួលព្រះវិញ្ញាណដ៏វិសុទ្ធ ដែលផ្តល់ជាកម្លាំងក្នុងការចេញទៅប្រកាសដំណឹងល្អ។ ពិធីនេះប្រារព្ធទៅកាលពីថ្ងៃទី១៧ កក្កដា ២០១៦ នៅព្រះវិហារព្រះយេស៊ូសង្គ្រោះមនុស្សលោក នៃមណ្ឌលសកម្មភាពតាខ្មៅ ក្នុងឃុំអំពៅព្រៃ ខេត្តកណ្តាល ដោយមានលោក អូលីវីយេ ឆ្មីតអឺស្លែរ អភិបាលព្រះសហគមន៍កាតូលិកភ្នំពេញ ជាជាអ្នកផ្តល់អគ្គសញ្ញា និងមានបងប្អូនគ្រីស្តបរិស័ទចូលរួមចំនួនជាច្រើនកុះករ។

ព្រះសហគមន៍ព្រះយេស៊ូសង្គ្រោះមនុស្សលោកជាព្រះសហគមន៍កាតូលិកថ្មីមួយ ដែលមានកើតឡើងប៉ុន្មានឆ្នាំចុងក្រោយនេះមានគ្រីស្តបរិស័ទទើបជ្រមុជទឹកថ្មីតិចតួចភាគច្រើន គឺជាយុវជនយុវនារី។ ទោះបីជាព្រះសហគមន៍នេះថ្មីតែមានជីវិតរស់រវើក ក្នុងការបម្រើបងប្អូនអ្នកក្រីក្រ និងចាស់ជរា។ មួយរយៈពេលចុងក្រោយនេះមានយុជន កុមារ និងមនុស្សពេញវ័យជាច្រើនចេញចូលដើម្បីស្គាល់ព្រះសហគមន៍ និងមកទទួលការអប់រំជំនឿ អំពីព្រះយេស៊ូដែរ។

នៅក្នុងធម្មទេសនា លោកអូលីវីយេ បានមានប្រសាសន៍ជំរុញឲ្យបេក្ខជន និងគ្រីស្តបរិស័ទឲ្យចេះទទួលស្វាគមន៍ព្រះយេស៊ូនៅក្នុងជីវិតរបស់យើង ដោយធ្វើតាមព្រះបន្ទូល អធិដ្ឋាន មានក្តីចិត្តស្រឡាញ់អ្នកឯទៀត ចេះលើកលែងទោស និងមានចិត្តបរិសុទ្ធ។ ជាងនេះទៅទៀតលោកបានសុំឲ្យទទួលស្វាគមន៍អ្នកតូចតាច និងសូមអង្វរព្រះវិញ្ញាណដ៏វិសុទ្ធបន្ថែមជំនឿ និងជួយបំភ្លឺថែមទៀត ដើម្បីឲ្យមានកម្លាំង និងដើម្បីបម្រើព្រះសហគមន៍ ក៏ដូចជាមប្រើអ្នកតូចតាចតាមរយៈសកម្មភាពមេត្តាករុណា។

បន្ទប់ពីធម្មទេសនាលោកអភិបាលបានសួរបញ្ជាក់អំពីជំនឿរបស់បេក្ខជនចំពោះព្រះជាម្ចាស់នៅក្នុងពិធីទទួលអគ្គសញ្ញាលាបថ្ងាស និងប្រកាសជំនឿរួមជាមួយគ្រីស្តបរិស័ទទាំងអស់ រួចទូលអង្វរព្រះជាម្ចាស់រួមជាមួយសន្តបុគ្គលទាំងអស់ដើម្បីសូមព្រះវិញ្ញាណយាងមកគង់សណ្ឋិតជាមួយ បេក្ខជនទាំងនោះ បីឲ្យពួកគេទទួលបានផលផ្លែនៃព្រះវិញ្ញាណ គឺ ១) មានប្រាជ្ញាឈ្លាសវៃ។ ២) ដឹងខុសដឹងត្រូវ។ ៣) ដឹងអំពីសេចក្តីពិត។ ៤) មានយោបល់ល្អ។ ៥) មានសេចក្តីអង់អាច។ ៦) ប្រព្រឹត្តតាមការណែនាំរបស់ព្រះវិញ្ញាណ។ និង៧) ចេះគោរពកោតខ្លាចព្រះបិតា។ បន្ទាប់មកបេក្ខជនទាំងអស់បានទទួលអគ្គសញ្ញាលាបថ្ងាសដែលដោប្រេងជាសញ្ញាឈើឆ្កាងដោយលោកអភិបាលព្រះសហគមន៍ព្រមជាមួយពាក្យ "ខ្ញុំដៅអ្នកដោយព្រះវិញ្ញាណ ដែលជាអំណោយទាននៃព្រះជាម្ចាស់! សូមអញ្ជើញទៅឲ្យបានសុខសាន្ត"។ លោកពោលបែបនេះបង្ហាញថា បេក្ខជនអាចចេញទៅប្រកាសដំណឹងល្អ ដែលបំភ្លឺដោយព្រះវិញ្ញាណដ៏វិសុទ្ធ។

លោកម៉ារីយ៉ូ ហ្គេហ្ស៊ី ជាអ្នកទទួលខុសត្រូវមណ្ឌលសកម្មភាពតាខ្មៅ បានឲ្យដឹងថា៖ បេក្ខជន បេក្ខនារីដែលទទួលអគ្គសញ្ញាទាំងនេះបានចាប់អារម្មណ៍ និងទទួលការអប់រំជំនឿជាច្រើនឆ្នាំ។ ពួកគេក៏សកម្មក្នុងកិច្ចការព្រះសហគមន៍ និងឈ្វេងយល់អំពីជំនឿរបស់ខ្លួន។

លោកថា អ្នកទាំងនេះ បានធ្វើ ឲ្យព្រះសហគមន៍ មានកម្លាំងមួយយ៉ាងពិសេស ក្នុងបន្តសកម្មភាពមេត្តាករុណានានាដល់អ្នកភូមិ។ លោកបូជាចារ្យបន្តថា តាមរយៈគ្រីស្តបរិស័ទថ្មីទាំង៩នាក់រួមជាមួយគ្រីស្តបរិស័ទដែលមានគ្នា៦នាក់ផ្សេងទៀត ព្រះសហគមន៍អាចបង្កើតគណៈកម្មការបាន មានដូចជា គណៈកម្មការសង្គហៈ គណៈកម្មការអប់រំជំនឿ និង គណៈកម្មការពិធីបុណ្យ។

បេក្ខនារី ផល្លា សុខចាន់ ជាប្រធានក្រុមយុវជន បាននិយាយពោពេញដោយជំនឿថា នាងជឿថាអគ្គសញ្ញាលាបថ្ងាសបានធ្វើឲ្យនាងទៅជាគ្រីស្តបរិស័ទយ៉ាងពេញលេញ ដោយមានព្រះវិញ្ញាណដ៏វិសុទ្ធគង់នៅជាមួយ ដើម្បីផ្តល់កម្លាំង។

សុខចាន់ បន្តថា៖ "ខ្ញុំមានជំនឿថាព្រះវិញ្ញាណដ៏វិសុទ្ធនេះ នឹងផ្តល់កម្លាំងនិងសេចក្តីក្លាហានដល់ខ្ញុំ ក្នុងកិច្ចការ ធម៌មេត្តាករុណានៃគណៈកម្មការសង្គហៈដែលទើបតែបង្កើតថ្មីនេះ។ *ដាលីស*

# យុវជនកម្ពុជា៣៧នាក់ចូលរួមទិវាយុវជនពិភពលោក២០១៦ នៅប្រទេសប៉ូឡូញ

តំណាងយុវជន យុវនារីទាំងបីភូមិភាគនៃព្រះសហគមន៍កាតូលិកកម្ពុជាចំនួន ៣៧ នាក់ បានចាកចេញពីមាតុភូមិកាលពីថ្ងៃ១៨ កក្កដា ២០១៦ ដើម្បីចូលរួមទិវាយុវជនពិភពលោក២០១៦ នៅប្រទេសប៉ូឡូញ។

ក្នុងមួយសប្តាហ៍ដំបូងនៅក្នុងប្រទេសប៉ូឡូញ យុវជនកាតូលិកម្ពុជា បានធ្វើបូជនីយេស៍ទៅកាន់ទីសក្ការៈ នៅភូមិភាគគៀលសេប្រទេសប៉ូឡូញ ដោយថ្មើរជើងអមដោយឈើឆ្កាង និងទង់ជាតិកម្ពុជា។ បូជនីយេស៍នេះធ្វើឡើង កាលពីថ្ងៃទី២១ កក្កដា មុននឹងចូលរួមកម្មវិធីជាមួយយុវជន ១០ប្រទេសផ្សេងទៀត។

បន្ទាប់ពីបូជនីយេស៍ យុវជនទាំងអស់បានចែករំលែកបទពិសោធន៍ និងជំនឿទៅវិញទៅមក ហើយក៏ជាឱកាសមួយដើម្បីឲ្យយុវជនកម្ពុជាធ្វើបទបង្ហាញឲ្យយុវជនដទៃទៀតស្គាល់ពីប្រទេសកម្ពុជា និងប្រពៃណីខ្មែរផងដែរ។

យុវជនកម្ពុជាបានធ្វើទស្សនកិច្ច នៅមណ្ឌលចាស់ជរា ជនពិការ និងជីព្រះពរ នៅភូមិភាគគៀលសេប្រទេសប៉ូឡូញ នៅថ្ងៃទី២២កក្កដា២០១៦។

នៅថ្ងៃទី២៣ កក្កដា យុវជនមកពីបណ្តាប្រទេសផ្សេងៗ បានចូលរួមជាមួយគ្នានៅភូមិភាគគៀលសេដដែល និងមានកម្មវិធីរិះគិតរួមជាមួយគ្នាអំពីជំនឿមុននឹងចាកចេញទៅកាន់ទីក្រុងក្រាកាវ ជាទីកន្លែងជួបជុំយុវជនក្នុងទិវាយុវជនពិភពលោក។ ក្នុងការស្នាក់នៅយុវជនកាតូលិកកម្ពុជាក៏មានឱកាសបានស្នាក់នៅ និងរៀនពីគ្រួសារមួយចំនួននៅទីក្រុងនេះដែរ។ ទិវាយុវជនពិភពលោក ២០១៦ មានសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ ធ្វើជាអធិបតី។ លោក និងអញ្ជើញទៅដល់ប្រទេសប៉ូឡូញ ថ្ងៃទី២៦ ហើយស្នាក់នៅ និងជួបជាមួយយុវជន ដែលបានមកពីជុំវិញពិភពលោក រហូតដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៦។

ក្នុងរយៈពេលនេះតាមកម្មវិធីលោកនឹងជួបយុវជនយុវនារីដែលគេបានប៉ាន់ប្រមាណថា មានចំនួនប្រមាណជា ២ លាននាក់ មកពីគ្រប់ទ្វីបក្នុងពិភពលោកទាំងមូល ព្រមទាំងជួបជាមួយថ្នាក់ដឹកនាំប្រទេសប៉ូឡូញ និងថ្នាក់ដឹកនាំព្រះសហគមន៍ផងដែរ។ ក្នុងសប្តាហ៍នេះយុវជនទាំងអស់នឹងជួបសម្តេចប៉ាប។ ទទួលការអប់រំជំនឿតាមតំបន់ តាមភាសារ និងមានកម្មវិធីជាច្រើនទៀ។ *ដាលីស*



## នាយករដ្ឋមន្ត្រីកម្ពុជាប្រកាសដំណើរចុះសាកសួរសុខទុក្ខពលរដ្ឋ២៥ខេត្តរាជធានី

ប្រមុខរដ្ឋាភិបាលកម្ពុជា កាលពីថ្ងៃទី២០ ខែកក្កដា បានប្រកាសតាមបណ្តាញសង្គមជាផ្លូវការរបស់ខ្លួនថា និងចុះសាកសួរសុខទុក្ខប្រជាពលរដ្ឋ មន្ត្រីរាជការកងកម្លាំងប្រដាប់អាវុធទាំង ២៥ ខេត្តរាជធានី។ ការប្រកាសនេះត្រូវបានធ្វើឡើងក្រោយពេលដែល សម្តេចតេជោ ហ៊ុន សែន បានចុះទៅសាកសួរសុខទុក្ខប្រជាពលរដ្ឋតាមបណ្តោយផ្លូវជាតិលេខ ៥ នៅក្នុងដំណើរចុះទៅសម្ពោធសមិទ្ធផលមួយថ្មីនៅក្នុងខេត្តបាត់ដំបង។

បន្ទាប់ពីបានចុះជួបជាមួយនឹងប្រជាពលរដ្ឋ នៅក្នុងផ្សារនៅផ្សារសាមគ្គីក្រគរ នៅខេត្តពោធិសាត់ និងបានទទួលទានអាហារពេលព្រឹកនៅក្នុងផ្សារនោះ សម្តេចតេជោ ហ៊ុន សែន បានចុះជួបសិស្ស នៅសាលានៅអនុវិទ្យាល័យមោង ឬស្សី ក្នុងស្រុកមោងឬស្សី ខេត្តបាត់ដំបង ហើយក៏បានជួបសំណេះសំណាលជាមួយនឹងមន្ត្រីរាជការនៅសាលាខេត្តបាត់ដំបង។ ហើយនៅពេលល្ងាចក៏បានជួបជុំ និងប្រជាពលរដ្ឋមួយចំនួនរួមទាំងបានទទួលទានពេលល្ងាចជាមួយពួកគេ ក្រោយពីពួកគេសំណូមពរជួបសម្តេចតាមរយៈការបញ្ចេញយោបល់តាមបណ្តាញសង្គមហ្វេសបុក ។

សម្តេចតេជោ ហ៊ុន សែន បានប្រកាសថា នៅក្នុងដំណើរមកខេត្តបាត់ដំបងលើកនេះ សម្តេចនឹងបន្តចុះសាកសួរសុខទុក្ខ ប្រជាពលរដ្ឋនៅខេត្តជុំវិញបឹងទន្លេសាប ដែលរួមមាន បន្ទាយមានជ័យ សៀមរាប និងកំពង់ធំ ។

នេះ មិនមែនជាដំណើរចុះសាកសួរសុខទុក្ខប្រជាពលរដ្ឋតំបូងនោះទេ កន្លងមក សម្តេចបានចុះដោយផ្ទាល់បែបនេះនៅខេត្តកំពត និងព្រះសីហនុ នៅក្នុងដំណើរតាមរទេះភ្លើងរួចហើយផងដែរ។

## ឧបការីក្រសួងការបរទេសអាមេរិក ចង់ឲ្យមានបរិយាកាសប្រសើរមុនបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ឆ្នាំក្រោយ

លោក ថុម ម៉ាលីណូវស្គី ឧបការីរដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក ទទួលបន្ទុកលទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងការងារបានមកបំពេញទស្សនៈកិច្ចនៅកម្ពុជា ដោយផ្តោតសំខាន់នៅលើការពង្រឹងលទ្ធិប្រជាធិបតេយ្យ។

នៅក្នុងដំណើរទស្សនៈកិច្ចរយៈពេល ២ថ្ងៃ ពីថ្ងៃទី១៨-១៩ ខែកក្កដា លោកឧបការីបានជួបជាមួយនឹងអ្នកនយោបាយ សង្គមស៊ីវិលក៏ដូចជា យុវជន និងមន្ត្រីរដ្ឋាភិបាលនៅកម្ពុជាមួយចំនួន។

មានប្រសាសន៍ទៅកាន់អ្នកសារព័ត៌មាននៅស្ថានទូតអាមេរិក លោកបានសង្កត់ធ្ងន់ថា ដំណើររបស់លោកមកកម្ពុជាលើកនេះ គឺដើម្បីជំរុញឲ្យមានបរិយាកាសប្រសើរមួយនៃលទ្ធិប្រជាធិបតីនៅកម្ពុជា ជាពិសេស គឺបរិយាកាសមុនការបោះឆ្នោតខាងមុខនេះ។

នៅក្នុងឱកាសនោះ លោកបានសង្កត់ធ្ងន់ និងបានទទួចឲ្យអាជ្ញាធរទម្លាក់ចោលបទចោទទាំងឡាយប្រឆាំងនឹងសកម្មជនសិទ្ធិមនុស្សអង្គការអាដហុក (ADHO C) និងលោក នី ចរិយា អគ្គលេខាធិការរង គ.ជ.ប ហើយបានជំរុញឱ្យអាជ្ញាធរស៊ើបអង្កេតដោយត្រឹមត្រូវ និងប្រកបដោយការជឿទុកចិត្តទៅលើឃាតកម្មលើលោកបណ្ឌិត កែម ឡី។

ឆ្លើយតបនឹងកង្វល់នៃបញ្ហានេះ លោក អ៊ុច បូររិទ្ធ រដ្ឋលេខាធិការក្រសួងការបរទេស បានអះអាងថា ពាក់ពន្ធ័នឹងការចាប់ឃុំឃាំងសកម្មជន សិទ្ធិមនុស្ស ហើយនិងសមាជិកសភារបស់គណបក្សសង្គ្រោះជាតិជាបញ្ហារបស់បុគ្គលដែលប្រព្រឹត្តខុសឆ្គងបំពានច្បាប់ ពុំមែនជាការប្រព្រឹត្តរបស់គណបក្ស ឬក៏របស់អង្គការក្រៅរដ្ឋាភិបាលទេ។

វិធានការដែលរដ្ឋាភិបាលបានអនុវត្តន៍ គឺអនុលោមទៅតាមច្បាប់ជាធរមានដែលមាននៅក្នុងប្រទេសកម្ពុជា។

ឯកឧត្តមបានបន្ថែមទៀតថា ជាការពិតរដ្ឋាភិបាលកម្ពុជា បានប្តេជ្ញាចិត្តអនុវត្តន៍ គោលនយោបាយតាមប្រព័ន្ធលទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស នៅក្នុងក្របខ័ណ្ឌច្បាប់ នេះបើតាមសេចក្តីប្រកាសពីក្រសួងដែលប្រកាសក្រោយជំនួបរវាលោក ថុម ម៉ាលីណូវស្គី និងលោក អ៊ុច បូររិទ្ធ។

## រដ្ឋាភិបាលតួកគីកំពុងតែអនុវត្តវិធានការក្តៅក្រោយរដ្ឋប្រហារយោធាបរាជ័យ

ក្រោយរដ្ឋប្រហារយោធាកាលពីពាក់កណ្តាលខែកក្កដា បានបរាជ័យក្រោមការគាំទ្រពីប្រជាពលរដ្ឋ រដ្ឋាភិបាលតួកគីកំពុងតែអនុវត្តវិធានការក្តៅ នៅក្នុងការខិតខំបោសសំអាត ឫសគល់នៃរដ្ឋប្រហារ។

មិនត្រឹមតែកងកម្លាំងប្រដាប់អាវុធដែលចូលរួមនៅក្នុងរដ្ឋប្រហារនោះទេ ដែលកំពុងតែមានទោស សូម្បីតែចៅក្រមរហូតដល់គ្រូបង្រៀន នៅតាមសាលា តាមសាកលវិទ្យាល័យក៏កំពុងតែជាប់សង្ស័យ និងមានទោសផងដែរជុំវិញរដ្ឋប្រហារ។

តាមប្រភពពីបណ្តាញព័ត៌មានបរទេស បានឲ្យដឹងថា តួកគីបានបញ្ឈរជើងគ្រូបង្រៀន និងសាស្ត្រាចារ្យជាង ១៥.២០០ នាក់ក្រោយរដ្ឋប្រហារ។

ពួកគេត្រូវបានចោទប្រកាន់ថា មានទំនាក់ទំនងជាមួយបុព្វជិតរត់ចោលស្រុក លោក ហ្វេធូឡាស ហ្គូឡិន ដែលអាជ្ញាធរនៅក្នុងប្រទេសនេះ ចោទប្រកាន់ថា ជាមេក្លោងរៀបចំឲ្យមានរដ្ឋប្រហារនេះ ។

ប្រព័ន្ធផ្សព្វផ្សាយរដ្ឋបាននិយាយថា ព្រឹទ្ធបុរសសាកលវិទ្យាល័យជាង១.៥០០ នាក់ ក៏ត្រូវបានបង្គាប់ឱ្យចុះចេញពីតំណែង ដោយក្រុមប្រឹក្សាអប់រំកម្រិតខ្ពស់របស់តួកគីដែរ។

រដ្ឋប្រហារនេះ បានសម្លាប់មនុស្សប្រមាណជា ៣០០នាក់ ១.៤០០ នាក់បានរងរបួស ខណៈដែលទាហានជិត ២០.០០០ នាក់ត្រូវបានបញ្ឈរជើង ឬចាប់ឃុំខ្លួន៕

## ស្វីសបន្តជួយគាំទ្រដំណើរការមន្ទីរពេទ្យគន្ធបុប្ផា ខណៈរដ្ឋាភិបាល កម្ពុជាសម្រេចកាត់លុយ ២ដុល្លារពីភ្ញៀវទេសចរបរទេសចូលអង្គរ

មន្ត្រីរដ្ឋាភិបាលស្វីសបានប្រកាសពីការសន្យាបន្តជួយគាំទ្រដំណើរការមន្ទីរពេទ្យគន្ធបុប្ផាបន្តទៀត ខណៈដែលមន្ត្រីកម្ពុជា បានប្រកាសថា រដ្ឋាភិបាលកម្ពុជានឹងកាត់លុយចំនួន ២ ដុល្លារពីភ្ញៀវទេសចរបរទេសដែលបានចំណាយចូលទៅទស្សនាប្រាសាទអង្គរវត្ត ដើម្បីជួយរួមចំណែកជានិរន្តរភាពមន្ទីរពេទ្យនេះ។ ព័ត៌មាននេះត្រូវបានគេដឹងថា បានបំភ្លឺឡើងនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ និងចុះអនុស្សារណៈនៃការយោគយល់គ្នាស្តីពីកិច្ចព្រមព្រៀងពិគ្រោះយោបល់ទ្វេភាគីប្រចាំឆ្នាំរវាង លោក អ៊ុច បូររិទ្ធ រដ្ឋលេខាធិការក្រសួងការទេសជាមួយលោក ដូ ហាណេស ម៉ាធីយ៉ាស៊ី ឧបការីក្រសួងការបរទេសស្វីស កាលពីព្រឹកថ្ងៃទី២០ កក្កដា ២០១៦ នៅទីស្តីការក្រសួងការបរទេស។

លោក ដូ បានបញ្ជាក់ថា ប្រទេសស្វីសនៅតែបន្តជួយដល់មន្ទីរពេទ្យគន្ធបុប្ផា ទៅថ្ងៃអនាគតគ្មានលោកវេជ្ជបណ្ឌិត បេអាត រិចន្នឺរ ខណៈដែលលោក អ៊ុច បូររិទ្ធ បានថ្លែងបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជាបានប្រកាស កាត់លុយចំនួន២ដុល្លារពីភ្ញៀវទេសចរណ៍បរទេស ដែលចូលទស្សនាប្រាសាទអង្គរវត្ត ចូលមូលនិធិសំរាប់ជួយមន្ទីរពេទ្យគន្ធបុប្ផា។

## ចិនច្រានចោលការសម្រេចរបស់តុលាការអាជ្ញាកណ្តាលអន្តរជាតិទីក្រុងឡាអេ

បើទោះបីជាតុលាការអាជ្ញាកណ្តាលអន្តរជាតិនាទីក្រុងឡាអេ បានប្រកាសថា ចិនមិនមានសិទ្ធិស្របច្បាប់នៅក្នុងការកាន់កាប់ទឹកដីនៅកោះជម្លោះនាដែនសមុទ្រចិនខាងត្បូង ដែលប្តឹងដោយហ្វីលីពីនក៏ដោយក៏រដ្ឋាភិបាលក្រុងប៉េកាំងនៅតែបន្តកាន់កាប់ទឹកដីនោះដដែល។

អាជ្ញាធរ នៅក្នុងទីក្រុងប៉េកាំងត្រូវបានប្រកាសច្រានចោលការសម្រេចនោះដោយអះអាងថា នេះគឺជាដែនអធិបតេយ្យរបស់ខ្លួន។ បន្ទាប់ពីការសម្រេចនេះ នៅថ្ងៃទី១៩ ខែកក្កដា ចិនបានប្រកាសចាប់ផ្តើមសមយុទ្ធយោធាលើកទី២របស់ខ្លួន រយៈពេល២សប្តាហ៍នៅសមុទ្រចិនខាងត្បូង ដែលក្រុមមេដឹកនាំកងទ័ពចិនបានព្រមានសហរដ្ឋអាមេរិកថា សេរីភាពនៃការល្បាតដោយធ្វើនាវាចរណ៍របស់ខ្លួនអាចមិនសម្រេចបានផលដូចបំណង។

លោក វូ សេងលី ប្រមុខដឹកនាំកងទ័ពជើងទឹកចិន បាននិយាយប្រាប់លោក ចនរីឆាតសុន ឧត្តមនាវីអាមេរិកដែលបានកំពុងធ្វើទស្សនកិច្ចនៅចិនថា ចិននឹងមិនបោះបង់ចោលអធិបតេយ្យភាព និងសិទ្ធិរបស់ខ្លួននៅសមុទ្រចិនខាងត្បូងនោះទេ។

លោកក៏បានប្រកាសតបតតាមគ្រប់រូបភាព អាស្រ័យលើកម្រិតនៃការគំរាមកំហែងដែលចិនប្រឈមប៉ុណ្ណោះ។

ក្រៅពីសមយុទ្ធយោធា កងកម្លាំងជើងអាកាសនៃកងទ័ពរំដោះប្រជាជនចិនក៏បានបញ្ជូនយន្តហោះទម្លាក់គ្រាប់បែកនុយក្លេអ៊ែរទៅសមុទ្រចិនខាងត្បូងផងដែរ។

កងទ័ពចិនក៏បានបញ្ជូនយន្តហោះទម្លាក់គ្រាប់បែកនុយក្លេអ៊ែរ បើកក្នុងចម្ងាយឆ្ងាយហោះវិលប្រជុំកោះជម្លោះក្នុងសមុទ្រចិនខាងត្បូង។



*លោកបូជាចារ្យ ហ្វ្រង់ស្វ័រ ប៉ុងសូង៍*

សូមបងប្អូនអានអត្ថបទទី ២ ក្នុងអាទិត្យ ទាំងប៉ុន្មានខាងក្រោយនេះ មួយៗ បីបួនដង ទាំងយកចិត្តទុកដាក់ រិះគិតពិចារណា ព្រោះអត្ថបទទាំងនោះសំខាន់បំផុត តែពិបាកយល់បន្តិច។

### ថ្ងៃទី៣ កក្កដា ២០១៦ ត្រូវនឹងថ្ងៃអាទិត្យទី១៤ ក្នុងរដូវធម្មតា

លិខិតរបស់គ្រីស្តទូតប៉ូលផ្ញើជូនគ្រីស្តបរិស័ទនៅស្រុកកាឡាទី៦: ១៤-១៨

*បងប្អូនជាទីស្រឡាញ់![១៧]ខ្ញុំមិនយកអ្វីមកអួតខ្លួនក្រៅពីឈើឆ្កាងរបស់ព្រះយេស៊ូគ្រីស្តជាព្រះអម្ចាស់នៃយើងឡើយ។ ដោយសារឈើឆ្កាងនេះ អ្វីៗក្នុងពិភពលោកជាប់ឈើឆ្កាង ហើយខ្ញុំក៏ជាប់ឈើឆ្កាងដែរ គឺខ្ញុំលែងពាក់ព័ន្ធនឹងពិភពលោកទៀតហើយ។ [១៥] ពិធីកាត់ស្បែកឬមិនកាត់ស្បែក មិនសំខាន់អ្វីទេ មានតែការកើតជាថ្មីវិញឯណោះ ទើបសំខាន់។*

គ្រីស្តបរិស័ទនៅស្រុកកាឡាទីជាច្រើនវិលទៅកាន់តាមធម្មវិន័យរបស់លោកម៉ូសេវិញ ដោយធ្វើពិធីកាត់ស្បែកមក ពឹងផ្អែកវិញ។ គ្រីស្តូទប៉ូលស្តីបន្ទោសគេថា គ្រីស្តបរីស័ទផ្ញើជីវិតទាំងស្រុងលើព្រះយេស៊ូដែលបានបូជាព្រះជន្ម សម្រាប់យើង អ្វីៗផ្សេងទៀតគ្មានសារៈសំខាន់ទាល់តែសោះ គឺប្រពៃណីសាសនា និងពិធីបុណ្យផ្សេងៗ គ្មានសារៈសំខាន់សោះ ក្រៅពីមានគោលដៅដាស់តឿនជំនឿរបស់ខ្លួនប៉ុណ្ណោះឲ្យផ្ញើជីវិតលើព្រះគ្រីស្ត។ យើងសុខចិត្តលះបង់ អ្វីៗទាំងអស់ក្នុងពិភពលោក ដូចយកអ្វីទាំងនោះមកភ្ជាប់ឈើឆ្កាង គឺយើងមិនខិតខំរកទ្រព្យសម្បត្តិ រកកិត្តិយស ចង់បានឡានធំៗ រកប្រព្រឹត្តតាមកាមគុណថោកទៀប ការសប្បាយភ្លើតភ្លើន ការពុករលួយ និងខិតខំចង់បានអ្វីៗ ដែល មនុស្សឯទៀតធ្លាប់រាប់រកនិងចង់បាននោះឡើយ។ យើងជាគ្រីស្តបរិស័ទពិតជាបានទទួលជីវិតថ្មី ដើម្បីឲ្យយើងរស់នៅតាមបែបខុសប្លែកពីអ្នកដទៃ។ យើងចង់បានអ្វីៗទាំងនោះដែរ តែយើង យកចិត្តទុកដាក់រួមរស់ជាមួយព្រះយេស៊ូគ្រប់ពេលវេលា។ ពេលខ្ញុំគូសញ្ញាឈើឆ្កាងលីខ្លួន ខ្ញុំត្រូវតែនឹកអំពីសេចក្តីទាំងនោះ។

### ថ្ងៃទី១០ ខែកក្កដា ២០១៦ ត្រូវនឹងថ្ងៃអាទិត្យទី ១៥ ក្នុងរដូវធម្មតា

លិខិតរបស់គ្រីស្តទូតប៉ូលផ្ញើជូនគ្រីស្តបរិស័ទក្រុងកូឡូស ១:១៥-២០

*បងប្អូនជាទីស្រឡាញ់![១៥]ព្រះគ្រីស្តជាតំណាងរបស់ព្រះជាម្ចាស់ដែលមនុស្សមើលពុំឃើញ ព្រះអង្គជារៀមច្បងនៃអ្វីៗទាំងអស់ដែលព្រះជាម្ចាស់បានប្រតិស្ឋានមក ព្រដ្បិតព្រះជាម្ចាស់បានប្រតិស្ឋានអ្វីៗសព្វសារពើក្នុងអង្គព្រះគ្រីស្តទាំងអ្វីៗដែលនៅលើមេឃ ទាំងអ្វីៗដែលនៅលើផែនដី ទាំងអ្វីៗដែលមនុស្សមើលឃើញ ទាំងអ្វីៗដែលមនុស្សមើលមិនឃើញ ទាំងក្រុមទេវតា ទាំងម្ចាស់ទឹកម្ចាស់ដី ទាំងវត្ថុសក្តិសិទ្ធិ និងអ្វីៗដ៏អរូបី ដែលមានអំណាច គឺព្រះជាម្ចាស់បានប្រតិស្ឋានអ្វីៗទាំងអស់ដោយសារព្រះគ្រីស្ត និងសម្រាប់ព្រះគ្រីស្ត។*

*[១៧]ព្រះគ្រីស្តមានព្រះជន្មមុនអ្វីៗទាំងអស់ ហើយអ្វីៗទាំងអស់ក៏នៅស្ថិតស្ថេររួមគ្នា ដោយសារព្រះអង្គដែរ។*

សូមអានអត្ថបទនេះមួយៗ បីបួនដង ទាំងរិះគិតនិងអធិដ្ឋាន។ គ្រីស្តបរិស័ទក្រុងកូឡូស ចូលចិត្តរិះគិតតាមទស្សនវិជ្ជាក្រិកស្តីអំពីធាតុទាំងបួន (ទឹក ភ្លើង ខ្យល់ ដី) និងអំពីអំណាចដ៏អរូបីទាំងឡាយដែលត្រួតត្រាពិភពលោក មានយ៉ុយក្ស អារក្ស អ្នកតា ទេវតាព្រៃភ្នំម្ចាស់ទឹកម្ចាស់ដី និងវត្ថុស័ក្តិសិទ្ធិជាដើម។ គ្រីស្តបរិស័ទខ្លះរាប់បញ្ចូលព្រះគ្រីស្តក្នុងចំណោមអំណាចទាំងនោះដែរ។ ហេតុនេះ គ្រីស្តទូតប៉ូលបញ្ជាក់ថា ព្រះយេស៊ូពិតជាមនុស្សដូចមនុស្សឯទៀតៗ តែព្រះអង្គក៏ពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់ផងដែរ។ ព្រះអង្គជាព្រះអម្ចាស់ដែលគ្រប់គ្រងលើសត្វលោកទាំងអស់ ទ្រង់ក៏មានអំណាចលើវត្ថុស័ក្តិសិទ្ធិទាំងឡាយ ទាំងនៅលើផែនដី ទាំងនៅលើមេឃ។ តើយើងជាគ្រីស្តបរិស័ទខ្មែរ ដែលខ្លាចខ្មោចបិសាចទៀតដូចគេឬទេ? ព្រះអង្គបានឈ្នះវាហើយ។ យើងជាគ្រីស្តបរិស័ទ សូមផ្ញើជីវិតទាំងស្រុងលើព្រះគ្រីស្តជាព្រះអម្ចាស់លើអ្វីៗទាំងអស់។

### ថ្ងៃទី ១៧ ខែកក្កដា ២០១៦ ត្រូវ នឹងថ្ងៃអាទិត្យទី ១៦ ក្នុងរដូវធម្មតា

លិខិតរបស់គ្រីស្តទូតប៉ូលផ្ញើជូនគ្រីស្តបរិស័ទក្រុងកូឡូស ១:២៥-២៨

*បងប្អូនជាទីស្រឡាញ់![២៥]ខ្ញុំបានទទួលមុខងារបម្រើព្រះសហគមន៍ តាមការចាត់ចែងរបស់ព្រះជាម្ចាស់ ដែលបានផ្ញើមុខងារនេះមកខ្ញុំសម្រាប់បងប្អូន ពោលគឺបង្ហើយការប្រកាសព្រះបន្ទូលរបស់ព្រះអង្គឲ្យបានសព្វគ្រប់។ [២៦]នេះហើយជាគម្រោងការដែលព្រះជាម្ចាស់បានលាក់ទុកតាំងពីយូរអង្វែងតរៀងមក។ [២៧] ព្រះជាម្ចាស់សព្វព្រះហឫទ័យសម្តែងសិរីរុងរឿងដ៏លើសលប់នៃគម្រោងការនេះនៅក្នុងចំណោមជនជាតិដទៃ ពោលគឺ ព្រះគ្រីស្តគង់នៅក្នុងចំណោមបងប្អូន។*

ព្រះគ្រីស្តបានផ្ញើមុខងារមួយឲ្យគ្រីស្តបរិស័ទយើងម្នាក់ៗបំពេញក្នុងព្រះសហគមន៍ និងក្នុងពិភពលោក។ សូមបងប្អូនរិះគិតបន្តិចសិន ឲ្យស្គាល់មុខងារដែលព្រះជាម្ចាស់បានផ្ញើមកខ្លួន។ ការបម្រើក្រុមគ្រួសារឬ? ការជួយសម្រុះសម្រួលអ្នកដែលទាស់ទែងគ្នាឬ? ការសម្តែងមេត្តាករុណាដល់អ្នកក្រីក្រឬ? ការខិតខំរក យុត្តិធម៌សម្រាប់អ្នកតូចតាចឬ? ការបង្រៀនកូនក្មេងឬ? ការអប់រំជំនឿឬ? ប្រសិនបើយើងជា គ្រីស្តបរិស័ទបំពេញការងារបម្រើអ្នកដទៃ យើងបង្ហើយគម្រោងការរបស់ព្រះជាម្ចាស់ ដែលព្រះអង្គសព្វព្រះ ហឫទ័យឲ្យយើងបង្ហើយការប្រតិស្ឋានពិភពលោកតាមរបៀបផ្សេងៗ។ ប្រសិនបើយើងបម្រើអ្នកដទៃដូច្នេះ ព្រះគ្រីស្តពិតជាគង់នៅជាមួយមនុស្សលោកនាបច្ចុប្បន្នកាលនេះមែន។

### ថ្ងៃទី ២៤ ខែកក្កដា ២០១៦ ត្រូវនឹងថ្ងៃអាទិត្យទី ១៧ ក្នុងរដូវធម្មតា

លិខិតរបស់គ្រីស្តទូតប៉ូលផ្ញើជូនគ្រីស្តបរិស័ទក្រុងកូឡូស ២:១២-១៤

*បងប្អូនជាទីស្រឡាញ់![១២]ដោយបងប្អូនទទួលពិធីជ្រមុជទឹក បងប្អូនត្រូវបានកប់ក្នុងផ្នូររួមជាមួយព្រះគ្រីស្ត ហើយបងប្អូនក៏ទទួលជីវិតថ្មីរួមជាមួយព្រះអង្គដែរ ដោយបងប្អូនបានផ្ញើជីវិតលើមហិទ្ធិឫទ្ធិរបស់ព្រះជាម្ចាស់ដែលបានប្រោសព្រះគ្រីស្តឲ្យតើនឡើងពីចំណោមមនុស្សស្លាប់។*

យើងជាគ្រីស្តបរិស័ទរួមស្លាប់រួមរស់ជាមួយព្រះគ្រីស្តដែលសោយទិវង្គតនិងមានព្រះជន្មថ្មីដ៏រុងរឿង។ យើងក៏ បានជីវិតថ្មី គឺបានទទួលព្រះជន្មផ្ទាល់របស់ព្រះគ្រីស្តក្នុងខ្លួន។ ហេតុនេះ យើងក៏លែងរស់នៅតាមរបៀប មនុស្សលោកធម្មតាទៀតហើយ។ អគ្គសញ្ញាជ្រមុជទឹក មិនមែនជារង្វាន់ទេ តែដោយអគ្គសញ្ញាជ្រមុជទឹក ព្រះយេស៊ូរស់នៅក្នុងខ្លួនយើង ព្រះអង្គជម្រុញយើងឲ្យធ្វើជាសាក្សីអំពីជីវិតថ្មី ដែលយើងបានទទួល គឺយើងកាន់តាមវិន័យនៃសេចក្តីស្រឡាញ់ យើងមិនរកស៊ីខូច មិនពុករលួយ មិនខែបន្លំ មិនលួចប្លន់គេ។ល។ ប្រសិនបើគ្រីស្តបរិស័ទទាំងអស់នៅប្រទេសកម្ពុជា ហ៊ានផ្តល់សក្ខីភាពអំពីជីវិតថ្មីរបស់ព្រះគ្រីស្តដែលខ្លួន បានទទួលនោះ មុខជាសង្គមផ្លាស់ប្តូរឲ្យបានប្រសើរជាងសង្គមសព្វថ្ងៃនេះមិនខាន។

### ថ្ងៃទី ៣១ ខែកក្កដា ២០១៦ ត្រូវនឹងថ្ងៃអាទិត្យទី ១៨ ក្នុងរដូវធម្មតា

លិខិតរបស់គ្រីស្តទូតប៉ូលផ្ញើជូនគ្រីស្តបរិស័ទក្រុងកូឡូស ៣:១-៥.១៩

*បងប្អូនជាទីស្រឡាញ់![១]ហេតុនេះ បើបងប្អូនទទួលជីវិតថ្មីរួមជាមួយព្រះគ្រីស្តដូច្នេះទៅហើយ ចូរស្វែងរកអ្វីៗនៅស្ថានលើជាស្ថានដែលព្រះគ្រីស្តគង់នៅខាងស្តាំព្រះជាម្ចាស់នោះវិញ។[២]ចូរនឹកគិតពីអ្វីៗដែលនៅស្ថានលើកុំនឹកគិតពីអ្វីៗនៅលើផែនដីនេះឡើយ [៣] ដ្បិតបងប្អូនបានស្លាប់ផុតទៅហើយ ហើយជីវិតរបស់បងប្អូនក៏ត្រូវបានលាក់ទុកជាមួយព្រះគ្រីស្តក្នុងព្រះជាម្ចាស់ដែរ។ ហេតុនេះ សូមបងប្អូនសម្លាប់អ្វីៗខាងលោកីយ៍ក្នុង ខ្លួនបងប្អូនចោលទៅ គឺកាមគុណថោកទាប អំពើសៅហ្មង តណ្ហាអាក្រក់ និងចិត្តលោភលន់(ដែលជាការយកទ្រព្យសម្បត្តិគោរពទុកជាព្រះ)។ [១១]ដូច្នេះ ព្រះគ្រីស្តនឹងបានបំពេញអ្វីៗទាំងអស់ក្នុងមនុស្សទាំងអស់។*

គ្រីស្តទូតប៉ូលបញ្ជាក់យ៉ាងច្បាស់ថា ដោយយើងទទួលអគ្គសញ្ញាជ្រមុជទឹក គឺយើងបានទទួលជីវិតថ្មី គឺជាព្រះជន្មផ្ទាល់របស់ព្រះគ្រីស្តដែលមានព្រះជន្មថ្មីដ៏រុងរឿងហើយ។ ដូច្នេះយើងជាគ្រីស្តបរិស័ទ ត្រូវខិតខំរកសម្បត្តិសួគ៌ដូចព្រះគ្រីស្តបានស្វែងរកដែរ គឺមានចិត្តមេត្តាករុណា ចិត្តសុភាពាបសារ ចិត្តស្លូតបូត ចិត្តអត់ធ្មត់ ខន្តី បេះអត់ទោសទៅវិញទោមក។ល។ គ្រីស្តបរិស័ទមិនគ្រាន់តែ ផ្ញើជីវិតលើព្រះគ្រីស្តជាព្រះសង្គ្រោះ ប៉ុណ្ណោះទេ តែជាអ្នកដែលយកចិត្តទុកដាក់រួមរស់ជាមួយព្រះអង្គ។ យើងរស់នៅលើផែនដីនេះ ដោយមានចិត្តរួមជាមួយព្រះគ្រីស្ត ដែលតែងតែបែរទៅរកព្រះបិតាជានិច្ច។ យើងយកចិត្តទុកដាក់ធ្វើអំពើល្អ ឲ្យបានស្របតាមកិត្តិយសដ៏ខ្ពង់ខ្ពស់បំផុតរបស់ខ្លួនជាបុត្រធីតារបស់ព្រះបិតា។

# រូបភាពសកម្មភាពព្រះសហគមន៍កាតូលិក



ការណ៍អស្ចារ្យនៃភូមិសុខសាន្ត! អំណាចនៃសេចក្តីស្រឡាញ់!

*កញ្ញាស្រីអូល អាយុ ១៧ឆ្នាំ និយាយមិនកើតតាំងពីកំណើត។ កាលពីពីរសប្តាហ៍មុន ប្អូនស្រីអូលអាចនិយាយបាន។ ប្អូនប្រុស ភា អាយុ ៤ឆ្នាំ មិនអាចដើរបាន។ កាលពីមួយសប្តាហ៍ ប្អូនអាចដើរបាន!!!។ "ព្រះវិញ្ញាណដ៏វិសុទ្ធនៃព្រះអម្ចាស់គង់សណ្ឋិតលើខ្ញុំ។ ដ្បិតព្រះអង្គបានលាបប្រេងអភិសេកខ្ញុំឲ្យប្រកាសដំណឹងល្អដល់អ្នកក្រីក្រ។ ព្រះអង្គបានចាត់ខ្ញុំទៅប្រកាសសេរីភាពដល់អ្នកជាប់ពន្ធនាគារ និងប្រោះមនុស្សខ្វាក់ឲ្យមើលឃើញ ដោះលែងអ្នកត្រូវគេជិះជាន់ឲ្យមានសេរីភាព ប្រកាសឆ្នាំនៃព្រះហឫទ័យរបស់ព្រះអម្ចាស់"។*

Peace Village Miracles ! Power of Love !

*Ol is 17 years old. She cannot not speak since her birth. Since 2 weeks she can speak ! Phear is 4 years old, he cannot walk.... Since one week, he can walk !!!!! "The Spirit of the Lord is on me, because he has anointed me to proclaim good news to the poor. He has sent me to proclaim freedom for the prisoners and recovery of sight for the blind, to set the oppressed free, to proclaim the year of the Lord's favor."*



*មណ្ឌលសុខសុខភាព ពេទ្យឃាយជី នៃព្រះសហគមន៍កាតូលិកបាត់ដំបង ផ្នែកព្យាបាលសរសៃ ដោយចលនា និងចាក់ម្ជុលវិទ្យាសាស្ត្រ បានអភិវឌ្ឍបន្ថែមចំនួនសម្ភារៈ ម៉ាស៊ីនស្ទែនសរសៃ ពង្រឹងសម្ថភាពបុគ្គលិកក្នុងចាក់ម្ជុលវិទ្យាសាស្ត្រ និងធ្វើចលនា។ ពេលនេះលទ្ធភាព។*

## ទិវាយុវជនពិភពលោក២០១៦



# វិទ្យុវ៉ារីតាស់អាស៊ីខេមរភាសា

## សំលេងពីព្រះសហគមន៍កាតូលិកកម្ពុជា

**-ផ្សាយតាមរលកធាតុអាកាស FM**

| | | |
|---|---|---|
| **ភ្នំពេញ** | : FM 104 Mhz | **ម៉ោង ៥:០០- ៦:០០ រាល់ថ្ងៃ** |
| **បាត់ដំបង** | : FM 91.0 Mhz | **ម៉ោង ៧:៣០- ៨:៣០ រាល់ថ្ងៃ** |
| **សៀមរាប** | : FM 98.75 Mhz | **ម៉ោង ៥:០០- ៦:០០យប់ រាល់ថ្ងៃ** |
| **កំពង់ធំ** | : FM 103.5 Mhz | **ម៉ោង ៧:០០- ៨:០០យប់ រាល់ថ្ងៃ** |
| **កំពង់ចាម** | : FM 100.5 Mhz | **ម៉ោង ៧:០០- ៨:០០ រាល់ថ្ងៃ** |
| **ព្រះសីហានុ** | : FM 100.5 Mhz | **ម៉ោង ៦:០០- ៧:០០ រាល់ថ្ងៃ** |
| **កំពត** | : FM 93.25 Mhz | **ម៉ោង ៥:០០- ៦:០០ រាល់ថ្ងៃ** |

**-ផ្សាយតាមរលកធាតុអាកាសខ្លី (SW)**

ជាភាសាខ្មែររយៈពេល ៣០ នាទីរាល់ថ្ងៃពីម៉ោង ៥:០០-៥:៣០នាទីល្ងាច តាមរលកធាតុអាកាសខ្លី ១១៨៥០ គីឡូហឺតស៍ ត្រូវនឹងកម្ពស់ ២៥,៣២ ម៉ែត្រ។

**- តាមប្រព័ន្ធអ៊ីនធឺណែត ២៤ម៉ោង**

លោកអ្នកអាចស្តាប់កម្មវិធីវិទ្យុវ៉ារីតាស់អាស៊ី ភាសាខ្មែរ ២៤ម៉ោង តាមរយៈទូរស័ព្ទ Smart Phone ដែលប្រើប្រព័ន្ធ Android ឬ ប្រព័ន្ធ IOS ដោយគ្រាន់តែចូលទៅកាន់ Play Store ឬ App Store វាយពាក្យ Radio Varitas Asia រួច Download កម្មវិធីនោះដោយស្វែងរកប៊ូតុង (Khmer Live Audio)។

ឬ តាមរយៈវេបសាយ៖ http://khmer.rveritas-asia.org